01188259



ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2016, 10:03
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣៥៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

លោក ឯម ហ៊ុយ

លោក នីកូឡូ ប៉ុងស៍*(Mr. Niccolo PONS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក សុះ រំលី (2-TCW-904) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សុះ រំលី** (2-TCW-904)

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី.............................................. ទំព័រ ២
សួរដោយលោក វ៉ែន ពៅ ផ្ដើមពី .............................................. ទំព័រ ៣០
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.............................................. ទំព័រ ៣៤
សួរដោយកញ្ញា អង់តា ហ្គិសសេ ផ្ដើមពី.............................................. ទំព័រ ៥៦

# កិច្ចដំណើរការនីតិវិធី

[០៩:០២:៣០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរកានីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី សុះ រំលី បន្តបញ្ចប់។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក សុះ រំលី លោកនិងមេធាវីប្រឹក្សារបស់លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរមិនមានសាក្សីបម្រុងទេ។

សូមអរគុណលោកប្រធាន។

[០៩:០៣:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊ុយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ដោយថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន និងមិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំ

លះបង់សិទ្ធិចូលរួច និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៨ ខែ មករា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ និងវិលមុខពេលអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើការសវនាការពីបន្ទប់ខាងក្រោមស្ថិតនៅខាងក្រោមសាលសវនាការនេះ។

ហើយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក នីកូឡាស គូមជែន៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

[០៩:០៥:៤៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកអាចប្រាប់បានទេ ថាតើលោកទទួលបានការអប់រំបណ្ដុះបណ្ដាលកម្រិតណាដែរ គឺនៅមុនឆ្នាំ៧០?

**លោក សុះ វំលី៖**

**ឆ៖** មុនឆ្នាំ៧០ ខ្ញុំមិនដែលបានទទួលបណ្ដុះបណ្ដាលអ្វីទេ ខ្ញុំមិនដែលស្គាល់ថាអ្វីទេកាលហ្នឹង។

**ស៖** សូមអរគុណ។ លោកបញ្ជាក់ថា គេជ្រើសរើសលោកធ្វើស្មៀនឃុំដោយសារតែអក្សរ

ស្អាត។ ប៉ុន្តែលោកថាលោកអត់ដែលបានរៀនទេ ប៉ុន្តែខ្ញុំចង់ដឹងថាតើលោកចេះសរសេរអក្សរហ្នឹងដោយរបៀបណា? តើលោករៀននៅសាលារបស់ជនជាតិ -- សាលាចាមមែនដែរឬទេ?

**ឆ៖** ខ្ញុំបានរៀនសាលាបឋមសិក្សាទ្រា ថ្នាក់ទី៣។ ហើយក្រោយពីរៀន ខ្ញុំបានព្យាយាមមើលកាសែត ហើយនិងអានឯកសារជាច្រើន។

[០៩:០៧:០៧]

**ស៖** សូមអរគុណលោកសាក្សី។ មុនឆ្នាំ៧០ ថាតើលោកកាន់សាសនាអ៊ីស្លាមមែនទេ?

**ឆ៖** បាទ សាសនាអ៊ីស្លាម។

**ស៖** លោកសាក្សី តើលោកចាំទេថានៅថ្ងៃ១៧ មេសា ៧៥ គឺថ្ងៃដែលខ្មែរ -- ដែលទីក្រុងភ្នំពេញធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម។ តើលោកនៅចាំអំពីថ្ងៃនោះទេ?

**ឆ៖** ខ្ញុំចាំបាននៅថ្ងៃទី១៧ មេសា។

**ស៖** ក្រោយថ្ងៃ១៧ មេសា ៧៥ រហូតដល់ចុងឆ្នាំ៧៩ តើមានការផ្លាស់ប្តូរអ្វីខ្លះចំពោះជនជាតិចាមនៅទ្រា?

**ឆ៖** នៅឆ្នាំ១៩៧៥ នៅភូមិទ្រា ពួកខ្មែរក្រហមបានចាប់ផ្តើមបិទព្រះវិហារ ស៊ូរ៉ាវ ហើយនិងមិនឲ្យចូលថ្វាយបង្គំ ឬមួយថ្វាយបង្គំក្នុងផ្ទះក៏មិនឲ្យដែរ។ ហើយឲ្យស្ត្រីហ្នឹងកាត់សក់ខ្លី ខុសពីប្រពៃណីអ៊ីស្លាម។

**ស៖** នៅមុនថ្ងៃ១៧ មេសា ៧៥ ថាតើជនជាតិចាមនៅក្នុងឃុំទ្រាហ្នឹង គាត់បួងសួងថ្វាយបង្គំព្រះដែរឬទេបើតាមខ្ញុំដឹងគឺថាតាមសាសនាអ៊ីស្លាម គេថ្វាយបង្គំប្រាំដងក្នុងមួយថ្ងៃ តើជនជាតិចាមនៅភូមិទ្រា គាត់អនុវត្តបែបនេះទេ?

**ឆ៖** បាទ មុនឆ្នាំ៧៥ សហគមន៍អ៊ីស្លាម សហគមន៍ចាមនៅភូមិទ្រាហ្នឹង បានថ្វាយបង្គំមួយថ្ងៃមួយយប់ប្រាំដង។ ហើយក្នុងប្រាំពីរថ្ងៃ ថ្ងៃសុក្របានទៅជួបជុំគ្នានៅវិហារថ្វាយបង្គំថ្ងៃសុក្រម្តង។

[០៩:១០:០០]

**ស៖** លោកនិយាយថា ក្រោយ៧៥ គេថាក្រោយពេលដែលរបប លន់ នល់ ដួលទៅ គេលែងអនុញ្ញាតឲ្យថ្វាយបង្គំព្រះហើយ។ ដូច្នេះ ខ្ញុំចង់សួរថា តើខ្មែរក្រហមនៅក្នុងតំបន់របស់លោកហ្នឹង តើគេហាមឃាត់ប្រជាជនមិនឲ្យទៅថ្វាយបង្គំព្រះ មិនឲ្យទៅវិហារចាមហ្នឹង គឺហាមឃាត់ដោយរបៀបណាដែរ?

**ឆ៖** គេហាមឃាត់តាមរបៀបប្រជុំ។ គេប្រជុំថា សាសនាអត់មានផលប្រយោជន៍អី។ ជាសាសនាប្រតិកិរិយា។ អ៊ីចឹង ហាមមិនឲ្យថ្វាយបង្គំក្នុងវិហារ ឬតាមស៊ូរ៉ាវ ឬក្នុងផ្ទះខ្លួនឯង។

**ស៖** លោកសាក្សី ខ្ញុំសង្កេតឃើញថា កាលពីថ្ងៃពុធ ក៏ដូចជាថ្ងៃហ្នឹង ខ្ញុំឃើញលោកពាក់មួកកាតិបជនជាតិចាម។ តើមួកដែលលោកពាក់ហ្នឹងជាប្រពៃណីរបស់ជនជាតិ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាប្រពៃណីជនជាតិចាម។

**ស៖** ចាប់ពីខែមេសា ៧៥ រហូតទៅដល់ដាច់ឆ្នាំ៧៨ ថាតើនៅក្នុងភូមិទ្រា ទាំងលោកទាំងជនជាតិចាមដទៃទៀត ថាតើបុរសៗគេអនុញ្ញាតឲ្យពាក់មួយកាតិបដែរឬទេ? ហើយនារីៗគេអនុញ្ញាតឲ្យពាក់ស្បៃគ្របមុខដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ។

ខ្ញុំមិនជំទាស់ទៅលើសំណួរនេះទេ ប៉ុន្តែវាជាការសង្កេតរបស់ខ្ញុំមួយ ពាក់ព័ន្ធទៅសំណួរដែលព្រះរាជអាជ្ញាសួរគឺជាសំណួរដែលមិនប្រាកដ។ ខ្ញុំមិនប្រាកដថាហេតុអ្វីបានព្រះរាជអាជ្ញាសួរតែត្រឹមពីថ្ងៃ ត្រឹមពីខែមេសា ៧៥ ប៉ុណ្ណោះ ព្រោះថាមានភស្តុតាងជាច្រើនបានបង្ហាញថា តំបន់គឺថាបានកើតឡើងនៅក្នុងឆ្នាំ៧៧ ឯណោះ។ ខ្ញុំមិនយល់ថាហេតុអ្វីបានជាព្រះរាជអាជ្ញាធ្វើបែបនេះទេ។ ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា ភស្តុតាងបានបង្ហាញជាច្រើនថា អ្វីៗបានប្រែប្រួលខ្លាំងចាប់ពីខែមេសា ៧៥មក។

[០៩:១២:៤៣]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថាប្រហែលជាមេធាវីការពារក្តីគាត់មិនចង់និយាយថា ខុសពីយុត្តាធិកាពេលវេលា ហើយប៉ុន្តែយុត្តាធិកាពេលវេលាតុលាការចាប់ផ្តើមពីខែមេសា ៧៥។ ដូច្នេះ ខ្ញុំសូមបន្ត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរថាតើមួកកាតិបដែលលោកពាក់ថ្ងៃហ្នឹង ហើយនិងកន្សែងទទូរបាំងមុខដែលជនជាតិចាមជានារីគាត់ពាក់ហ្នឹង តើនៅខែមេសា ៧៥ តទៅហ្នឹង គេអនុញ្ញាតឲ្យពាក់ឬអត់?

**លោក សុះ រំលី៖**

ឆ៖ គេមិនអនុញ្ញាតឲ្យពាក់ជាដាច់ខាតតែម្តង។

ស៖ ថាតើមានជនជាតិចាមណាម្នាក់បដិសេធមិនអនុវត្តតាមការហាមឃាត់ហ្នឹងទេ? បានន័យថាតើមានជនជាតិចាមណាម្នាក់ ថាតើមានជនជាតិចាមណាម្នាក់គាត់នៅតែបន្តថ្វាយបង្គំព្រះ គាត់នៅតែបន្តពាក់មួកកាតិបអីហ្នឹងដែរឬទេ?

ឆ៖ បាទ អត់មានទេ ព្រោះអីគេទាំងអស់ ពួកគេទាំងអស់ខ្លាច។ ក្រោយពីបង្ក្រាបនៅស្វាយឃ្លាំងរួច នៅភូមិទ្រាគេខ្លាចតែម្តង។ គេខ្លាចតែមកដល់គេមកបង្ក្រាបនៅភូមិទ្រាទៀត ចាប់ចងមនុស្សជាច្រើននៅឆ្នាំ៧៥ ហ្នឹង ហើយសហករណ៍ចាមទាំងអស់នុំងខ្លាចតែម្តង អត់ហ៊ានទេ អត់ហ៊ានប្រឆាំងតតាំងទេ។

[០៩:១៤:៣៤]

ស៖ តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាប្រជាជនខ្លាច? តើមានមូលហេតុអីដែលធ្វើឲ្យប្រជាជនគាត់ខ្លាចនៅឆ្នាំ៧៥ ហ្នឹង ក្រោយពីលោកថាមានការកម្ទេចនៅ ក្រោយពីមានការកម្ទេចនៅស្វាយឃ្លាំងហ្នឹង?

ឆ៖ គេខ្លាច ព្រោះអីមុនថ្ងៃ១៧ មេសា ក៏មានការចាប់ចង ដូចជា ហាកឹម តួន មេចំអះ ឬមួយអ្នកចេះដឹង មានពេទ្យ មានអី គេចាប់អស់ច្រើនហើយ ព្រោះអីអ្នកក្រោយហ្នឹង គេខ្លាចតែម្តង។

ស៖ តើអ្នកដែលគេចាប់ខ្លួនហ្នឹង តើមានអ្វីកើតឡើងចំពោះរូប ចំពោះពួកគាត់ទេ លោកដឹងទេ?

ឆ៖ ខ្ញុំមិនដឹងទេ គ្រាន់តែគាត់ជាមានមុខងារតែប៉ុណ្ណោះ។

ស៖ នៅពេលដែលលោកខ្លាចជាស្មៀនឃុំ ថាតើអ្នកណាជាមេឃុំ?

ឆ៖ បាទ ដំបូងឈ្មោះ ឈាន។

ស៖ តើមានអ្វីកើតឡើងចំពោះ ឈាន?

ឆ៖ សុំសំណួរម្តងទៀត ព្រោះខ្ញុំអត់យល់ កើតឡើងយ៉ាងម៉េច ខ្ញុំអត់យល់។

ស៖ តើ ឈាន គាត់នៅបន្តតួនាទីជាមេឃុំរហូត ឬមួយក៏យ៉ាងណាដែរ? តើលោកដឹងទេ ថាមានអ្វីកើតឡើងចំពោះគាត់ ថាតើគាត់ត្រូវបានគេផ្ទេរចេញ ឬក៏ត្រូវបានគេចាប់ខ្លួន ឬក៏យ៉ាងម៉េចដែរ?

ឆ៖ បាទ ឈាន នៅឆ្នាំ១៩៧៧ ឈាន ត្រូវចាប់ខ្លួន ដោយសារគេចោទថា ឮគេថាក្បត់បក្ស។

ស៖ តើលោកដឹងទេថាមានអ្វីកើតឡើងចំពោះគាត់ ក្រោយពេលដែលគេចាប់ខ្លួនគាត់យកទៅ?

**ឆ៖** ក្រោយមក ឮថាស្លាប់ហើយ គេសម្លាប់ហើយ។

**ស៖** តើអ្នកណាមកជំនួសតួនាទីរបស់ ឈាន?

**ឆ៖** ក្រោយពីចាប់ ឈាន ទៅគឺគេផ្តល់មកវិញនូវកម្មាភិបាលសន្តិសុខ ខាងសន្តិសុខស្រុកក្រូចឆ្មារហ្នឹងម្នាក់ ឈ្មោះ ស៊ឹម។ អនុ ម្នាក់ឈ្មោះ ហាន មកពីកសិកម្ម។

**ស៖** តើ ចុះចំពោះ ស៊ឹម ហើយនិង ហាន ហ្នឹងវិញ មានអ្វីកើតឡើងដែរចំពោះពួកគេ?

**ឆ៖** គាត់ទាំងពីរហ្នឹងនៅឆ្នាំ១៩៧៨ ពាក់កណ្តាល១៩៧៨ហ្នឹង គាត់ត្រូវចាប់ខ្លួនទៀត ដោយខាងភូមិកណ្តាលទៅចាប់។

**ស៖** តើលោកដឹងដែរឬទេ ថាតើអ្នកណាជាអ្នកបញ្ជាឲ្យចាប់ខ្លួនពួកគាត់ហ្នឹង បើលោកដឹងលោកប្រាប់យើង បើលោកមិនដឹងទេ លោកប្រាប់ថាមិនដឹងទៅ? ហើយខ្ញុំចង់សួរថា លោកស្គាល់អត់អ្នកដែលថាមកពីភូមិភាគកណ្តាលហ្នឹង? សូមលោកឆ្លើយ?

**ឆ៖** ខ្ញុំអត់ដឹង។ មកហ្នឹង កាលហ្នឹង ៣០នាក់ កងទាហានហ្នឹង ៣០នាក់ ប៉ុន្តែស្គាល់ថាមេគេហ្នឹងឈ្មោះ ហ្វូ តែប៉ុណ្ណឹង។

**ស៖** តើអ្នកណាអ្នកមកជំនួស ស៊ឹម ហើយនិង ហាន នៅពេលក្រោយទៀត?

**ឆ៖** ក្រោយមក ហ្វូ ហ្នឹងបានចាត់តាំងឈ្មោះ ម៉េង នៅភូមិទ្រា ហ្នឹងជាមេភូមិជំនួស។

[០៩:១៩:៥១]

**ស៖** តើ ម៉េង ហ្នឹងគាត់មកពីកន្លែងណាដែរ លោកដឹងទេ?

**ឆ៖** បាទ ម៉េង នុ៎ង គេជម្លៀសគាត់ពីភូមិព្រែកអាជី ដែលជាភូមិក្បែរខាងភូមិទ្រានុ៎ង មកនៅឃុំទ្រានុ៎ង ធ្វើជាមេឃុំ។

**ស៖** លោកបាននិយាយអំពីឈ្មោះ ហ៊ា ដែលជាអ្នកតែងតាំង ម៉េង។ ដូច្នេះខ្ញុំចង់សួរថា តើ ហ៊ា ហ្នឹង គាត់មានតួនាទីអ្វីដែរ?

**ឆ៖** តាមដឹង ម៉េង ប្រាប់ខ្ញុំថា ប្រធានស្រុកក្រូចឆ្មារហ្នឹង មកធ្វើជាប្រធានស្រុក។

**ស៖** សុំទោសលោក ទៅតាមដែលខ្ញុំស្តាប់ឮបកប្រែ គេថា ម៉េង ជាចៅហ្វាយស្រុកក្រូចឆ្មារ។ ដូច្នេះខ្ញុំគ្រាន់តែចង់សួរលោកអំពីឈ្មោះ ហ៊ា ទេ ថាតើ ហ៊ា ហ្នឹងជានរណាដែរ? តើ ហ៊ា ហ្នឹងជាមេស្រុកក្រូចឆ្មារមែនទេ?

**ឆ៖** ហ្វូ ហ្នឹងជាមេស្រុកក្រូចឆ្មារ។ ម៉េង នុ៎ង ហ្វូ ចាត់តាំងឲ្យធ្វើមេឃុំទ្រាហ្នឹង ជំនួស ស៊ឹម។

[០៩:២១:២៥]

**ស៖** ថាតើអ្នកណាមានតួនាទីធំជាង? ហ៊ា ឬក៏ ម៉េង?

**ឆ៖** ហូ ហ្នឹងហើយមាននាទីធំ ព្រោះ ហូ ចាត់តាំង ម៉េង ឲ្យធ្វើមេឃុំ។ ម៉េង ហ្នឹងជាប្រជាជននៅក្នុងឃុំទ្រាហ្នឹង។

**ស៖** ប្រហែលជាមានបញ្ហាបន្តិចបន្តួច ប៉ុន្តែតែខ្ញុំចង់សួរឡើងវិញ ថាតើ ហ៊ា គាត់មានតួនាទីអ្វីដែរ នៅពេលដែលគាត់តែងតាំង ម៉េង នោះ?

**ប្រធានអង្គជំនុំ៖**

បញ្ជាក់ឲ្យច្បាស់នៅក្នុងឯកសារដែលយើងប្រើប្រាស់កន្លងមក ហូ មិនមែន ហ៊ា ទេ។ ហើយព្រះរាជអាជ្ញារងអន្តរជាតិ ប្រយ័ត្នប្រយែងផងលើឈ្មោះនេះ កុំឲ្យមានការភ័ន្តច្រឡំ។ ឈ្មោះ ហូ ដែលនៅក្នុងការដេញដោល ក៏ដូចជាឯកសារដែលពាក់ព័ន្ធកន្លងមកនេះ គឺមានឈ្មោះ ហូ មិនមែនឈ្មោះ ហ៊ា ទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអភ័យទោសលោកសាក្សី ដែលខ្ញុំបង្កឲ្យមានការយល់ច្រឡំ។ ឥឡូវខ្ញុំសួរឡើងវិញ ហូៗ តើ ហូ ហ្នឹង គាត់មានតួនាទីអ្វីដែរ ដែលថាគាត់មានតួនាទីអ្វីដែរ ទើបគាត់អាចតែងតាំង ម៉េង ហ្នឹងឲ្យធ្វើជាមេឃុំបាននុ៎ង? ដូច្នេះខ្ញុំចង់សួរលោក ថាតើ ហូ ហ្នឹងគាត់មានតួនាទីអ្វីដែរ?

[០៩:២២:៥៥]

**លោក សុះ រំលី៖**

**ឆ៖** ហូ ទៅពីភូមិភាគកណ្តាលទៅ ដឹកនាំកងកម្លាំងប្រហែលជា៣០នាក់។ តាម ម៉េង ប្រាប់ខ្ញុំតាហូ ហ្នឹងជាប្រធានស្រុកក្រូចឆ្មារ មកៗធ្វើជាប្រធានស្រុកក្រូចឆ្មារ។

**ស៖** សូមអរគុណច្រើន។ ខ្ញុំចង់ដឹងថា តើលោកធ្វើយ៉ាង -- ធ្វើយ៉ាងណាទើបដឹងថា គាត់ហ្នឹងឈ្មោះ ហូ?

**ឆ៖** ហូ ហ្នឹងដំបូង គាត់ធ្វើនេសាទតំបន់ខាងស្រុកស្ទឹងត្រង់ហ្នឹង ហើយថ្ងៃមួយ គាត់ហៅឪក្មេកខ្ញុំទៅជួយធ្វើឧបករណ៍នេសាទ។ អ៊ីចឹងឪពុកក្មេកខ្ញុំឃើញមុខគាត់ គាត់ប្រាប់ខ្ញុំថាគាត់ហ្នឹងឈ្មោះហូ។

**ស៖** តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំជាមួយ ហូ ដែរឬទេ?

[០៩:២៤:១៤]

**ឆ៖** ក្រោយមក ខ្ញុំបានចូលរួមម្តងគត់ជាមួយ ហូ ហ្នឹង។

**ស៖** តើលោកអាចប្រាប់បានទេថា មានអ្វីកើតឡើងចំពោះប្រជាជនចាមនៅភូមិទ្រា នៅពេលដែល ហូ មកដល់?

**ឆ៖** ហូ មកដល់នុ៎ង ចាប់ឈ្មោះ ស៊ឹម ជាមេឃុំ ចាប់ឈ្មោះ ហាន ជាអនុឃុំ ព្រមទាំងចាប់ឈ្មោះ យ៉ា យ៉ូប គាត់ជាសមាជិកគណៈកម្មការស្រុកក្រូចឆ្មារហ្នឹង គាត់ជាជនជាតិចាម ទទួលបន្ទុកនេសាទ។ បីនាក់នុ៎ងចាប់មុនគេ។

[០៩:២៥:០៥]

**ស៖** សូមអរគុណ ខ្ញុំនិយាយថា -- ខ្ញុំចង់សួរថាតើបីនាក់ដែលលោកទើបតែនិយាយឈ្មោះហ្នឹងមិនមែនជាជនជាតិចាមទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ បីនាក់ហ្នឹង ជនជាតិចាមម្នាក់ ឈ្មោះ យ៉ា យ៉ូប ហ្នឹងជនជាតិចាម គាត់ជាសមាជិកគណៈកម្មាស្រុក ខេត្តក្រូចឆ្មាហ្នឹង ហើយជា គាត់ទទួលបន្ទុកខាងនេសាទស្រុក។

**ស៖** តើលោកដឹងទេថា មានអ្វីកើតឡើងចំពោះបីនាក់ដែលលោកថាគេចាប់ខ្លួនហ្នឹង គឺចាប់ខ្លួនដោយហូ ហ្នឹង។ តើមានអ្វីកើតឡើងចំពោះពួកគាត់នៅពេលក្រោយ?

**ឆ៖** ក្រោយមកគាត់ដឹកយកទៅខាងស្ទឹងត្រង់បីនាក់ហ្នឹង ហើយឮតាមគេតាមឯងហ្នឹងថាស្លាប់អស់ហើយ ទាល់សព្វថ្ងៃអត់ដែលឃើញគាត់ទេ។

**ស៖** តើ ហូ គាត់ធ្វើយ៉ាងបែបណាដែរចំពោះជនជាតិចាមនៅក្នុងកន្លែងលោកហ្នឹង?

**ឆ៖** ក្រោយមក ហូ បានហៅអង្គភាពជុំវិញឃុំ មកប្រជុំ។ មានគ្នាប្រហែលជាជាង ២០នាក់ ហើយមិនមែន ហូ ហៅទេ គាត់ឲ្យអ្នកសហការីគាត់មកជាមួយគាត់ ខ្ញុំមិនដឹងថាគាត់ធ្វើជាមុខងារអ្វីដែរ ប៉ុន្តែហៅមកប្រជុំនៅក្នុងវិហារអ៊ីស្លាមហ្នឹង។ ហើយប្រាប់ថាស្អែកឲ្យទៅរៀនសូត្រមួយខែ ទាំងអស់គ្នាហ្នឹង មកជួបជុំគ្នានៅមន្ទីរ។ គេមកយកមន្ទីរឃុំហ្នឹងជាមន្ទីរស្រុករបស់គេ ហើយគេឲ្យទៅជួបជុំគ្នានៅកន្លែងនោះ។

**ស៖** តើលោកដឹងទេ មានអ្វីកើតឡើងនៅកិច្ចប្រជុំហ្នឹងដែរ?

**ឆ៖** ក្នុងការប្រជុំហ្នឹងអត់មានអីកើតឡើងទេ គេគ្រាន់តែឲ្យយើង ស្អែកហ្នឹង គេថា "ស្អែកហ្នឹងឲ្យយកខោអាវទៅមន្ទីរស្រុកដើម្បីទៅរៀនសូត្រ"។

**ស៖** តើទាំងអស់គ្នាហ្នឹងទៅមន្ទីរស្រុកមែនទេ?

**ឆ៖** បាទ ទៅមន្ទីរស្រុក។

[០៩:២៨:១១]

**ស៖** តើមានអ្វីកើតឡើងនៅក្នុងកិច្ចប្រជុំ គឺកិច្ចប្រជុំនៅមន្ទីរស្រុកនោះ?

**ឆ៖** នៅមន្ទីរស្រុកហ្នឹង ខ្ញុំមិនដឹងទេ ប៉ុន្តែពួកគេហ្នឹង ទៅជារៀងរហូត គ្មានត្រឡប់មកវិញទេ។

**ស៖** តើលោកឃើញពួកគេម្តងទៀតទេ នៅពេលក្រោយមក?

**ឆ៖** អត់ដែលឃើញទាល់តែសោះ សូម្បីម្នាក់។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើមន្ទីរស្រុកហ្នឹងនៅកន្លែងណាដែរ? មុនហ្នឹងលោកនិយាយថាមន្ទីរស្រុកហ្នឹង គឺគេៗដូរមកពីមន្ទីរឃុំទេ តើអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនអ៊ីចឹងទេ មន្ទីរឃុំដែលធ្វើការកន្លែងមកនុ៎ង តាំងពី ឈាន, តាំងពី សឹម មកហ្នឹងជាមន្ទីរឃុំ។ ដល់ពួក ហ្វូ មកហ្នឹង មកនៅកន្លែងហ្នឹងតែម្តង ហើយអ្នកកន្លែងឃុំហ្នឹង គេនាំគ្នាចេញមកនៅតាមផ្ទះ ហើយ ម៉េង ហ្នឹង ធ្វើមេឃុំក្រោយហ្នឹងធ្វើលើផ្ទះគាត់តែម្តង។

**ស៖** ចាតើមានពេលណាមួយដែលជនជាតិចាមមកពីខាងបូព៌ាដែលមកភូមិទ្រាដែរឬទេនៅពេលក្រោយមក?

**ឆ៖** កាលនោះ មានៗមកតាមរទេះគោ គេដឹកតាមរទេះគោមកនៅភូមិទ្រាហ្នឹង ហើយគេនាំចូលទៅកន្លែងមន្ទីរស្រុកហ្នឹង។

**ស៖** តើលោកដឹងទេ ឬលោកចាំទេថា អ្នកដែលមកតាមរទេះគោហ្នឹង គាត់មកនៅប្រហែលជាពេលណាដែរ?

**ឆ៖** ភ្លាមៗហ្នឹង ភ្លាមៗ ហ្វូ មកដល់ កន្លែងនោះ ហ្វូ មកនៅធ្វើមន្ទីរស្រុកនៅកន្លែងហ្នឹងគាត់ចាប់ ផ្តើមហៅជាបន្តបន្ទាប់មកហើយ។

**ស៖** តើលោកអាចប្រាប់បានទេថា នៅក្នុងឆ្នាំណាដែរ ហើយបើសិនជាលោកចាំ ថានៅក្នុងខែណាដែរ?

**ឆ៖** ខែខ្ញុំមិនចាំទេ ប៉ុន្តែឆ្នាំ១៩៧៨ ប្រហែលជាពាក់កណ្តាលឆ្នាំ ប្រហាក់ប្រហែល ខែ៥។

[០៩:៣១:៤៣]

**ស៖** ដូច្នេះ ខ្ញុំចង់សួរលោកថាតើភូមិ -- ថាតើឃុំទ្រាហ្នឹងស្ថិតនៅតាមដងទន្លេមេគង្គមែនទេ?

**ឆ៖** បាទ។

**ស៖** តើមន្ទីរស្រុកហ្នឹងនៅចម្ងាយប្រហែលប៉ុន្មានពីទន្លេ តើលោកអាចប្រាប់បានទេ?

**ឆ៖** នៅក្បែរមាត់ទន្លេតែម្ដង។ ផ្ទះមន្ទីរឃុំហ្នឹង ឆ្ងាយពីមាត់ទន្លេប្រហែលជា ២០-៣០ ម៉ែត្រ។

**ស៖** ដូច្នេះតើលោកដឹងទេ ថាមានអ្វីកើតឡើងចំពោះប្រជាជនដែលគេយកទៅមន្ទីរស្រុក?

**ឆ៖** ក្រោយមកឃើញរណ្ដៅសាកសពនៅក្បែរមន្ទីរស្រុកហ្នឹង ប្រហែលជាជាង ២០រណ្ដៅ ទាំងតូចទាំងធំ។

**ស៖** តើលោកអាចពន្យល់បានទេថា លោកឃើញរណ្ដៅហ្នឹង ឃើញជាដំបូងនៅពេលណាដែរ?

**ឆ៖** ខ្ញុំឃើញក្រោយថ្ងៃរំដោះ ០៧ មករា ហើយ ខ្ញុំកាលនោះ រៀបនឹងដាច់នោះ ខ្ញុំរត់ចូលព្រៃទៅខាងក្រោយឯណោះ។ ដល់ក្រោយមក ប្រហែលជាកន្លះខែ ខ្ញុំមកដល់ភូមិវិញ។ ពីកន្លះខែ ទៅ ២០ថ្ងៃ ខ្ញុំមកដល់ភូមិវិញ ហើយបានដើរទៅមើលក្បែរៗហ្នឹង ឃើញរណ្ដៅហ្នឹងហាក់បីដូចជាដីហ្នឹងផត ដោយសារឆ្នាំ១៩៧៨ហ្នឹង ទឹកឡើងលិចភូមិទាំងអស់ ហើយស្រកទៅវិញកន្លែងនោះ វារាងស្រុតៗ រណ្ដៅហ្នឹង។

[០៩:៣៣:៥០]

**ស៖** អ៊ីចឹងមានន័យថា លោកឃើញនៅក្នុងឆ្នាំ៧៩ ឬក៏ឃើញនៅពេលក្រោយមកទេ?

**ឆ៖** ឃើញនៅឆ្នាំ៧៩។

**ស៖** តើលោកដឹងទេថា មានអ្វីដែរនៅក្នុងរណ្ដៅទាំងអស់នោះ?

**ឆ៖** រណ្ដៅនោះ ឃើញឆ្អឹងសាកសពគរលើគ្នានៅក្នុងរណ្ដៅ។

**ស៖** នៅពេលដែលប្រជាជនដែលមកតាមរទេះគោហ្នឹង តើលោកដឹងទេថាពួកគាត់ជាជនជាតិអីដែរ?

**ឆ៖** ខ្ញុំដឹង ជនជាតិចាមទាំងអស់។

**ស៖** តើការដឹកមនុស្សតាមរទេះគោហ្នឹងគេដឹកតែមួយថ្ងៃទេ ឬមួយក៏ដឹកច្រើនថ្ងៃ?

**ឆ៖** តាមដឹង ប្រហាក់ប្រហែល១០ថ្ងៃ។

**ស៖** តើលោកអាចធ្វើការប៉ាន់ប្រមាណទៅមើល ថាតើមានចំនួនមនុស្សប្រហែលប៉ុន្មាននាក់ដែលគេដឹកតាមរទេះគោយកមកភូមិទ្រានោះ?

**ឆ៖** តាមខ្ញុំប៉ាន់ប្រមាណទៅ មនុស្សហ្នឹងប្រហែល៥-៦០០នាក់ ទាំងក្មេងទាំងចាស់ ទាំងអស់។

**សៈ** តើលោកដឹងទេថា ហូ គាត់មានទំនាក់ទំនង ឬក៏មានការទាក់ទងអ្វីដែរជាមួយប្រជាជនទាំងអស់នេះ?

**ឆៈ** ខ្ញុំមិនដឹងទេ។

**សៈ** សូមអរគុណ។ លោកសាក្សី លោកនិយាយថាមានម្តងនោះលោកបានរត់ចេញពីភូមិទ្រា ដូច្នេះ ខ្ញុំចង់សួរថា តើលោករត់គេចចេញពីភូមិទ្រានៅពេលណាដែរ?

**ឆៈ** កាលនុ៎ង ខ្ញុំមិនឆ្ងាយទេ ខ្ញុំគេចក្បែរៗហ្នឹង ហើយពេលដែលខ្ញុំនៅធ្វើស្មៀនឲ្យ ស៊ឹម ហើយឮថាភូមិភាគបូព៌ាហ្នឹងក្បត់ ហើយមានខាងកងទ័ពមជ្ឈិមមកបោសសម្អាត។ អ៊ីចឹង អង្គភាពទាំងអស់មានការភ័យខ្លាច ហើយរត់គេចទៅផ្ទះរៀងៗខ្លួន ហើយនៅ ជួនកាលនៅព្រៃក្បែរៗផ្ទះខ្លួនឯង។

[០៩:៣៧:៣៩]

**សៈ** ថាតើលោករត់ជាមួយអ្នកដទៃហ្នឹង តើអ្នកដែលរត់ជាមួយលោកហ្នឹង ជាជនជាតិខ្មែរ ជនជាតិចាម ឬក៏មានទាំងខ្មែរ មានទាំងចាម?

**ឆៈ** ការរត់នេះ មិនមែនជារត់នេះទេ គឺគ្រាន់តែគេចខ្លួនបណ្តោះអាសន្នតាមកាលនុ៎ងម្នាក់ឯង។

**សៈ** ដូច្នេះ ខ្ញុំចង់សួរថាតើលោករត់គេចជាមួយកម្មាភិបាលដទៃទៀត ឬមួយក៏យ៉ាងម៉េចដែរ ហើយបើសិនបើលោករត់គេចជាមួយកម្មាភិបាលដទៃទៀត តើកម្មាភិបាលដទៃទៀតនោះ ជាជនជាតិខ្មែរ ឬក៏ជនជាតិចាម?

**ឆៈ** ខ្ញុំរត់នុ៎ង រត់តែម្នាក់ឯងទេ ប៉ុន្តែកម្មាភិបាលដទៃក៏រត់ដូចខ្ញុំដែរ ប៉ុន្តែរត់ដោយខ្លួនៗ ទៅនៅផ្ទះក្បែរៗផ្ទះនុ៎ង ហើយកម្មាភិបាលដទៃទៀត សុទ្ធតែជាជនជាតិខ្មែរ មិនមែនជាជនជាតិចាមទេ តែម្នាក់ខ្ញុំទេជាជនជាតិចាម។

**សៈ** លោក ថាតើលោកជាសមាជិករបស់ក្រុមក្បត់ប៉ុល ពត ឬមួយលោកស្ថិតនៅក្នុងក្រុមដែលមានគម្រោងក្បត់ប៉ុល ពត ឬមួយក៏យ៉ាងម៉េចដែរ?

**ឆៈ** ខ្ញុំអត់មានមុខងារជាក្រុមស្នូល ឬក៏ជាសមាជិក ជាបក្ខជនរបស់គេទេ។ គ្រាន់តែគេហៅឲ្យទៅធ្វើការ ទៅធ្វើការតាម ក្នុងការធ្វើការហ្នឹង គឺខ្លាច មិនប៊ានជំទាស់។

**សៈ** តើមាននរណាម្នាក់ គាត់ធ្លាប់មកបញ្ចុះបញ្ចូល ឬក៏មកហៅលោកឲ្យចូលរួមផែនការក្បត់ប្រឆាំងនឹងប៉ុល ពត ទេ?

**ឆៈ** កាលនុ៎ងអត់មានទេ។

**ស៖** លោកអាចប៉ាន់ប្រមាណ ឬស្មានអំពីពេលវេលាដែលលោករត់ចេញពីភូមិទ្រាបានទេ?

**ឆ៖** ខ្ញុំប្រាប់ហើយថាខ្ញុំមិនរត់ឆ្ងាយទេ ខ្ញុំរត់នៅក្បែរៗផ្ទះហ្នឹង ជួនកាលនៅលើផ្ទះហ្នឹង ចេះតែពួនទៅ សភាពការណ៍កាលនុ៎ងវាច្របូកច្របល់។

**ស៖** បាទ គឺថាលោកបាននិយាយអំពីរឿងនេះហើយ។ តែខ្ញុំសួរអំពីពេលវេលាដែលលោករត់ចេញនៅក្បែរៗភូមិហ្នឹង មិនជាឆ្ងាយពីភូមិហ្នឹង តើវានៅក្នុងពេលណាដែរ?

**ឆ៖** ពេល ហ្វូ រៀបទៅដល់។ ដំបូងគេបង្អស់ហ្នឹង ចេះតែពួៗហ្នឹង នេះចេះតែភៀសខ្លួនបន្តិចៗ អត់ប៉ានៅមន្ទីរឃុំហ្នឹង បានចេះតែមកដល់ផ្ទះ មកផ្ទះខ្លួនឯង ទៅពួនក្នុងផ្ទះខ្លះទៅ នៅក្បែរៗផ្ទះខ្លះទៅ ពេល ហ្វូ មកដល់ ជិតមកដល់ហ្នឹង។

**ស៖** ខ្ញុំមានភាពច្របូកច្របល់បន្តិច ដោយសារថាលោកបានជួបប្រជុំជាមួយនឹង ហ្វូ។ អ៊ីចឹង សូមលោកបន្ស្រាយបន្តិចមក គឺចំពោះភាពច្របូកច្របល់នេះ?

[០៩:៤១:៣៣]

**ឆ៖** កាលនុ៎ង ខ្ញុំប្រាប់ហើយថា ដំបូងគេខ្ញុំរត់នុ៎ង ក្រោយមក ហ្វូ បានចាត់តាំង ម៉េង ជាមេឃុំហើយ ម៉េង នោះក៏ខ្ញុំហៅឲ្យធ្វើស្មៀនគាត់ទៀត ហើយក្រោយមកបីខែ បាន ហ្វូ គេប្រជុំម្ដង។ ពេលក្រោយនេះទេ ខ្ញុំបានរួមប្រជុំម្ដងហ្នឹង ដំបូងខ្ញុំមិនដែលស្គាល់អីទេ។

**ស៖** ខ្ញុំយល់ហើយ។ នៅចុងបញ្ចប់នៃឆ្នាំ១៩៧៨ លោករស់នៅទ្រាដដែល ឬក៏ចាកចេញពីទ្រា?

**ឆ៖** ខ្ញុំបានចាកចេញពីទ្រា នៅចុង១៩៧៨ រត់ចូលព្រៃតែម្ដង នុ៎ងរត់ៗទាំងអស់គ្នាតែម្ដង អ្នកភូមិហ្នឹងរត់ទាំងអស់ ដោយឮថាពួកខ្មែរក្រហមបានកៀរយកប្រជាជនទៅតាមខ្លួន។ អ៊ីចឹងភូមិខាងលើចេះតែឮមីក្រូ ឮអី ប្រកូកប្រកាសឲ្យចេញពីព្រៃឲ្យតាមទៅរត់តាមគេ។ អ៊ីចឹងអ្នកភូមិខ្ញុំនុ៎ងរត់ចូលព្រៃរត់ទាំងអស់គ្នា មិនរត់តែខ្ញុំទេ។ មានតែភូមិមួយរត់នៅជិតភូមិ គឺភូមិក្ដុលកណ្ដាល ជាភូមិខ្មែរ។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបជូនតុលាការបានទេ វាមានរយៈពេលប៉ុន្មានសប្ដាហ៍ប៉ុន្មានខែដែរ មុនពេលវៀតណាមចូលមកដល់?

**ឆ៖** ប្រហែលជាមួយខែ វៀតណាមចូលមកដល់។

**ស៖** ដូច្នេះគឺថាវាអាចនៅចុងឆ្នាំ១៩៧៨ ហើយ។ នៅពេលនោះ តើមានចាមប៉ុន្មាននាក់រស់នៅក្នុងឃុំទ្រាក្នុងចំណោមភូមិទាំងប្រាំហ្នឹង លោកអាចប៉ានប្រមាណបានទេ?

**ឆ៖** ខ្ញុំពិបាកប៉ានប្រមាណនៅពេល--

**ស៖** បាទមិនថ្វីទេ។ ឥឡូវនេះខ្ញុំផ្តោតការសួរទៅលើលោកអំពីអ្វីដែលកើតឡើងចំពោះជនជាតិចាម។ តើលោកធ្លាប់ដែលឮកម្មាភិបាលខ្មែរក្រហមណាម្នាក់និយាយអំពីផែនការអ្វីមួយពាក់ព័ន្ធទៅនឹងជនជាតិចាមដែរទេ?

**ឆ៖** ខ្ញុំធ្លាប់ឮម្តង កាលខ្ញុំធ្វើស្មៀនឲ្យ ឈាន នៅឆ្នាំ១៩៧៧។ មានសន្តិសុខតំបន់ គាត់មកសុំជួបមេឃុំ ឈាន ហ្នឹង ប៉ុនមេឃុំ ឈាន អត់នៅថ្ងៃនោះ គាត់ទៅស្រែ គាត់ទៅដឹកប្រឡាយជាមួយប្រជាជនហ្នឹង ហើយខ្ញុំនៅចាំមន្ទីរ ពេលថ្ងៃត្រង់ គាត់នៅអង្គុយលេងជាមួយខ្ញុំ។ គាត់សួរខ្ញុំថាផ្ទះទាំងអស់នេះគេទៅណាអស់។ ខ្ញុំថាផ្ទះទាំងអស់នេះជាផ្ទះបងប្អូនចាមហ្នឹង គេជម្លៀសទៅខាងភូមិភាគកណ្តាលអស់ហើយ។ រួចគាត់សួរថា ឥឡូវនៅទេ? គាត់ថា ខ្ញុំថានៅខ្លះប្រហែលគេជម្លៀសទៅប្រហែល៨០ភាគរយទៅ៨៥ភាគរយ គេទុក១៥ភាគរយទៅ២០ភាគរយនៅក្នុងភូមិហ្នឹង។ ហើយគាត់បានបញ្ជាក់ប្រាប់ខ្ញុំថាអនាគតចាមទាំងអស់ហ្នឹងគេកម្ទេចឲ្យទាំងអស់ហ្នឹង គេមិនឲ្យនៅសល់ទេ។

[០៩:៤៥:១៥]

**ស៖** សូមអរគុណ។ បុគ្គលដែលទទួលសន្តិសុខតាំងពីដើមមកនេះ លោកអាចជម្រាបទាំងឈ្មោះ ហើយតើគាត់មកពីខាងណាដែរ?

**ឆ៖** ខ្ញុំភ្លេចឈ្មោះគាត់ហើយ គាត់ឲ្យខទ្មេសនាមគាត់ ឃើញគាត់ហ្នឹងជាសន្តិសុខតំបន់ ប៉ុន្តែខ្ញុំអត់ចាំឈ្មោះទេ។

**ស៖** សូមអរគុណ។ តើគាត់មកតែម្នាក់ឯង ឬក៏មានកងការពារអីមកជាមួយគាត់ដែរ?

**ឆ៖** គាត់មកគ្នាពីរនាក់ អត់មានកងការពារទេ។

**ស៖** តើលោកគិតថា ឬក៏លោកដឹងថាគាត់ហ្នឹងដឹងថា លោកជាចាមដែរទេ?

**ឆ៖** ទេ គាត់អត់ដឹងទេ។

**ស៖** តើគាត់ធ្លាប់បានពន្យល់ ឬក៏លោកធ្លាប់បានឮ ដឹង ឬឮ ថាហេតុអ្វីបានជាមានផែនការកម្ទេចជនជាតិចាមចោល?

**ឆ៖** ខ្ញុំអត់ដែលឮ អត់ដឹងទាំងអស់។

**ស៖** លោកបានប្រាប់ទៅគាត់ថា ប្រជាជននៅ ៨០ ទៅ ៨៥ភាគរយនៅឃុំទ្រាត្រូវបានបញ្ចេញទៅភូមិភាគបស្ចិម។ តើមានមូលហេតុអីបានជាគេបញ្ជូនជនជាតិចាមចេញពីឃុំទ្រាទៅកាន់ភូមិភាគបស្ចិមនោះ?

**ឆ៖** ខ្ញុំមិនដឹងមូលហេតុទេ ប៉ុន្តែគេប្រជុំប្រាប់ថា នៅភូមិយើងមិនសូវសំបូរបាយហូប។ អ៊ីចឹង គេប្រាប់ថាឲ្យទៅច្រូតស្រូវនៅបាត់ដំបង វាមិនមែនប្រាប់ថានៅភូមិភាគកណ្ដាល ខេត្តកំពង់ធំហ្នឹងទេ។ គេថាទៅបាត់ដំបង ទៅច្រូតស្រូវ ស្រូវត្រង់ហ្នឹងទុំច្រើនណាស់ យើងទៅត្រង់នុំង ហូបបាយបានឆ្អែត។

**ស៖** ខ្ញុំចង់ដឹងអំពីពេលវេលា។ ពេលដែលលោកនិយាយថា ប្រជាជនចាមពី ៨០ ទៅ៨៥ភាគរយត្រូវបញ្ជូនទៅភូមិភាគកណ្ដាល។ តើការបញ្ជូនពី៨០ ទៅ ៨៥ភាគរយនេះ ទៅភូមិភាគកណ្ដាលនេះ ធ្វើឡើងនៅមុនឆ្នាំ១៩៧៥ ឬក្រោយឆ្នាំ១៩៧៥?

[០៩:៤៨:១៥]

**ឆ៖** នៅចុងឆ្នាំ១៩៧៥។

**ស៖** លោកសាក្សី លោកបាននិយាយថា មានហាក៊ីម បីនាក់នៅក្នុងឃុំទ្រា។ តើលោកដឹងថា មានរឿងរ៉ាវអ្វីកើតឡើងចំពោះហាក៊ីមទាំងបីនាក់នេះទេចាប់ពី៧៥ ដល់១៩៧៨?

**ឆ៖** ហាក៊ីមហ្នឹងគេចាប់តាំងពីដើមឆ្នាំ១៩៧៥ មកម្ល៉េះ។

**ស៖** តើលោកដឹងថា អ្នកទាំងបីនាក់ត្រូវបានគេចាប់ខ្លួន ឬក៏បាត់ខ្លួន?

**ឆ៖** មិនបាត់ទេ គេចាប់ទៅដាក់គុកនៅស្រុកក្រូចឆ្មារ នៅគេហៅស្ពានតាដួង។

**ស៖** ហើយតើពួកគាត់ហ្នឹងរស់រានមានជីវិតទេ ក្រោយពីរបបនោះមក?

**ឆ៖** បាត់ទាល់សព្វថ្ងៃ។

**ស៖** ខ្ញុំសូមសួរអំពីមនុស្សសំខាន់ៗមួយចំនួនទៀតនៅក្នុងឃុំទ្រា។ សូមជួយជម្រាបខ្ញុំផង។ ហាជី គឺអ្នកដែលធ្វើដំណើរទៅកាន់ទីក្រុងម៉េកា ហើយគឺថាជាមនុស្សសំខាន់នៅក្នុងសហគមន៍អ៊ីស្លាម។ តើមានអ្នកសាសនាប្រភេទនេះទេ មុនឆ្នាំ១៩៧៥?

**ឆ៖** មុនឆ្នាំ៧៥មាន។

**ស៖** លោកដឹងទេថាមានប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំមិនប្រាកដថាចំនួនប៉ុន្មានទេ ប្រហែលជាបួន-១០នាក់។

**ស៖** លោកដឹងថាហាជី ក្នុងចំណោម បួន-១០នាក់ហ្នឹង មានប៉ុន្មាននាក់រស់រានមានជីវិតពីរបបនោះមក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីវីុចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាការកត់សម្គាល់ ហើយក៏ជាការជំទាស់ជាផ្លូវការផងដែរ។ សហព្រះរាជអាជ្ញាកំពុងកម្រិតការតាំងសំណួរទៅលើអំឡុងពេលជិត៧៥ នៅក្នុងស្រុក និងនៅក្នុងតំបន់នេះ ក្នុងនោះមានការចាប់ខ្លួន និងការចាប់ខ្លួន និងការសម្លាប់មុនឆ្នាំ១៩៧៥ ដែលស្ថិតនៅខាងក្រៅយុត្តាធិការពេលវេលាហើយ។ ដូច្នេះដើម្បីធ្វើការញែកឲ្យដាច់ពីគ្នា បើមិនដូច្នេះទេ គឺថាធ្វើឲ្យសាក្សីនេះមានភាពច្របូកច្របល់ហើយ ព្រោះគាត់យល់ឃើញថាគាត់ត្រូវតែបង្ខំឲ្យឆ្លើយដូចអ្វីដែលកើតឡើងពី១៧ មេសា ១៩៧៥ ដូច្នេះដែរ។ នៅក្នុងឆ្នាំ៧០ មកឆ្នាំ៧២, ៧៣ មានព្រឹត្តិការណ៍កើតឡើងច្រើនណាស់ពាក់ព័ន្ធនឹងខ្មែរក្រហម។ ដូច្នេះ ខ្ញុំស្នើសុំឲ្យមានការកំណត់ពេលវេលាឲ្យបាន -- កម្រិតពេលវេលាឲ្យបានច្បាស់លាស់ក្នុងការតាំងសំណួរ តែត្រឹម១៧ មេសា ៧៥។

[០៩:៥២:៤០]

**លោក នីកូឡាស គូមជែន៖**

ជាការពិតណាស់ មេធាវីការពារក្ដីគឺអាចសួររយៈពេលពីឆ្នាំ៧០ ទៅ៧៥បាននៅពេលដល់វេនរបស់ពួកគាត់ត្រូវសួរ ពីព្រោះវាមានសារៈសំខាន់ណាស់។ ហេតុដូច្នេះឯងគឺថាសំណួរទាំងអស់នេះ ហេតុអ្វីគាត់ជឿជាក់ថាសាក្សីរូបនេះត្រូវបានកំពុងបង្ខំ បង្ខិតបង្ខំឲ្យឆ្លើយទៅនឹងសំណួររបស់ខ្ញុំនោះ។ លោកសាក្សីនេះ ឥឡូវនេះលោកកំពុងតែ -- លោកយល់ថា លោកឥឡូវនេះ ខ្ញុំកំពុងតែគំរាមកំហែងសម្លុតឲ្យលោកឆ្លើយ ឬក៏អត់ទេ?

**លោក សុះ រំលី៖**

លោកឆ្លើយថា -- អ៎! លោកសួរតាមសម្រួលទេ អត់បង្ខិតបង្ខំទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា គឺលោកវ៉ិចទ័រ កូប៉េ។ បញ្ហានេះគឺមានភាពពាក់ព័ន្ធដែលអង្គជំនុំជម្រះមានបំណងចង់ស្ដាប់ និងត្រូវការស្ដាប់បញ្ហានេះ ឲ្យបានច្បាស់លាស់ដែរ ដើម្បីមានមូលដ្ឋានក្នុងការយកមកត្រិះរិះពិចារណាពាក់ព័ន្ធជាមួយនឹងអង្គហេតុនេះ។ សាក្សីឆ្លើយតបនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ ប្រសិនបើលោកចងចាំ។

[០៩:៥៤:០៥]

**លោក សុះ រំលី៖**

ខ្ញុំអត់ចាំទេ សូមសំណួរម្តងទៀត។

**លោក នីកូឡាស គូមជែន៖**

**ស៖** លោកដឹងថាមានហាជី ប៉ុន្មាននាក់រស់រានមានជីវិតពីរបបខ្មែរក្រហម? បើលោកដឹងសូមលោកជួយប្រាប់តុលាការផង។

**លោក សុះ រំលី៖**

**ឆ៖** បាទ ខ្ញុំដឹងថានៅសល់តែម្នាក់គត់។

**ស៖** សូមអរគុណ។ ចុះគ្រូបង្រៀន តើគ្រូបង្រៀននៅឃុំទ្រា នៅមុនថ្ងៃ១៧ មេសា ១៩៧៥ មានៗគ្រូបង្រៀននៅឃុំទ្រាដែរទេ?

**ឆ៖** គ្រូបង្រៀនខាងចំណេះទូទៅ ខ្ញុំអត់សូវស្គាល់ទេ មិនដឹងគាត់មកពីភូមិណាៗ ខ្ញុំអត់ដឹងទេ។

**ស៖** សុំទោស ខ្ញុំគួរសួរឲ្យច្បាស់ជាងនេះ។ តើមានគ្រូបង្រៀនសាសនាអ៊ីស្លាមដែរឬទេ? គឺគ្រូដែលបង្រៀនឲ្យចេះអាន និងចេះប្រតិបត្តិតាមគម្ពីគួរ៉ាន់នោះ មានទេ?

**ឆ៖** បាទ មានបីនាក់។

**ស៖** តើអ្នកទាំងបីនេះរស់រានមានជីវិតពីរបបនោះមកដែរទេ?

**ឆ៖** ខ្មែរក្រហមចាប់យកទៅអស់ហើយ។

[០៩:៥៥:៥៨]

**ស៖** តើលោកធ្លាប់បានជួបពួកគាត់នេះឡើងវិញទេ?

**ឆ៖** អត់ដែលបានជួបទេ។

**ស៖** តើលោកអាចជម្រាបជូនតុលាការអំពីមនុស្សសំខាន់ៗមួយចំនួននៅក្នុងឃុំទ្រា? ដូចជាគ្រូបង្រៀន មេសាសនាជាដើម អ្នកដែលសំខាន់ៗនៅក្នុងឃុំទ្រាពីមុនឆ្នាំ១៩៧៥ មកត្រឹម១៩៧៥ សិន។

**ឆ៖** បាទ គ្រូបង្រៀនសាសនាបីនាក់ហ្នឹង មួយឈ្មោះ សុះ ស្លេម៉ាន គាត់ជានិស្សិតមកពីខាងប្រទេសអេហ្ស៊ីប។ គាត់ទៅរៀនខាងសាសនានៅប្រទេសអេហ្ស៊ីប។ ពីរឈ្មោះ សុះ យ៉ាស់កុះ។ គាត់រៀនខាង គាត់ទៅរៀនសាសនា គាត់ជានិស្សិតដែរមកពីម៉ាឡេ – ម៉ាឡេស៊ី ហើយគាត់នៅបង្រៀននៅភូមិទ្រាហ្នឹង ហើយទី៣ឈ្មោះ មិនដឹងត្រកូលគាត់ឈ្មោះអី គាត់ឈ្មោះ ព្រហ៊ីម – អ៊ីតព្រហ៊ីម ហ្នឹងគាត់ជាគ្រូ ហើយគាត់រៀននៅក្នុងភូមិ គាត់ចេះដឹងក្នុងភូមិ។

**សះ** តើលោកដឹងថាមានអ្វីកើតឡើងទៅដល់បញ្ញវន្តទាំងអស់នេះចន្លោះពីឆ្នាំ១៩៧៥ ដល់ ១៩៧៨?

**ឆះ** ទាំងបីនាក់នុ៎ងគេចាប់យកទៅ ខ្ញុំមិនដឹងដំណឹងគាត់ទេ ប៉ុន្តែគាត់បាត់ទាល់សព្វថ្ងៃ។

[០៩:៥៨:០៦]

**សះ** លោកអាចនឹកមើលអំពីពេលវេលា តើពួកគាត់នុ៎ងត្រូវបានគេចាប់ខ្លួនទៅនៅក្នុងពេលវេលាណាដែរ?

**ឆះ** កាលនុ៎ងប្រហាក់ប្រហែលជាចូល ទើបនឹងចូលឆ្នាំ១៩៧៥។

**សះ** លោកសាក្សី លោកបានឆ្លើយថា លោកមានបងប្អូនប្រាំនាក់។ តើបងប្អូនរបស់លោកទាំងប្រាំនាក់ហ្នឹងរស់រានមានជីវិតពីរបបនោះមកដែរទេ? ឬក៏អត់ទេ?

**ឆះ** បាទ បងប្អូនខ្ញុំប្រាំនាក់ ប៉ុន្តែស្លាប់តែម្នាក់ទេ។ ទាំងអស់នៅ នៅបួននាក់សព្វថ្ងៃ។

**សះ** ចុះបងប្អូនម្នាក់ដែលត្រូវបានគេសម្លាប់ហ្នឹង ជាបងប្អូនទីប៉ុន្មានដែរ?

**ឆះ** គាត់ជាបងទី១ នៅឆ្នាំ១៩៧៣ហ្នឹង គាត់បានទៅស្រុកវៀតណាម ប្រទេសវៀតណាមហ្នឹង ហើយគាត់ត្រឡប់មកវិញៗត្រូវខ្មែរក្រហមចាប់តាមផ្លូវនុ៎ង ហើយបាត់ឈ្មោះទាល់សព្វថ្ងៃ។

**សះ** លោកដឹងថាខ្មែរក្រហមចាប់គាត់ហ្នឹងនៅពេលណាដែរ?

**ឆះ** នៅឆ្នាំ៧៣ នុ៎ង បងខ្ញុំទៅនុ៎ង ទៅខេត្តមាត់ជ្រូកហ្នឹង ហើយគាត់ត្រឡប់មកវិញតាមផ្លូវតៃនិញនេះ ហើយមកតាមផ្លូវហ្នឹង បាត់ខ្លួនតាមផ្លូវតែម្តង។

**សះ** សូមអរគុណ។ ចុះបងប្អូនលោកបួននាក់ទៀត គាត់រស់នៅឃុំទ្រាវហូតមកដល់ឆ្នាំ១៩៧៨ ឬយ៉ាងណា?

**ឆះ** បាទ ពួកគាត់ទាំងអស់ នៅបន្ទុកខ្ញុំទាំងអស់។

**សះ** តើលោកមានធ្វើអ្វីមួយ ដើម្បីជួយការពារអាយុជីវិតរបស់ពួកគាត់ទេ?

**ឆះ** ខ្ញុំអត់មានលទ្ធភាពអីជួយពួកគាត់ទាំងអស់គ្នាទេ ពេលនោះ?

[១០:០១:០៣]

**សះ** នៅក្នុងឃុំទ្រា មុនខ្មែរក្រហមចូលកាន់កាប់អំណាច តើជនជាតិចាមទាំងអស់នោះមានអនុវត្តការប្រតិបត្តិសាសនាទាក់ទងទៅនឹងការបញ្ចុះសពអីនោះដែរទេ?

**ឆះ** សូមសំណួរម្តងទៀត បញ្ចុះសពយ៉ាងម៉េច ខ្ញុំអត់ទាន់យល់។

**ស៖** ខ្ញុំមិនមែនជាអ្នកជំនាញទេ ប៉ុន្តែខ្ញុំយល់ថា នៅក្រោមសាសនាអ៊ីស្លាម គឺគេត្រូវអនុវត្តថា គេត្រូវលាងសម្អាតខ្លួនប្រាណសាកសពឲ្យបានស្អាតតាមរបៀបរបស់គេមុននឹងកប់ខ្មោចនោះ។ អ៊ីចឹង មានអ្នកខ្លះ គេថា គេមានយកដៃហ្នឹងទៅចង្កុលក្បាល ឬក៏ថ្វាស់អីអ៊ីចឹង។ អ៊ីចឹងឯងបានជាខ្ញុំសួរថា តើការអនុវត្តប្រតិបត្តិទៅលើជំនឿលាងសាកសព មុននឹងកប់សាកសពនេះ គេមានអនុវត្តបែបនេះទេ មុនឆ្នាំ១៩៧៥?

**ឆ៖** បាទ នៅមុនឆ្នាំ១៩៧៥ មកដល់សព្វថ្ងៃហ្នឹង ពេលគេ គឺគេអនុវត្តអ៊ីចឹង។ សាកសពមុននឹងយកទៅកប់ គេត្រូវលាងសម្អាត ដុសសាប៊ូឲ្យស្អាតគ្រប់ទីកន្លែងទាំងអស់ គ្មានសល់កន្លែងណាមួយកន្លែងទេ។ ហើយមិនមែនទៅគេដៃទៅចង្កុលក្បាលទេ គេយកដាក់លើទ្រូងទាំងពីរ។

**ស៖** តើប្រជាជននៅទ្រា អនុញ្ញាតឲ្យប្រតិបត្តិសាសនារបៀបនេះដដែលទេ ក្នុងរបបខ្មែរក្រហម គឺការប្រតិបត្តិសាសនាពាក់ព័ន្ធទៅនឹងការលាងខ្លួនប្រាណសាកសព និងការបញ្ចុះសាកសពនេះ?

**ឆ៖** រឿងសាកសពដែលស្លាប់ទៅ រឿងស្លាប់ក្នុងការឈឺថ្កាត់ អាចលួចលាក់បាននៅលើផ្ទះ ព្រោះពេលស្លាប់ហ្នឹង ខ្មែរក្រហមមិនសូវរវីរវល់ទេ។

**ស៖** បាទ សូមអរគុណ។ ចុះភាសាចាមវិញម្តង នៅមុនឆ្នាំ១៩៧០ តើនៅក្នុងភូមិរបស់លោក គេប្រើប្រាស់ភាសាចាម ក្នុងកម្រិតទូលំទូលាយដែរទេ មុនឆ្នាំ១៩៧០?

**ឆ៖** បាទ មុន៧០ គេប្រើទូលំទូលាយ ក្នុងសហគមន៍ជនជាតិចាមទាំងអស់នោះ។

[១០:០៤:៣៧]

**ស៖** ហើយជាពិសេស ក្រោយខែមេសា ១៩៧៥ ដល់ ១៩៧៨ តើគេអនុញ្ញាតឲ្យជនជាតិចាមហ្នឹងនិយាយភាសាចាមដែរទេ នៅភូមិទ្រានោះ?

**ឆ៖** គេមិនអនុញ្ញាតឲ្យនិយាយភាសាចាមទេ ក៏ប៉ុន្តែគេមិនសូវជាធ្ងន់ធ្ងរ ដូចជានៅក្នុងផ្ទះ គ្នាអីហ្នឹងលួចនិយាយគ្នាបាន។

**ស៖** លោកសាក្សី លោកនិយាយអំពីកម្មាភិបាលមកពីភូមិភាគកណ្តាលទៅដល់ឃុំទ្រា។ តើមានកម្មាភិបាលមកពីភូមិភាគដទៃទៀតចូលមកកាន់ឃុំទ្រានេះដែរទេ?

**ឆ៖** ខ្ញុំឃើញមានចម្លែកពីរនាក់។ គាត់និយាយរដីន១ពីរនាក់នុំង ហើយក្រៅពីហ្នឹងដូចនៅ មកពីភូមិភាគកណ្តាល។

**ស៖** តើមានកម្មាភិបាលមកពីភូមិភាគដទៃទៀតដែរទេ ក្រៅពីភូមិភាគកណ្តាល?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ ប៉ុនប្រហែលគ្មានទេមើលទៅ។

**ស៖** តើលោកដែលដឹងថា គេមានបញ្ជូនកម្មាភិបាលមកពីភូមិភាគនិរតីទៅកាន់ភូមិទ្រាដែរទេ?

**ឆ៖** ឃើញមានពីរនាក់ ស្រីម្នាក់ ប្រុសម្នាក់។

**ស៖** លោកស្គាល់ឈ្មោះអ្នកទាំងពីរនេះទេ?

**ឆ៖** ខ្ញុំស្គាល់បានម្នាក់ប្រុសនុ៎ង គាត់ឈ្មោះ ទ្រឹម។ គាត់នុំង ក្រោយពី ម៉េង ក្រោយពី ញឹប មក ទ្រឹម ហ្នឹងជាមេឃុំ។

**ស៖** សូមលោកជួយជម្រាបមើល តើតួនាទី គាត់មានតួនាទីជាអ្វីដែរ?

**ឆ៖** គាត់ជាមេឃុំ។ ទ្រឹម ហ្នឹងជាមេឃុំ ក៏ប៉ុន្តែមិនសូវនៅឃុំទេ គាត់នៅតាខាងៗលើ មិនដឹង នៅត្រង់ណាទេ គាត់ យូរៗគាត់មកម្តង ប៉ុនគាត់អះអាងថា គាត់មេឃុំ។

[១០:០៨:០០]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ប្រហែលជាដល់ពេលសមរម្យនឹងឈប់សម្រាកហើយ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសមស្របល្មមឈប់សម្រាកហើយ ហើយជម្រាបថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺមានពេលវេលាតែប្រហែលជា២០នាទីប៉ុណ្ណោះទៀតប៉ុណ្ណោះ ក្នុងការតាំងសំណួរដេញដោលសាក្សីរូបនេះ។

បាទ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៩ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៣:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អម្បាញ់មិញនេះ ដោយសារមានបញ្ហាដែលត្រូវស្តាប់សារណារបស់ភាគីលើបញ្ហាមួយចំនួន ចំពោះមុខបន្ទាន់ដែលអង្គជំនុំជម្រះត្រូវស្តាប់ និងយកទៅពិចារណាសម្រេចលើសំណើសុំមួយចំនួន ហេតុដូច្នេះហើយបានជាអង្គជំនុំជម្រះឲ្យផ្អាកក្នុងការអញ្ជើញ សាក្សី និងមេធាវីប្រឹក្សាសាក្សី ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការអម្បាញ់មិញនេះ។

នៅជាបន្តទៅនេះ អង្គជំនុំជម្រះសូមធ្វើការសវនាការស្តាប់នូវសារណាផ្ទាល់មាត់លើបញ្ហាមួយចំនួន។ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦ ការិយាល័យសហព្រះរាជអាជ្ញាបានជូនដំណឹងមកអង្គជំនុំជម្រះ និងភាគីថា សហព្រះរាជអាជ្ញាអន្តរជាតិកំពុងរៀបចំដាក់បង្ហាញឯកសារថ្មីៗពីសំណុំរឿង ០០៣ និង ០០៤ និងថាឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនេះ ជាប់ពាក់ព័ន្ធនឹងសាក្សី ដែលមានរហស្សនាម 2-TCW-938 ដែលត្រូវបានកំណត់ពេលឲ្យមកផ្តល់សក្ខីកម្មនៅ អ.វ.ត.ក នៅថ្ងៃចន្ទទី១១ ខែមករា ឆ្នាំ ២០១៦។

ក្នុងចំណោមចំណុចផ្សេងៗទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំថា ការស្តាប់សក្ខីកម្មសាក្សីរូបនេះ គួរត្រូវពន្យារពេលរហូតដល់ចុងបញ្ចប់នៃសវនាការលើអង្គហេតុ ស្តីពីការប្រព្រឹត្តលើក្រុមគោលដៅជាក់លាក់ចំពោះជនជាតិចាម មុនពេលស្តាប់សក្ខីកម្មអ្នកជំនាញ ដែលមានរហស្សនាម 2-TCE-95។ ហើយមុនពេលដំណើរការស្តាប់នូវសារណាតបពីភាគីនានា ទៅនឹងសារអេឡិចត្រូនិច របស់សហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះសូមឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ បំភ្លឺថា តើឯកសារទាំងនេះ មានជាប់ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម 2-TCW-988, 2-TCW-987 និង 2-TCW-894 ដែរឬទេ?

ម្យ៉ាងទៀតអង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីថា នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានទទួលដំណឹងថា សហព្រះរាជអាជ្ញា -- សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា សាក្សីដែលមានរហស្សនាម 2-TCW-938 និងសាក្សីដែលមានរហស្សនាម 2-TCW-894 ឋិតនៅក្នុងចំណាត់ថ្នាក់ប្រភេទ(គ) អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឯកសារ E319/25

កថាខណ្ឌ៣ ចំណុច(គ)។ អនុលោមតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដូចដែលបានកំណត់នៅក្នុងអនុស្សរណ: E319/25 ខាងលើនេះ អង្គជំនុំជម្រះកំពុងរង់ចាំការបញ្ជាក់នូវលក្ខខណ្ឌអនុវត្តមួយចំនួនពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលនឹងស្នើដល់អង្គជំនុំជម្រះឲ្យអនុវត្តនូវលក្ខខណ្ឌទាំងនោះ។

ហើយជាបឋមនេះ សូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីធ្វើការបញ្ជាក់បំភ្លឺទៅលើបញ្ហាដូចដែលបានលើកឡើងនេះ ពាក់ព័ន្ធនឹងការដាក់បង្ហាញ ឯកសាររបស់ខ្លួន។

សូមអញ្ជើញ!

[១០:៣៧:៣០]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនប្រាកដថាខ្ញុំអាចឆ្លើយនឹងសំណួរទាំងអស់នេះនៅពេលនេះបានទេ ប៉ុន្តែខ្ញុំប្រហែលជាអាចឲ្យមន្ត្រីខ្ញុំនឹងឆ្លើយនៅយ៉ាងយូរបំផុតត្រឹមចុង១បញ្ចប់នៅថ្ងៃនេះ។ ប៉ុន្តែដូចដែលបានបញ្ជាក់នៅក្នុងអ៊ីម៉ែលអ៊ីចឹង គឺយើងបានបញ្ជាក់ដូច្នេះ។ នេះគឺជាបញ្ហាដែលបានចេញមកពីខាងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយជាការដាក់បង្ហាញនូវឯកសារយ៉ាងច្រើន។ ហើយខ្ញុំមិនដឹងចំនួនច្បាស់ទេ ប៉ុន្តែខ្ញុំគិតថាឯកសារទាំងអស់នេះ គឺវាមានចំនួនច្រើនដែលអាចតម្រូវឲ្យយើងត្រូវការពេលវេលាដល់រាប់សប្តាហ៍ក្នុងការសម្រេច ថាតើឯកសារទាំងអស់នេះស្ថិតនៅក្នុងប្រភេទដែលត្រូវដាក់បង្ហាញឬក៏យ៉ាងណា?

អ្វីដែលយើងដឹងនៅពេលនេះ គឺថា១កាលពីប៉ុន្មានថ្ងៃមុន ឯកសារមួយចំនួន គឺពាក់ព័ន្ធទៅនឹង 2-TCW-938 ដែលសាក្សីនេះគឺមានការនិយាយយោងមួយចំនួននៅក្នុងចម្លើយរបស់សាក្សីដទៃទៀត។ ដើម្បីជាប្រយោជន៍ក្នុងការដាក់បង្ហាញឯកសារឲ្យបានច្រើន ដូច្នេះខ្ញុំគិតថា ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តរបស់ជនជាតិចាម ខ្ញុំគិតថាប្រហែលជាមានប្រាំពីរឯកសារ ដែលត្រូវបានដាក់បង្ហាញតាមរយៈតាមអ៊ីម៉ែលកាលពីម្សិលមិញ។ ដូច្នេះ ខ្ញុំត្រូវតែពិនិត្យមើលឡើងវិញ ហើយខ្ញុំសង្ឃឹមថា ខ្ញុំនឹងអាចឆ្លើយនៅក្នុងថ្ងៃនេះបាន ថាតើមានឯកសារប៉ុន្មានដែលពាក់ព័ន្ធទៅនឹងសាក្សីដែលខ្ញុំទើបតែលើកបាន -- ទើបតែលើនិយាយឡើងនេះ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំត្រូវការពេលវេលាដើម្បីពិនិត្យ ហើយខ្ញុំសូមបញ្ជាក់ថាខ្ញុំមិនអាចឆ្លើយ ឲ្យបានច្បាស់លាស់នៅពេលនេះ បាននោះឡើយ។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកដឹងថា តើលោកត្រូវការពេលវេលាប៉ុន្មានសប្តាហ៍ដែរទេ? តើព្រះរាជអាជ្ញាត្រូវការពេលប៉ុន្មានសប្តាហ៍ដើម្បីពិនិត្យឯកសារនោះ?

[១០:៣៩:៥១]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា នៅយ៉ាងយូរបំផុតក្នុងថ្ងៃនេះ ខ្ញុំនឹងឆ្លើយជូនលោកស្រីចៅក្រម ប៉ុន្តែខ្ញុំមិនប្រាកដថា នៅពេលនេះ ខ្ញុំត្រូវការពេលវេលាប៉ុន្មានទេ ព្រោះយើងមានឯកសារជាច្រើនដែលត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញ គឺថា ឯកសារហ្នឹងមកដល់ការិយាល័យរបស់យើងនៅពេលដែលបុគ្គលិកចាកចេញពីកន្លែងធ្វើការរួចទៅហើយ។ ដូច្នេះហើយអ្វីដែលយើងបានទទួលគឺទទួលបានកាលពីថ្ងៃចន្ទ។ ដូច្នេះខ្ញុំគិតថា ខ្ញុំត្រូវការពេលវេលាបន្ថែមទៀតដើម្បីពិនិត្យទៅលើឯកសារទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ វាបញ្ហាប្រឈមចំពោះមុខរបស់អង្គជំនុំជម្រះនោះគឺថា សប្តាហ៍ក្រោយអង្គជំនុំជម្រះកំណត់ស្តាប់សក្ខីកម្មសាក្សីរូបនេះហើយ។ ឥឡូវនេះ សហព្រះរាជអាជ្ញាបានលើកឯកសារពាក់ព័ន្ធនឹងសាក្សីដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនៅថ្ងៃចន្ទ គឺជាបន្ទាន់ភ្លាមៗ។ បញ្ហាដែលអង្គជំនុំជម្រះពិភាក្សានេះ គឺចង់ឱ្យមានបញ្ហាការបញ្ជាក់ក្រៅពីពាក់ព័ន្ធនឹងសាក្សីដែលត្រូវកំណត់ធ្វើសវនាការនៅថ្ងៃចន្ទសប្តាហ៍ក្រោយនេះ សួរថា តើបណ្តាឯកសារទាំងនោះ ដែលគ្រោងដាក់ហ្នឹងមានការពាក់ព័ន្ធជាមួយនឹងសាក្សីចំនួនបួនរូបដទៃផ្សេងទៀតដែលអង្គជំនុំជម្រះបានកំណត់រួចហើយគឺ 2-TCW-988, 2-TCW-987 និងសាក្សី 2-TCW-894 ដែរឬយ៉ាងណា? នេះចង់បញ្ជាក់នេះដោយសារមូលហេតុអង្គជំនុំជម្រះចង់សម្របសម្រួលជាមួយនឹងភាគីពាក់ព័ន្ធ ហើយជាពិសេសជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញប្រសិនបើមិនមានបញ្ហាអីប្រឈមខ្លាំងទេ អង្គជំនុំជម្រះនឹងជម្នះបញ្ហាមានការផ្លាស់ប្តូរនៃកាលវិភាគសម្រាប់សវនាការនៅសប្តាហ៍ក្រោយដើម្បីប្រឹងប្រែងធ្វើយ៉ាងណាកុំឱ្យពេលវេលាដែលកន្លងទៅវាអត់ប្រយោជន៍ គឺឱ្យមានដំណើរការប្រក្រតីភាពនៃការប្រព្រឹត្តទៅសវនាការចំពោះការរៀបចំសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង។ នេះបញ្ជាក់ឱ្យបានច្បាស់លាស់។ អម្បាញ់មិញនេះ គឺលោក

ឆ្លើយទៅលើបញ្ហាពាក់ព័ន្ធទៅនឹងឯកសារ ពាក់ព័ន្ធនឹងសាក្សីតែរឿង 338 ទេ ប៉ុន្តែសំណួរដែលពាក់ព័ន្ធនឹងសាក្សីដទៃទៀត ដែលអង្គជំនុំជម្រះចង់ដឹង ហើយនិងចង់ស្ដាប់ភាគីពាក់ព័ន្ធដទៃទៀតថាតើលទ្ធភាពនៃការរៀបចំកាលវិភាគសវនាការនៅសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះអាចរៀបចំបានអត់ ទី១។ ទី២ អង្គជំនុំជម្រះមិនអាចបង្អែបង្អង់បញ្ហានេះបាន ដោយសារមូលហេតុអង្គភាពគាំពារសាក្សីនិងអ្នកជំនាញគេត្រូវការសម្របសម្រួលដើម្បីផ្លាស់ប្ដូរនេះ ទៅយក ទៅសម្របសម្រួលបណ្ដាសាក្សីដែលមានការប្រែប្រួលនេះ ដើម្បីទទួលនាំយកមកផ្ដល់សក្ខីកម្មតាមកាលវិភាគដែលអង្គជំនុំជម្រះកំណត់ និងកំណត់ធ្វើនៅសប្ដាហ៍ក្រោយ។

[១០:៤២:៥១]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ដើម្បីបញ្ជាក់ឲ្យបានច្បាស់គឺថា ខ្ញុំមានចំណុចមួយ ព្រោះថាវាមានឯកសារដែលបានដាក់បង្ហាញ គឺថាមិនមែនព្រះរាជអាជ្ញាចង់ប្រើប្រាស់ឯកសារទាំងអស់នេះជាមួយនឹងសាក្សី 938 នោះទេ ប៉ុន្តែការពិតយើងដាក់បង្ហាញព្រោះថា ប្រហែលជាអាចថាមេធាវីការពារក្ដីគាត់ចង់ប្រើប្រាស់ឯកសារទាំងអស់នេះ។ ដូច្នេះគឺថា យើងមិនមានចេតនានឹងយោងទៅលើកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីណាមួយនោះឡើយ។ ហើយខាងព្រះរាជអាជ្ញាមិនចង់ប្រើប្រាស់ឯកសារទាំងអស់នោះឡើយ។ ដូច្នេះប្រសិនបើសួរថា វាមានភាពពាក់ព័ន្ធទៅនឹងសាក្សីដទៃទៀត ដូចជាសាក្សី 938, 894 ជាដើមនេះ គឺថាខ្ញុំមិនទាន់មានឯកសារហ្នឹងនៅចំពោះមុខនោះឡើយ។ ប៉ុន្តែខ្ញុំអាចពិនិត្យមើលឡើងវិញ ហើយខ្ញុំចង់បញ្ជាក់ថា យើងមិនមានចេតនានឹងប្រើប្រាស់ទេ ប៉ុន្តែយ៉ាងយូរបំផុតត្រឹមរសៀលនេះ ឬក៏ក្នុងថ្ងៃនេះ ខ្ញុំនឹងបញ្ជាក់ឲ្យបានច្បាស់អំពីចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

មានការអីទេ? សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់។ ខ្ញុំមានសំណួរមួយសុំឲ្យបំភ្លឺ ចំពោះខ្ញុំ ខ្ញុំទទួលបានអ៊ីម៉ែលរបស់សំណើសហព្រះរាជអាជ្ញាដែលមានភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធដែលបញ្ជាក់អំពីកំណត់ហេតុប្រាំដែលនឹងអាចត្រូវពាក់ព័ន្ធនឹងសាក្សី 2-TCW-938 ហើយខុសពីសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះ គឺថានៅក្នុងឧបសម្ព័ន្ធនេះ មានជាតារាង ហើយក្នុងតារាងនោះ បញ្ជាក់អំពី

ផលប្រយោជន៍នៃកំណត់ហេតុទាំងអស់នោះ។ ឯកសារបួនក្នុងចំណោមឯកសារប្រាំហ្នឹង ជាភាសាអង់គ្លេស ខ្ញុំសូមអានជាភាសាអង់គ្លេស។

(អានភាសាអង់គ្លេស)៖ ឯកសារដោះបន្ទុករួមមានទាំងការសម្រេចទៅលើសំណើ៨៧។

សំណួរនេះ គឺខ្ញុំចង់សួរទៅសហព្រះរាជអាជ្ញាអន្តរជាតិផ្ទាល់តែម្តង ពីព្រោះថានៅក្នុងឯកសារនោះ គាត់ដាក់ថាប្រហែលជាអាចមានសំណើយោងតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ អ៊ីចឹង តើសំណើហ្នឹង សំណើចេញមកពីសហព្រះរាជអាជ្ញា ឬក៏យ៉ាងម៉េច? ខ្ញុំដូចជាវង្វេង។ យើងចង់ទទួលបានព័ត៌មានឲ្យបានច្បាស់ពាក់ព័ន្ធទៅនឹងការដោះបន្ទុក។ ព្រោះថាឥឡូវនេះ ខ្ញុំមិនទាន់ដឹងថា ដោះ ឬក៏ដាក់ទេ ពីព្រោះខ្ញុំមិនទាន់បានមើលឯកសារទាំងអស់ហ្នឹងទេ។ ខ្ញុំត្រូវមានពេលវេលាដើម្បីពិនិត្យមើលឯកសារហ្នឹងសិន។ ក៏ប៉ុន្តែឧបសម្ព័ន្ធសហព្រះរាជអាជ្ញានោះ បង្ហាញឲ្យឃើញថា អាចនឹងមានវិធានយោងតាមវិធាន៨៧(៤) ពីសំណាក់ការិយាល័យសហព្រះរាជអាជ្ញា។ ហើយវាមិនដូចជាអ្វីដែលគាត់បានលើកឡើងអម្បាញ់មិញនេះទេ។ នេះជាការសុំឲ្យគាត់បំភ្លឺទី១។ ការសុំឲ្យបំភ្លឺទី២ គឺនៅក្នុងកថាខណ្ឌ៣ នៃអ៊ីម៉ែលនោះ ដែលមិនទាន់មានលេខ ERN ឬក៏លេខយោងឯកសារអ្វីនៅឡើយទេ។ ហើយគឺមានចំណងជើងថា “សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធទៅនឹងការដាក់ផ្សាយសំណុំរឿង០០៣ ០០៤ ទៅក្នុងសំណុំរឿង០០២”។ គឺឯកសារហ្នឹងគឺចុះថ្ងៃនេះតែម្តង។គឺនៅកថាខណ្ឌទី៣ នៃអ៊ីម៉ែលដែលបានផ្ញើជូនមានការសរសេរជាភាសាអង់គ្លេសដូចតទៅ ខ្ញុំសូមអភ័ទោសផង ដែលខ្ញុំត្រូវអានជាភាសាអង់គ្លេស។ គឺនៅចុងកថាខណ្ឌជាភាសាអង់គ្លេស។

[១០:៤៧:១៣]

(អានភាសាអង់គ្លេស៖) ដោយសារតែភាគីទើបតែបានទទួលការជូនដំណឹងអំពីការកំណត់កាលបរិច្ឆេទសម្រាប់សាក្សីថ្មីៗនេះ ហើយវាពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម ហើយដោយសារតែព្រះរាជអាជ្ញាមានឱកាសច្រើនក្នុងការពិនិត្យទៅលើឯកសារជាច្រើន ដែលត្រូវបានដាក់បង្ហាញនៅក្នុងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃ១៨ ធ្នូ នោះ គឺព្រះរាជអាជ្ញាសូមធ្វើការដាក់បង្ហាញទៅលើឯកសារទាំងអស់នេះ នៅក្នុងឯកសារដែលមានភ្ជាប់ជាមួយ។” (បញ្ចប់ការអានភាសាអង់គ្លេស)

[១០:៤៧:៥៨]

តាមរយៈកថាខណ្ឌនេះ ខ្ញុំចង់សួរដូចតទៅ គឺខ្ញុំយល់ថា នៅពេលដែលសហព្រះរាជអាជ្ញាធ្វើសំណើដើម្បីដាក់បង្ហាញឯកសារជូនទៅភាគីទាំងអស់ដែលចេញមកពីការស៊ើបអង្កេតនោះ ពីព្រោះថា

គាត់ដឹងអំពីខ្លឹមសារនៃឯកសារហ្នឹងរួចអស់ទៅហើយ ទើបបានជាគាត់ស្នើសុំ ដើម្បីដាក់បង្ហាញទៅភាគីផ្សេងទៀត។ ក៏ប៉ុន្តែបើយោងតាមការអានទូវសំណើរបស់សហព្រះរាជអាជ្ញាជាអ៊ីម៉ែលនោះ គឺមើលទៅដូចជាសហព្រះរាជអាជ្ញាមិនទាន់ដឹងអំពីខ្លឹមសារនៅក្នុងឯកសារទាំងអស់ហ្នឹងនៅឡើយទេ។ អ៊ីចឹងបានជាខ្ញុំសូមស្នើឲ្យមានការបំភ្លឺពីសំណាក់សហព្រះរាជអាជ្ញា។

ជាទូទៅ គឺសហព្រះរាជអាជ្ញាគួរតែដឹង ថាខ្លឹមសារនុំងយ៉ាងម៉េចទៅហើយ។ ហើយអ៊ីចឹងម៉េចក៏សុំពេលវេលាដើម្បីពិនិត្យឯកសារថែមទៀត ខ្ញុំមិនយល់សោះ ខ្លួនឯងជាស្នើសុំដាក់ឯកសារ តែមិនទាន់បានដឹងឯកសារផង។ នេះជាបញ្ហាដែលចោទឡើង ពាក់ព័ន្ធទៅការដាក់បង្ហាញឯកសារនេះ។

ហើយការកត់សម្គាល់ទីពាររបស់ខ្ញុំ គឺខ្ញុំសូមបញ្ជាក់ថា ប្រសិនបើសហព្រះរាជអាជ្ញាមិនទាន់ដឹងខ្លឹមសារ ហើយត្រូវការពេលវេលានោះ យើងជាមេធាវីការពារក្ដីដែលមិនទាន់បានមើលឯកសារនោះផងយើងក៏ត្រូវការពេលវេលាដែរ។ ហើយខាង -- អ៊ីចឹង បើលោកស្នើសុំពេល យើងក៏យើងត្រូវការពេលដើម្បីអាចឲ្យយើងគ្រប់គ្រងពេលវេលារបស់យើងពាក់ព័ន្ធទៅនឹងការពិនិត្យមើលឯកសារទាំងអស់នេះផងដែរ។ ខ្ញុំសូមបញ្ជាក់ហើយ ថាខ្ញុំមិនទាន់មានពេលវេលាដើម្បីពិនិត្យមើលឯកសារដែលបានផ្ញើជូនតាមអ៊ីម៉ែលមកឲ្យយើងខ្ញុំទេ ហើយខ្ញុំទើបតែទទួលបានកាលពីព្រឹកមិញនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[១០:៥០:០២]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា ខ្ញុំអាចផ្តល់ព័ត៌មានបន្ថែមបន្តិច ហើយនិងឆ្លើយតបទៅនឹងសំណួរទាំងនេះ។ ថាតើឯក-សារទាំងអស់នេះ មានភាពពាក់ព័ន្ធទៅនឹងសាក្សីដទៃទៀត ឬក៏អត់នោះ។ តាមការពិនិត្យរបស់យើង គឺថាវាអាចពាក់ព័ន្ធទៅនឹងសាក្សី 894 ប៉ុន្តែមិនពាក់ព័ន្ធចំពោះ938 និង 987 នោះឡើយ -- 988 នោះឡើយ។ ដូច្នេះខ្ញុំគិតថា ខ្ញុំអាចពន្យល់ទៅលើអ្វីដែលមេធាវីការពារក្តីបានលើកឡើង។ ឯកសារទាំងអស់ដែលយើងបាននិយាយនៅក្នុងការដាក់បង្ហាញនោះ គឺវាគឺថាយើងនឹងធ្វើសារណាមួយពាក់ព័ន្ធនឹងវិធាន ៨៧(៤) ទាក់ទងទៅនឹងការទទួលយក ប៉ុន្តែយើងមិនប្រើ -- យើងមិនមានបំណងប្រើប្រាស់ឯកសារទាំងអស់នេះជាមួយសាក្សី 938 នោះឡើយ។ យើងមិនមានចេតនានឹងប្រើប្រាស់ជាមួយសាក្សីនោះទេ ប៉ុន្តែយើងគិតថាវាជាការចាំបាច់ដែលយើងត្រូវដាក់បង្ហាញ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថានៅពេល

បន្តិចទៀតនេះ នៅពេលឆាប់ៗនេះ ខ្ញុំនឹងអាចឆ្លើយបានថាតើយើងនឹងទៅការពារប៉ុន្មានដើម្បីពិនិត្យមើលឯកសារនេះ។ ហើយម្យ៉ាងទៀតខាងសហចៅក្រមស៊ើបអង្កេតបានដាក់នូវលក្ខខណ្ឌយ៉ាងច្រើន ដើម្បីឲ្យយើងទាក់ទងទៅនឹងឯកសារទាំងអស់នេះ។

[១០:៥១:៣៩]

ដោយសារតែខ្ញុំមិនចាំច្បាស់អំពីកាលបរិច្ឆេទ គឺថាអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយដែលថា ជាការចាំបាច់ឲ្យពួកយើងក្នុងការដាក់បង្ហាញ ទី១ ទៅតាមការស្នើឲ្យមេធាវី ខៀវ សំផន បានពិនិត្យមើលឯកសារ ព្រោះថាឯកសារទាំងអស់នោះអាចជាឯកសារដោះបន្ទុក ហើយបន្ទាប់មកទៀតអង្គជំនុំជម្រះបានកំណត់ថាតើយើងត្រូវកំណត់ពាក្យទុំងដោយរបៀបណា ហើយយើងត្រូវគ្រប់ដោយរបៀបណា ហើយវាមានឯកសារមួយចំនួនទៀតដែលយើងចង់ប្រើប្រាស់ ក៏យើងត្រូវដាក់តាមរយៈសារណាតាមវិធាន៨៧(៤)។ ដូច្នេះនេះគឺជាអ្វីដែលជាការទាមទារ ហើយយើងក៏ធ្វើការស្នើជាមួយនឹងចៅក្រមស៊ើបអង្កេត ហើយចៅក្រមស៊ើបអង្កេតគាត់បានដាក់នូវឯកសារមួយចំនួន ដែលគិតថាជាមានលក្ខណៈជាភស្តុតាងដោះបន្ទុក។ ដោយសារតែអង្គជំនុំជម្រះបានចេញសេចក្ដីបែបនេះហើយ ទើបយើងធ្វើការដាក់បង្ហាញនូវឯកសារមួយចំនួន ហើយយ៉ាងណាក្ដី យើងស្ថិតក្នុងដំណើរការកំពុងតែពិនិត្យមើលនៅឡើយ ហើយក្នុងពេលឥឡូវនេះខ្ញុំមិនទាន់មានចម្លើយថាតើយើងត្រូវការពេលវេលាប៉ុន្មាននោះឡើយ។ ប៉ុន្តែខ្ញុំគិតថា នៅពេលរសៀលនេះ គឺនៅវគ្គទី១ នៅពេលរសៀលនេះ ខ្ញុំនឹងអាចចម្លើយជូនអង្គជំនុំជម្រះក៏ដូចជាភាគីបាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្ត អង្គជំនុំជម្រះផ្ដល់វេទិកាជូនក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយដោយសារភាពមិនទាន់ច្បាស់លាស់នៃបញ្ហាទី១ ជាបញ្ហាចម្បង ប៉ុន្តែអង្គជំនុំជម្រះក៏ចង់ដឹងដែរថាតើប្រសិនបើអង្គជំនុំជម្រះរៀបចំនូវកាលវិភាគសវនាការនៅក្នុងសប្ដាហ៍ក្រោយនេះ រំកិលនូវសាក្សីដែលមានរហស្សនាម 2-TCW-988 និង 2-TCW-987 មកធ្វើសវនាការនៅដើមសប្ដាហ៍ក្រោយ។ តើវាមានបញ្ហាអីដែរឬទេ? បញ្ហាទី១ គួរតែត្រូវបានផ្អាកទុកសិន ព្រោះមិនទាន់មានការបង្ហាញច្បាស់លាស់ពីអ្នកដែល សហព្រះរាជអាជ្ញាអន្តរជាតិ ដែលអត់ដាក់សំណើនៅឡើយទេ។ អាហ្នឹងយើងនឹងធ្វើនីតិវិធីនៅពេលក្រោយទៀត។ ប៉ុន្តែយើងចង់ដឹងពីបញ្ហាលទ្ធភាពនៃការ -- អង្គជំនុំជម្រះនឹងរៀបចំកាលវិភាគសវនាការសម្រាប់សប្ដាហ៍ក្រោយនេះយ៉ាងដូចម្ដេច។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងចាំការពន្យល់ពីសហព្រះរាជអាជ្ញានៅរសៀលនេះសិន ក៏ប៉ុន្តែខាងយើងគឺយើងត្រៀមខ្លួនរួចហើយសម្រាប់សាក្សី 2-TCW-988 និង 2-TCW-987 នៅដើមសប្តាហ៍ក្រោយនេះលោកប្រធាន។

[១០:៥៤:៥២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយចុះខាងភាគីក្រុមមេធាវីការពារក្តីវិញ យ៉ាងម៉េចដែរលើបញ្ហាលទ្ធភាពនៃការប្រមើលមើលលើការដែលអង្គជំនុំជម្រះមានបំណងក្នុងការរៀបចំសវនាការនៅដើមសប្តាហ៍ក្រោយនេះក្នុងការស្តាប់សក្ខីកម្មសាក្សីផ្សេងទៀតដែលមិនមានការពាក់ព័ន្ធនឹងបញ្ហាដែលការដាក់បង្ហាញឯក-សាររបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលមានបំណងជូនដំណឹងតាមអ៊ីម៉ែលដែលយើងបានលើកជាបញ្ហាសារវន្តមកពិភាក្សាអម្បាញ់មិញនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-988 និងសាក្សីដែលមានរហស្សនាម 2-TCW-987។

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំពិបាកក្នុងការឆ្លើយសំណួរនេះណាស់លោកប្រធាន។ ខ្ញុំឃើញអ៊ីម៉ែលទាំងបួននេះនៅពេលព្រឹកហើយខ្ញុំមិនទាន់ទាំងមានពេលបានអានឲ្យបានជាផ្លូវការនៅឡើយ។ ខ្ញុំក៏មិនប្រាកដផងដែរ ហើយខ្ញុំគិតថាមានសាក្សីមួយរូប គឺសាក្សី 987 គឺជាសាក្សីដែលអាចផ្តល់សក្ខីកម្មអំពីហេតុការណ៍នៅក្នុងស្រុកកងមាស ហើយសាក្សីមួយទៀត បើខ្ញុំចាំមិនខុសទេ គឺមានតួនាទីអាចផ្តល់សក្ខីកម្មអំពីស្រុកកំពង់សៀមគឺតំបន់៤១។ ដូច្នេះខ្ញុំគិតថាជាការ -- ទុកជាការសម្រេចរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងសំណើរបស់យើង។ ចំពោះការស្តាប់សាក្សី ទាក់ទងទៅនឹងមន្ទីរសន្តិសុខវត្តអូរត្រកួនវិញ គឺ TCW-987 គ្រាន់តែអាចផ្តល់សក្ខីកម្មអំពីអង្គហេតុទាក់ទងទៅនឹងមន្ទីរសន្តិសុខអូរត្រកួនក្នុងស្រុកកងមាសប៉ុណ្ណោះ ហើយខ្ញុំគិតថាយើងអាចបន្តជាមួយសាក្សីរូបនេះ ប៉ុន្តែចំពោះសាក្សីដទៃទៀតដែលពួកគាត់មានការពាក់ព័ន្ធជាមួយនឹងការទំនាក់ទំនងនៅក្នុងតំបន់៤១ ក៏ដូចជាហេតុការណ៍នៅក្នុងស្រុកកំពង់សៀម ខ្ញុំគិតថាវាជាការលំបាកក្នុងការបន្តជាមួយសាក្សីទាំងអស់នោះដោយសារតែមានការដាក់បង្ហាញឯកសារយ៉ាងច្រើន។ ដូច្នេះខ្ញុំចង់បញ្ជាក់ប្រាប់ថា យើងស្ថិតនៅក្នុងដំណាក់កាលមួយដែលប្លែកដែលយើងមិនដែលធ្លាប់ជួប គឺទាក់ទងទៅនឹងស្រុកកំពង់សៀម។ ជាជម្រើសមួយទៀត គឺថាយើងអាចបន្តកិច្ចដំណើរការនីតិវិធីមួយ

ដូចដែលយើងបានបន្តគឺសាក្សី 2-TCW-1000 ព្រោះថាគាត់មានភាពប្រហាក់ប្រហែលគ្នាជាមួយនឹងសាក្សីដែលបានផ្តល់ក្នុងសប្តាហ៍កន្លងមកនេះទាក់ទងទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាម។

[១០:៥៨:១៤]

ហើយខ្ញុំគិតថាប្រហែលជាខាងព្រះរាជអាជ្ញាអាចចាប់ផ្តើម ទោះបីថាវាមានបញ្ហាក៏ដោយ ក៏ពួកគាត់អាចចាប់ផ្តើមការសួរសាក្សី 938 ហើយយើងអាចនឹងបន្តនៅពេលណាមួយទៀតហ្នឹង គឺទៅលើសាក្សី 938 ខ្ញុំគិតថាវាជាការស្មុគស្មាញ តែសាក្សីត្រូវទៅហើយត្រឡប់មកវិញ ប៉ុន្តែវាជាជម្រើសមួយទៀតរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ ក៏វាជាបញ្ហាមួយដែលហាក់ដូចជាមានបញ្ហាស្មុគស្មាញច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំស្ថិតនៅក្នុងស្ថានភាពលំបាកដូចមេធាវីលោកនួន ជា ដែរ។ ខ្ញុំមិនដឹងថាតើខ្ញុំត្រូវសម្របខ្លួនឲ្យបានឆាប់រហ័សយ៉ាងម៉េចទៅនឹងហេតុការណ៍នេះទេ ខ្ញុំត្រូវតែពិនិត្យមើលឲ្យអស់សិន។ ខ្ញុំចង់កត់សម្គាល់ទី១ ពាក់ព័ន្ធទៅនឹងសាក្សី 2-TCW-987 ខ្ញុំឮសហព្រះរាជអាជ្ញាគាត់ថានៅក្នុងឯកសារថ្មីៗដែលនឹងដាក់បង្ហាញជូននោះ ឬក៏ដាក់ជាភស្តុតាងនោះ គឺមិនទាន់ -- គឺឯកសារទាំងអស់ហ្នឹងមិនមានពាក់ព័ន្ធនឹងសាក្សីហ្នឹង រូបហ្នឹងទេ។ ហើយក៏ខ្ញុំក៏វាមិនឃើញមានពាក់ព័ន្ធទៅនឹងឯក-សារ -- ទៅនឹងសាក្សី 938 ដែរ គឺវា -- ក៏ប៉ុន្តែយើងឃើញថាវាមានទំនាក់ទំនងរវាងថ្នាក់លើរបស់ 2-TCW-937 និងថ្នាក់លើរបស់ 2-TCW-938។ អ៊ីចឹងហើយ យើងត្រូវតែពិនិត្យមើលបានលម្អិតទៅលើឯកសារថ្មីហ្នឹងទាំងអស់សិន ដើម្បីឲ្យយើងអាចដឹងបាន។ ដូច្នេះ ខ្ញុំនិយាយនេះគ្រាន់តែជាការសន្មតសិនទេ គ្រាន់តែជាសមត្ថកម្មសិនទេ ព្រោះថាខ្ញុំមិនទាន់ដឹងថាត្រូវធ្វើយ៉ាងម៉េចទេនៅក្នុងដំណាក់កាលនេះនោះ។

ហើយប្រហែលជាសំណើរបស់មេធាវី នួន ជា ក្នុងការចាប់ផ្តើមស្តាប់សាក្សី 2-TCW-938 សិន ហើយបន្ទាប់មកអាចផ្អាកសិន ដើម្បីឲ្យយើងពិនិត្យមើលឯកសារថ្មីទាំងអស់ហ្នឹងសិនក៏បាន ដូចខាង នួន ជា គាត់បានស្នើ ឬមួយក៏យើងអាចពិនិត្យមើលសិន ចាំពេលសម្រាកថ្ងៃនេះហ្នឹង ខ្ញុំមើលជាមួយលោក គង់ សំអុន សិន ថាតើយើងធ្វើយ៉ាងម៉េចសម្រាប់ដើមសប្តាហ៍ក្រោយនេះ។ ឥឡូវនេះ

យើងដូចជាពិបាកហើយ មិនដឹងថាតើឆ្លើយយ៉ាងម៉េចបានទៅនឹងសំណួររបស់អង្គជំនុំជម្រះនោះ ព្រោះថាវាទាន់ហាន់ពេក។ ខ្ញុំមិនអាចផ្តល់ព័ត៌មានអីជាក់លាក់បានទេ ក៏ប៉ុន្តែសាក្សី 2-TCW-988 គឺដូចជាអត់មានបញ្ហាអីចោទឡើងទេ អ៊ីចឹងយើងអាចកោះហៅសាក្សីហ្នឹងមកមុនគេបាន។ ហើយខ្ញុំមិនដឹងថាតើខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ គាត់មានបញ្ជីសាក្សីត្រូវហៅយ៉ាងម៉េចខ្លះទេ។ ឥឡូវនេះ ខ្ញុំមិនអាចផ្តល់ព័ត៌មានអីបានច្បាស់ជូនអង្គជំនុំជម្រះបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញលោកចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គ្រាន់តែជាមតិបន្ថែមប៉ុណ្ណោះ។ ជាទូទៅ គឺសំណើតាមវិធាន៨៧(៤) គឺជាសំណើមួយដែលមិនជាអាក្រក់ណាស់ណានោះទេ។

**លោក នីកូឡាស គូមជែន៖**

ហើយដើម្បីជាការបញ្ជាក់គឺថា យើងមិនបានដាក់សំណើតាមវិធាន៨៧(៤) នោះឡើយនៅមុនពេលសាក្សីដាក់បង្ហាញ។ យើងបង្ហាញឯកសារទាំងអស់នេះដោយសារតែយើងគឺថា ក្រោយពេលដែលផ្តល់សាក្សីគឺថា យើងគិតថាឯកសារហ្នឹងវាមានភាពពាក់ព័ន្ធទៅនឹងផ្នែកនេះ ប៉ុន្តែយើងមិនបានដាក់សំណើតាមវិធាន៨៧(៤) ក្នុងពេលនេះទេ ប៉ុន្តែអាចនៅពេលក្រោយ។

[១១:០២:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការពិភាក្សាលើបញ្ហានេះ ហើយទោះបីយ៉ាងណាក៏ដោយគឺកិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះគឺបំណងដូចជម្រាបអ៊ីចឹង គឺបំណងក្នុងការរៀបចំនូវកាលវិភាគសវនាការសម្រាប់បន្តធ្វើសម្រាប់ដើមសប្តាហ៍ក្រោយ។ នេះជាបញ្ហាចំពោះមុខ។ បញ្ហាទី២ គឺគិតពីផលវិបាកនៃការផ្លាស់ប្តូរអំពីលំដាប់សាក្សីនេះ គឺទាំងភាគី ទាំងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលនឹងមានភារកិច្ចនៅក្នុងការទៅសម្របសម្រួល និងទទួលយកសាក្សីមកផ្តល់សក្ខីកម្ម។ នេះជាបញ្ហាដែលអង្គជំនុំជម្រះមានបំណងចង់បានឆាប់រហ័សដើម្បីឆ្លើយតបបានទាន់ពេលវេលា ហើយអង្គជំនុំជម្រះសង្ឃឹមថានៅថ្ងៃក្រោយពីអាហារថ្ងៃត្រង់នេះ ភាគីសហព្រះរាជអាជ្ញា និងភាគីដទៃទៀតពាក់ព័ន្ធនឹងបញ្ហានេះទំនងអាចបញ្ជាក់

បន្ថែមខ្លីលើបញ្ហានេះដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានសមស្របសម្រាប់សម្រេចចាត់ចែងលើការរៀបចំកាលវិភាគសវនាការស្ដាប់សក្ខីកម្មសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សប្ដាហ៍ក្រោយបាន។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីបន្តការតាំងសំណួរ ហើយសូមមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីរួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១១:០៤:៥២]

**ប្រធានអង្គជំនុំ៖**

បាទ សូមផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះប្រសិនបើមានសំណួរ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគី។ មេធាវីនាំមុខសូមផ្ទេរវេទិកានេះទៅជូនលោក វ៉ែន ពៅ ដើម្បីសួរសំណួរជំនួសឲ្យមេធាវីនាំមុខ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី វ៉ែន ពៅ!

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

[១១:០៥:៣១]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរលោក។ សំណួរខ្ញុំជាដំបូង គឺថាកាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ កន្លងមកនេះ លោកបានឆ្លើយរួចហើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាជាតិ ដែលពាក់ព័ន្ធទៅនឹងវិហារចាមនៅក្នុងឃុំរបស់លោក។ លោកបានឆ្លើយ

ថា នៅក្នុងឃុំរបស់លោកមានវិហារចាមមួយ ហើយវិហារនេះក្រោយមកត្រូវខ្មែរ -- ពួកខ្មែរក្រហមបិទ និងធ្វើជាមន្ទីរពេទ្យ។ ខ្ញុំចង់សួរថាតើនៅក្នុងឃុំរបស់លោកទាំងមូលហ្នឹង មានវត្តអារាមខ្មែរយើងដែរទេបាទ?

**លោក សុះ រំលី៖**

**ឆ៖** បាទ មានមួយនៅភូមិក្តុលកណ្តាល ហៅឈ្មោះ -- អ៎!មានឈ្មោះថា វត្តអមប្បវន្ត។

**ស៖** ហើយវត្តនោះ នៅក្នុងរបបខ្មែរក្រហមទាំងមូល តើមានគេអនុញ្ញាតឲ្យប្រតិបត្តិព្រះពុទ្ធសាសនាទេ ឬក៏មានព្រះសង្ឃ ព្រះអីដែរទេ បាទ?

**ឆ៖** ពីឆ្នាំ៧៥មក គឺគ្មានព្រះសង្ឃទេ នៅក្នុងវត្តនុ៎ង ត្រូវបិទអស់ហើយ។

[១១:០៧:០៣]

**ស៖** សូមអរគុណ។ លោកមានដឹង ឬមានពីណាប្រាប់លោកទេថា វត្តខ្មែរនោះត្រូវបានគេយកធ្វើអីនៅជំនាន់ៗនោះ បាទ?

**ឆ៖** នៅក្នុងវត្តហ្នឹង អត់មានធ្វើអីទេ តែក្នុងបរិវេណវត្ត ម្តងម្កាល គឺធ្វើស្នាក់ការចល័ត។

**ស៖** បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតដកស្រង់ចម្លើយរបស់គាត់ចេញពីកំណត់ហេតុស្តាប់ចម្លើយ គឺដែលមានលេខឯកសារ E3/5196 ដែលមានលេខ ERN ជាភាសាខ្មែរ 00204456, ERN ជាភាសាអង់គ្លេស 00223087, ERN ជាភាសាបារាំង 00274739។ នៅក្នុងចម្លើយរបស់គាត់ សំណួរសួរថា៖ "តើពួកខ្មែរក្រហមចាប់ផ្តើមសម្លាប់ប្រជាជនចាមក្នុងភូមិអ្នកឬទេ?" លោកបានឆ្លើយថា៖ "ជាដំបូងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣ មិនជាអាក្រក់ពេកទេ។ ប៉ុន្តែចាប់តាំងពីដើមទីមកពួកគេបានចាប់ផ្តើមបំពាក់បំប៉នមនោគមន៍វិជ្ជាថា ការប្រតិបត្តិសាសនាគឺជាការខាតបង់។"

សំណួររបស់ខ្ញុំចង់សួរលោក ថាតើការវគ្គបំពាក់បំប៉ន ឬក៏ជាមនោគមន៍វិជ្ជានេះថា តើថ្នាក់ណាមកបំពាក់បំប៉ន ហើយគេបំពាក់បំប៉នចំពោះកម្មាភិបាល ឬក៏ប្រជាជនទូទៅ?

**ឆ៖** ដំបូងគេបំពាក់បំប៉នកម្មាភិបាល តែពីឆ្នាំ៧៥មក បានគេបំពាក់បំប៉នដល់ប្រជាជនទាំងអស់។

**ស៖** បាទ សូមអរគុណ។ កាលពីសវនាការថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ កន្លងមកនេះដែរ លោកបានឆ្លើយសំណួរទៅនឹងសហព្រះរាជអាជ្ញាជាតិដែរថា លោកធ្លាប់បានធ្វើរបាយការណ៍ -- អ៎! សុំទោសលោក លោកបានធ្វើជាលិខិតអញ្ជើញទៅមេភូមិ ឬក៏ប្រធានសហករណ៍មកប្រជុំ។ សំណួររបស់

ចង់សួរថាតើការអញ្ជើញនេះជាញឹកញាប់ទេ ប្រចាំខែ? មួយខែប៉ុន្មានដង? ឬយ៉ាងម៉េចដែរបាទ?

**ឆ៖** មិនជាញឹកញាប់ប៉ុន្មានទេ មួយខែមានពីរដង ឬមួយដង។

**ស៖** ចុះក្រៅពីធ្វើលិខិត ធ្វើ -- ក្រៅពីធ្វើលិខិតអញ្ជើញ ថាតើមេឃុំ ឬក៏ថ្នាក់ដឹកនាំឃុំមានចុះទៅតាមមូលដ្ឋាន ឬតាមភូមិ ដើម្បីអប់រំ ឬក៏បំពាក់បំប៉នប្រជាជនដែរទេ?

**ឆ៖** មេឃុំ ភាគច្រើនតែកន្លែងការដ្ឋានជីកប្រឡាយ និងលើកទំនប់។ នៅតាមភូមិ គឺមិនសូវជាច្រើនប៉ុន្មានទេ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកក៏បានឆ្លើយថា លោកក្នុងឋានៈជាស្មៀនឃុំ ការងាររបស់លោក គឺលោកធ្វើរបាយការណ៍ប្រចាំខែ ខ្ញុំចង់សួរលោកថា តើលោកចេះធ្វើរបាយការណ៍នេះពីណាមក មានថ្នាក់ណាមកបង្រៀនលោករបៀបធ្វើរបាយការណ៍នេះ?

**ឆ៖** ដំបូងមេឃុំហ្នឹងគ្រាន់តែប្រាប់ថា របាយការណ៍ដំបូងគេនិយាយពីបញ្ហានេះៗអីចឹង ឲ្យខ្ញុំរាយការណ៍ ប៉ុន្តែភាគច្រើនក្នុងរបាយការណ៍របស់ខ្ញុំ គឺការងាររដ្ឋបាល ពិសេសសង្កត់ធ្ងន់ លើការងារបង្កបង្កើនផល អនុវត្តអ្វីខ្លះបានប៉ុន្មាន។

[១១:១១:១៥]

**ស៖** តើលោកដឹងទេ របាយការណ៍នោះថ្នាក់ឃុំបញ្ជូនទៅណាទៀត ឬទុក តម្កល់ទុកនៅត្រឹមថ្នាក់ឃុំនោះ?

**ឆ៖** រាល់ខែ របាយការណ៍បំណាច់ខែ គឺបញ្ជូនទៅស្រុក។

**ស៖** បាទ សូមអរគុណ។ កាលពីព្រឹកមិញនេះដែរ ឆ្លើយតបទៅនឹងអ្វីដែលលោកបានឆ្លើយជាមួយសហព្រះរាជអគ្គរជាតិ លោកបានបញ្ជាក់ថា នៅអំឡុងឆ្នាំ១៩៧៧ លោកបានជួបជជែកជាមួយកម្មាភិបាលខ្មែរក្រហមម្នាក់ដែលទទួលបន្ទុកខាងសន្តិសុខ ហើយលោកបានបញ្ជាក់ថា ដោយសារការអង្កេតរបស់លោកថាឃើញមានជនជាតិចាមនៅសល់តាមផ្ទះតែប្រហែល១៥ភាគរយ ៨៥ភាគរយទៀតត្រូវបានជម្លៀសចេញ។ តើលោកអាចបញ្ជាក់បានទេ លោកដឹងថានៅពេលនោះ ជាការជម្លៀសជនជាតិចាម ចេញពីភូមិទ្រាតែមួយ ឬក៏ឃុំទាំងមូល?

**ឆ៖** បាទ កាលនុំង ខ្ញុំមិនបានជជែកអីជាមួយគាត់ទេ ខ្ញុំ -- គាត់ទេមកសួរខ្ញុំថា ផ្ទះនេះជាផ្ទះពីណា? ខ្ញុំថាផ្ទះបងប្អូនជនជាតិចាម ក្រោយពីគេជម្លៀសទៅភូមិភាគកណ្តាល តែប៉ុណ្ណឹងទេ។

**ស៖** តើការជម្លៀសចេញ ដែលលោកថាទៅភូមិភាគកណ្តាលនៃជនជាតិចាមនោះ ថាជាការ

ជម្លៀសដោយបង្ខំ ឬក៏ជាការស្ម័គ្រចិត្ត?

**ឆ៖** គឺជម្លៀសដោយបង្ខំ។

**ស៖** តើលោកនៅចាំបានទេ ក្រោយពេលរំដោះ ថ្ងៃ០៧ មករា ៧៩ តើជនជាតិចាមដែលថាលោកថាត្រូវបានគេបង្ខំចេញមានវិលត្រឡប់មកវិញច្រើនទេ ឬយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

**ឆ៖** តាមខ្ញុំប៉ាន់ស្មានទៅ ក្រោយរំដោះ៧មករាហ្នឹង ការវិលត្រឡប់មកវិញ ប្រហែលជា៦០ភាគរយ ហើយឃុំដែលខ្ញុំភ្លាប់បានថា ស្រុកដែលទៅ ហើយស្លាប់ច្រើនជាងគេ គឺស្រុកសន្ទុក ហើយនិងស្រុកស្ទឹងត្រង់។

[១១:១៣:៤៩]

**ស៖** បាទ សូមអរគុណ។ សំណួរខ្ញុំជាបន្តទៀត ពាក់ព័ន្ធនឹងការរៀបការនៅក្នុងរបបខ្មែរក្រហម ខ្ញុំចង់សួរលោកថា តើក្នុងឋានៈលោកជាស្មៀនឃុំ តើលោកបានដឹង បានឮ ឬក៏បានឃើញការរៀបការនៅក្នុងរបបខ្មែរក្រហមនោះទេ បាទ?

**ឆ៖** បាទ ខ្ញុំធ្លាប់ដឹង ហើយខ្ញុំក៏រៀបការនៅសម័យខ្មែរក្រហមដែរ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើការរៀបការនេះជាការរៀបការដោយស្ម័គ្រ ឬក៏មានការបង្ខិតបង្ខំពីថ្នាក់ណាដែរ?

**ឆ៖** កាលរបបហ្នឹង នៅឃុំទ្រា រៀបការតែពីរដងគត់ ក្នុង៣ឆ្នាំ ៨ខែហ្នឹង។ ហើយខ្ញុំរៀបការដំបូងតែប្អូនគូទេ ហើយដល់ឆ្នាំចិតសិប -- កាលហ្នឹងឆ្នាំ១៩៧៧ ហើយក្រោយមកនៅឆ្នាំ១៩៧៨ ម្ដងទៀតមានចំនួនប្រហែលជាង២០គូ។ ហើយកាលនុ៎ង មានបង្ខំខ្លះ ស្ម័គ្រចិត្តខ្លះ ក្រោយមកហ្នឹង។

**ស៖** តើៗការរៀបការហ្នឹងជារវាងជនជាតិចាម និងជនជាតិចាមខ្លួនឯង ឬក៏មានការៗរវាងជនជាតិខ្មែរ និងជនជាតិចាមចម្រុះគ្នា?

**ឆ៖** អត់មានចម្រុះទេ គឺ ចាមនិងចាម ខ្មែរនិងខ្មែរ។

**ស៖** ខ្ញុំចង់បញ្ជាក់ជាមួយលោកបន្តិចដែរ។ លោកបានបញ្ជាក់ហើយថា នៅក្នុងឃុំរបស់លោកហ្នឹង គឺមានភូមិចាមចំនួនប្រាំ ហើយភូមិខ្មែរចំនួនបី។ ខ្ញុំចង់សួរថា តើនៅក្នុងឃុំលោកទាំងមូលហ្នឹងមានជនជាតិភាគតិចវៀតណាមរស់នៅទេ នៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** ពី៧៥ ដល់៧៩ គឺអត់មានទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ផងដែរ លោកបានឆ្លើយថា នៅក្នុងភូមិទ្រារបស់លោក

នុ៎ង មានប្រជាជនចាមប្រហែល២០០គ្រួសារ។ ហើយប្រជាជនសរុបទាំងអស់ហ្នឹង ទាំងប្រាំបីភូមិហ្នឹង ជិត១០០០ គ្រួសារ។ ខ្ញុំចង់បញ្ជាក់ថា តើក្រោយពេលរំដោះ១៧ -- ០៧ មករា ១៩៧៩ ថាតើជនជាតិចាមដែលត្រឡប់មកភូមិវិញ នៅរស់រានមានជីវិតនោះ មានប្រហែលប៉ុន្មាននាក់ដែរ លោកប៉ុន្មានគ្រួសារដែរ លោកអាចប៉ាន់ស្មានបានទេ?

[១១:១៦:៥២]

**ឆ៖** ខ្ញុំក្រោយ ០៧មករា ប្រហែលជាមួយខែខ្ញុំមកដល់ភូមិ។ ហើយកាលនុ៎ង ប្រហាក់ប្រហែលជា៥០០គ្រួសារ។

**លោក វ៉ែន ពៅ៖**

បាទ លោក។ សូមអស់សំណួរហើយ លោក១ប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយដំបូងនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១១:១៧:៣៦]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរលោកនៅព្រឹកនេះ និងនៅរសៀលនេះផងដែរ។ ដំបូងខ្ញុំសូមសួរនូវអ្វីដែលលោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេត ឯកសារ E3/5196។ សំណួរដំបូងបំផុតនោះ គឺលោកបានឆ្លើយថា ខ្មែរក្រហមបានចូលមកដល់ភូមិរបស់លោកនៅក្នុងឆ្នាំ ១៩៧០។ តើត្រឹមត្រូវដែរទេ?

**លោក សុះ រំលី៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** អ្នកណាហ្នឹងឲ្យពិតប្រាកដទៅ ដែលចូលមកភូមិរបស់លោកហ្នឹង នៅពេលនោះ គេស្គាល់

អ្នកទាំងនោះថាជាខ្មែរក្រហម ឬជាអ្នកណា? សូមលោករៀបរាប់ព្រឹត្តិការណ៍ពីឆ្នាំ១៩៧០ ដល់ ៧៦ អ្នកណាគ្រប់គ្រងភូមិរបស់លោក ឃុំរបស់លោក និងស្រុករបស់លោក?

[១១:១៨:៥២]

**ឆ៖** កាលឆ្នាំ៧០ដែលចូលដំបូងនុ៎ង មិនស្គាល់ថាជាខ្មែរក្រហមទេ គឺថារណសិរ្សរួបរួមជាតិកម្ពុជា លាយឡំនឹងកងទ័ពវៀតណាម។ ហើយដំបូង មកចាត់តាំងរចនាសម្ព័ន្ធនុ៎ង មានដាក់ឈ្មោះគេជ្រើសរើសឈ្មោះ វ៉ាត់ ម៉ាត់លី នុ៎ង ជាមេភូមិ។ ហើយប្រធានភូមិនុ៎ង ខ្ញុំភ្លេចឈ្មោះហើយ ព្រោះជាបន្តបន្ទាប់ តែងតែមានការតែងតាំងប្រធានភូមិ ផ្លាស់ប្តូរជាបន្តបន្ទាប់។

**ស៖** លោកទើបតែបាននិយាយថា នៅពេលនោះ កងទ័ពវៀតណាមក៏មកជាមួយដែរ ហើយលោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេតថា នៅពេលពួកគេមកដល់នៅក្នុងឆ្នាំ១៩៧០ គឺថាមានក្រុមរួមចំណុះគ្នាទាំងយួន ទាំងខ្មែរ។ តើលោកចង់និយាយថាម៉េចដែរចំពោះវៀតណាមដែលចូលមកភូមិ ឃុំស្រុករបស់លោកនេះ?

**ឆ៖** សូមសំណួរម្តងទៀត ខ្ញុំអត់ទាន់យល់។

**ស៖** *(គ្មានការបកប្រែ)*

[១១:២០:៥៨]

**ប្រធានអង្គជំនុំ៖**

មិនៗមានការបកប្រែជាភាសាខ្មែរ។

**អ្នកបកប្រែ៖**

អ៊ីចឹងសូមលោករៀបរាប់អំពីការវត្តមានកងទ័ពវៀតណាមដែលចូលមកភូមិរបស់លោកនៅក្នុងឆ្នាំ១៩៧០ហ្នឹង បន្តិចមក។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ ចាប់ផ្តើមសាជាថ្មីឡើងវិញ នូវការរៀបរាប់របស់លោកអម្បាញ់មិញនេះ ព្រោះអត់មានការបកប្រែជាភាសាខ្មែរទេ អ៊ីចឹងមិនៗយល់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំបានសួរលោកថាដូច្នេះថានៅពេលខ្មែរក្រហម បានមកដល់ភូមិរបស់លោក ស្រុករបស់លោក លោកបានឆ្លើយថា "គឺមកដល់ក្នុងឆ្នាំ១៩៧០"។ នៅពេលគេសួរសំណួរ លោកទៅលោក លោកក៏បានឆ្លើយផងដែរថា មានវត្តមានកងទ័ពវៀតណាមចូលមកដល់ភូមិនិងស្រុករបស់លោកផងដែរ។ ហើយលោកបានឆ្លើយទៀតថា នៅពេលខ្មែរក្រហមមកដល់ហ្នឹង គឺមានក្រុមចម្រុះគ្នាទាំងយួន ទាំងខ្មែរ។ សំណួររបស់ខ្ញុំ ថាតើវត្តមានរបស់កងទ័ពវៀតណាមនៅក្នុងភូមិរបស់លោកនេះ គេត្រូវមកនិយាយអំពីអី គេត្រូវមកធ្វើអំពីអី? តើតួនាទីរបស់កងទ័ពវៀតណាមពេលនោះធ្វើអី?

**លោក សុះ រំលី៖**

**ឆ៖** កាលនុំងខាងវៀតណាមហ្នឹង គេមិនរវីរវល់នឹងការងាររដ្ឋបាលចាត់តាំងនោះទេ គេខាងកងទ័ព តែការចាត់តាំងមានបងប្អូនខ្មែរទាំងអស់ ហើយខ្ញុំមិនដឹងថាខ្មែរក្រហមឬក៏រណសិរ្សយ៉ាងម៉េចខ្ញុំមិនដឹងទេ។

[១១:២២:៥៦]

**ស៖** ដូច្នេះ បើខ្ញុំយល់មិនច្រឡំទេ វត្តមានរបស់កងទ័ពវៀតណាមដែលលោកឃើញពីឆ្នាំ៧០ ដល់ ៧៥ហ្នឹង ភាគច្រើនបំផុតគឺថាចូលរួមពាក់ព័ន្ធតែក្នុងសកម្មភាពយោធាទេ នៅក្នុងភូមិរបស់លោក។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ហើយលោកចាំទេថា កងទ័ពវៀតណាមទាំងនេះ ចាកចេញទៅវិញនៅពេលណាដែរ? តើកងទ័ពវៀតណាមហ្នឹងចាកចេញពីភូមិស្រុករបស់លោកនៅក្នុងខែឆ្នាំណាដែរ?

**ឆ៖** ខ្ញុំមិនដឹងទេ កងទ័ពវៀតណាម ព្រោះកងទ័ពវៀតណាមហ្នឹងមិនប្រចាំការនៅឃុំទេ គ្រាន់តែឃើញម្ដងម្យាម គេចល័តទ័ពទាំងអស់។

**ស៖** សូមអរគុណ។ លោកក៏បាននិយាយពីឈ្មោះមនុស្សម្នាក់ឈ្មោះ ម៉ាត់លី។ តើ ម៉ាត់លី នេះជាអ្នកណា?

**ឆ៖** ម៉ាត់លី គឺជាអ្នកភូមិទ្រាហ្នឹង។ ដំបូងគាត់ធ្វើគ្រូបង្រៀននៅខាង១ចម្ការកៅស៊ូ ក្រោយមកគាត់មកនៅភូមិទ្រាហ្នឹង។

**ស៖** លោកស្គាល់មនុស្សម្នាក់ទៀតឈ្មោះ ម៉ាត់លី ដែរ ដែលមានតួនាទីខ្ពស់នៅក្នុងភូមិភាគ

បូព៌ា ក្រោយមកនោះ ក៏ក្លាយទៅជាសមាជិករដ្ឋសភានៃកម្ពុជាប្រជាធិបតេយ្យ។ លោកស្គាល់ដែរទេ?

**ឆ៖** ខ្ញុំឮតែឈ្មោះ ខ្ញុំមិនដែលមានទំនាក់ទំនងស្គាល់គាត់ទេ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឱ្យច្បាស់បន្តិច។ ម៉ាត់លី ដែលលោកកំពុងតែនិយាយនៅក្នុងភូមិរបស់លោកនេះគឺមិនមែនជា ម៉ាត់លី ដែលមានតួនាទីខ្ពង់ខ្ពស់នៅក្នុងភូមិភាគបូព៌ា និងមានតួនាទីនៅក្នុងរដ្ឋសភានៃកម្ពុជាប្រជាធិបតេយ្យនោះទេឬ? តើ ម៉ាត់លី ទាំងពីរហ្នឹងមិនមែនជាមនុស្សតែមួយទេឬ?

**ឆ៖** បាទ មិនមែនទេ ម៉ាត់លី នេះគឺ វ៉ាត់ ម៉ាត់លី នោះជាគ្រូបង្រៀនអ្នកភូមិទ្រា ហ្នឹងឯងក៏មានកំណើតនៅភូមិទ្រាហ្នឹង។

[១១:២៦:១១]

**ស៖** លោកខ្ញុំគិតថាលោកបានឆ្លើយហើយ ប៉ុន្តែខ្ញុំសួរបញ្ជាក់បន្តិច ថានៅពេលមួយលោកបានក្លាយទៅជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា ឬក៏ថាលោកបានក្លាយទៅជាកម្មាភិបាលខ្មែរក្រហម។ ត្រឹមត្រូវដែរទេ?

**ឆ៖** បានឆ្លើយថា ខ្ញុំនៅក្នុងសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ។ អ្នកដែលនៅក្នុងសមាជិកបក្សកុម្មុយនីស្តគេនោះចូលបក្សកុម្មុយនីស្ត ខ្ញុំមិនដែលចូលអ្វីទេ។

**ស៖** នៅពេលហ្នឹងតើលោកមានបានកត់សម្គាល់ថា មានប្រជាជនចាមខ្លះនៅក្នុងទឹកដីរបស់លោកចូលរួមជាមួយចលនាខ្មែរក្រហមដែរទេ ក្រោយឆ្នាំ១៩៧០?

**ឆ៖** ក្រោយ៧០ ប្រហែលជានៅឆ្នាំ១៩៧៣ មាន យុវជនចំនួនប្រហាក់ប្រហែលជា ២០នាក់ចូលធ្វើជាទាហានខាងនោះហើយ ខាង -- មិនដឹងជាខ្មែរក្រហមពេលណាមក ខ្ញុំមិនដឹងទេ។ មិនដឹងជាវណសិរ្សពេលណាមកក៏ខ្ញុំមិនដឹងដែរ ប៉ុន្តែសង្គ្រាមខាងហ្នឹង ចូលទ័ពខាងហ្នឹង។

**ស៖** ដូច្នេះ លោកដឹងថា មានយុវជនចាមប្រហែលជា២០នាក់ ដែលបានចូលរួមចលនាបដិវត្តន៍នៅដើមទសវត្សរ៍១៩៧០។ ចុះ ម៉ាត់លី ដែលលោកមិនដែលបានជួបដែលជាអ្នកមានឋានៈខ្ពង់ខ្ពស់នៅក្នុងជួរកម្ពុជាប្រជាធិបតេយ្យ និយាយពី ម៉ាត់លី មួយនេះ លោកដឹងដែរទេ? លោកស្គាល់ដែរទេ?

**ឆ៖** ខ្ញុំប្រាប់ហើយថា ខ្ញុំមិនស្គាល់ទេ។ ខ្ញុំឮតែឈ្មោះ។

[១១:២៨:៤៤]

**ស៖** ខ្ញុំសូមអានសម្រង់មួយចំនួនចេញពីសក្ខីកម្មរបស់សាក្សីផ្សេង ដែលសាក្សីនោះក៏មកពីភូមិស្រុករបស់លោកដែរ។ សាក្សីរូបនេះ ឈ្មោះ ម៉ាន សេន គាត់បានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតនៃ

ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺ E3/5205 ហើយគាត់ក៏បានផ្តល់សក្ខីកម្មបង្ហាញភស្តុតាងទៅដល់អ្នកនិពន្ធសរសេរសៀវភៅម្នាក់ គឺលោក ឧស្មាន។ ដូច្នេះ ខ្ញុំសូមអានសម្រង់មួយចំនួនចេញពីឯក-សារនិងសៀវភៅរបស់គាត់ ហើយនិងសួរលោក តើលោកយល់យ៉ាងដូចម្តេចដែរ? ឯកសារ E3/7675 ជាពិសេស ERN ជាភាសាអង់គ្លេស 00221859, បារាំង 00293924, ខ្មែរ 00221852 ដល់ 53។ សាក្សីរូបនេះមកពីឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ គាត់បានឆ្លើយថា៖ "ខ្មែរក្រហមចាប់ផ្តើមចាប់អ្នកភូមិនៅភូមិស្វាយឃ្លាំង នៅចុងឆ្នាំ១៩៧៣"។ តើលោកមានបានកំណត់សម្គាល់ឃើញថាមានការចាប់ជនជាតិចាមដែរហើយឬនៅ ចាប់ជនជាតិចាមខ្លះៗដែរឬនៅ នៅក្នុងឆ្នាំ១៩៧៣?

**ឆ៖** ខ្ញុំសូមបញ្ជាក់សួរវិញថា ចាប់នៅឃុំណា? ឃុំស្វាយឃ្លាំង ឬឃុំទ្រា ដែលចាប់នៅឆ្នាំ៧៣នោះ?

**ស៖** សាក្សីរូបនេះនិយាយតែការចាប់ខ្លួននៅស្វាយឃ្លាំងទេ ក្នុងឆ្នាំ៧៣។ តែសំណួររបស់ខ្ញុំសួរទៅលោក ថាតើមានការចាប់ខ្លួនអ្នកភូមិរបស់លោកដែរទេ នៅក្នុងឆ្នាំ១៩៧៣នុ៎ង?

**ឆ៖** មាន។

**ស៖** លោកនៅចាំបានទេ អ្នកដែលមកចាប់ខ្លួន គឺជាអ្នកណា?

**ឆ៖** ខ្ញុំមិនដឹងទេ អ្នកមកចាប់ខ្លួនហ្នឹង ឃើញតែទាហាន មកឡាន។

**ស៖** សាក្សីរូបនេះ ក៏បានឆ្លើយផងដែរថា ក្នុងឆ្នាំ១៩៧៤ ការចាប់ខ្លួននេះ គឺថាបន្តធ្វើឡើងនៅក្នុងទីករបស់គាត់។ គាត់ប្រាប់ថា នៅក្នុងឆ្នាំ៧៤នុ៎ង មានការចាប់ខ្លួនដល់៦០នាក់ឯណោះ នៅក្នុងតំបន់របស់គាត់ហ្នឹង។ ចុះនៅក្នុងតំបន់របស់លោកនេះ ទ្រានេះ ក្នុងឆ្នាំ៧៤ នៅតែមានបន្តការចាប់ខ្លួនទៀតដែរទេ?

**ឆ៖** ឆ្នាំ៧៤នុ៎ង មានចាប់ដែរ ប៉ុនថា យូរៗចាប់ម្នាក់ យូរៗចាប់ម្នាក់។

[១១:៣២:៤៦]

**ស៖** សាក្សីរូបនេះ គាត់បានឆ្លើយ -- ខ្ញុំសូមដកស្រង់ "នៅចុងឆ្នាំ១៩៧៤ ការចាប់ខ្លួនគឺមានការធ្លាក់ចុះ។ មិនមានជំនួយការហាគីម ឬក៏គេហៅថាមេក្រុម ក្តាប់តែ១០ផ្ទះនោះ គឺថានៅពេលនោះ មានអ្នកភូមិជាង១០០នាក់ចាប់ខ្លួន។ គឺថាយើងមាននៅស្រែឃ្លាំងមានប្រហែលជា ជំអះហ្នឹង៤០ ហើយមេក្រុមហ្នឹងច្រើន។" ដូច្នេះ ខ្ញុំសួរថានៅចុងឆ្នាំ១៩៧៤នេះ ចុងឆ្នាំ៧៤នេះ តើការចាប់ខ្លួនហ្នឹង វាកើនឡើងឬក៏អត់ទេ?

E1/372.1

**ឆ៖** នៅភូមិទ្រា ចុង៧៤ហ្នឹង មិនកើនទេ។

**លោក វិចទ័រ កូប៉េ៖**

លោកប្រធាន មើលទៅ ប្រហែលជាដល់ពេលសម្រាកពិសាបាយថ្ងៃហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:០១ នាទី)*

[១៣:៣១:០៣]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ទី១ អង្គជំនុំជម្រះសូមសាកសួរទៅព្រះរាជអាជ្ញាថា អង្គជំនុំជម្រះបានទទួលព័ត៌មានពីតំណាង

សហព្រះរាជអាជ្ញាអន្តរជាតិតាមរយៈអ៊ីម៉ែលពេលសម្រាកអាហារថ្ងៃត្រង់នេះ ហើយរហូតដល់ពេលនេះ តើថាលោកសហព្រះរាជអាជ្ញាអន្តរជាតិមានអ្វីចង់បំភ្លឺបន្ថែម បញ្ជាក់បន្ថែមលើអ៊ីមែលដែលផ្ញើឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិកាលពីអំឡុងពេលអាហារថ្ងៃត្រង់នេះដែរឬទេ?

[១៣:៣២:៣៧]

**លោក នីកូឡាស គូមជែន៖**

*(គ្មានការបកប្រែ)*

កំណត់ហេតុស្តាប់ចម្លើយសរុបដែលបានអនុញ្ញាតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតឲ្យបង្ហាញនោះ គឺមាន១២៣កំណត់ហេតុស្តាប់ចម្លើយឯណោះ។ ពីម្សិលមិញ ក៏ដូចជាថ្ងៃនេះ ក្នុងការបង្ហាញតាមរយៈអ៊ីម៉ែលនោះ គឺថាកំណត់ហេតុបួនពាក់ព័ន្ធទៅនឹងជនជាតិចាម ដែលព័ត៌មានទាំងអស់ពាក់ព័ន្ធទៅនឹងជនជាតិចាម និងបង្ហាញជូននៅក្នុងអ៊ីម៉ែល ហើយនៅសល់ជាង១២០ទៀត គឺថារបាយការណ៍ស៊ើបអង្កេត១៦ រួមទាំងឧបសម្ព័ន្ធ ហើយនិងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៤ទៅ៥០០ឯទៀត ទៀតឯណោះ។ នេះក៏ត្រូវធ្វើការបង្ហាញដែរ។ យើងខ្ញុំត្រូវការពិនិត្យនូវឯកសារទាំងអស់នេះ ដើម្បីពិនិត្យមើលថាវាបំពេញលក្ខណៈវិនិច្ឆ័យដែលអង្គជំនុំជម្រះត្រូវឲ្យធ្វើការបង្ហាញនូវឯក-សារទាំងអស់នេះដែរឬក៏អត់នោះ។

[១៣:៣៤:១៨]

ហេតុដូច្នេះ ដូចដែលអង្គជំនុំជម្រះបានបង្គាប់រួចមកហើយ ខ្ញុំស្មាន ប៉ាន់ប្រមាណថា ឯកសារ ១៥០០ ទៅ ២៥០០ទំព័រ ឬក៏ថាតិចជាង១៥០០ទំព័រ ដែលយើងខ្ញុំត្រូវធ្វើការអាទិភាព ហើយដោយត្រូវការពេលវេលាយ៉ាងតិចក៏ពីរសប្តាហ៍ដែរ។ ប្រហែលជាយើងខ្ញុំមិនអាចធ្វើឲ្យបានលឿនជាងពីរសប្តាហ៍នេះទេមើលទៅ ដើម្បីធ្វើការពិនិត្យឲ្យហ្មតចត់មែនទែន។ ដូច្នេះ យើងខ្ញុំស្នើសុំថា គឺថាអនុញ្ញាតឲ្យយើងខ្ញុំធ្វើការកំណត់អត្តិភាពនៃឯកសារទាំងអស់នេះ និងពិនិត្យទៅលើឯកសារណាបំពេញលក្ខណៈវិនិច្ឆ័យឲ្យបានគ្រប់គ្រាន់នោះជាមុនសិន ហើយក្នុងពេលជាមួយគ្នា យើងខ្ញុំ ឯកសារណាខ្លះដែលត្រូវនឹងដាក់ចូលមកក្នុងសំណើសុំ។

យើងខ្ញុំក៏សុំបញ្ជាក់ផងដែរថា យោងទៅតាមការពិនិត្យជាបឋមគឺថា ឯកសារជាង៣០ នៃកំណត់ហេតុស្តាប់ចម្លើយគឺថាមានជាប់ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមនិងខ្មែរក្រោម។ យើងខ្ញុំនឹងព្យាយាមកំណត់អត្តិភាពនៃឯកសារទាំង១២៤ នេះ។ ដូច្នេះ សូមអរគុណច្រើនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ព្ទនូវព័ត៌មានបន្ថែមចុងក្រោយនេះ។

បាទ តទៅនេះអង្គជំនុំជម្រះសម្រេចអំពីលំដាប់លំដោយសាក្សី ដែលនឹងមកផ្ដល់សក្ខីកម្មសម្រាប់សប្ដាហ៍ក្រោយ។ អង្គជំនុំជម្រះបានស្ដាប់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ពីភាគីស្ដីពីការដាក់បង្ហាញឯកសារនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយនិងពីលំដាប់លំដោយសាក្សីសម្រាប់សប្ដាហ៍ក្រោយ។ អង្គជំនុំជម្រះក៏បានប្រឹក្សាយោបល់ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញស្ដីពីលទ្ធភាពរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីណាដែលអាចមកផ្ដល់សក្ខីកម្មបានសម្រាប់សប្ដាហ៍ក្រោយនេះផងដែរ។ អង្គជំនុំជម្រះសម្រេចស្ដាប់សក្ខីកម្មសាក្សីនានាទៅតាមលំដាប់លំដោយដូចខាងក្រោម ដោយចាប់ពីថ្ងៃទី១១ -- ថ្ងៃចន្ទ ទី១១ ខែមករា ឆ្នាំ២០១៦។ ១) គឺសាក្សី 2-TCW-987, ២) 2-TCW-988 ហើយនិង ៣) 2-TCW-928។

ហើយបន្ទាប់ពីការស្ដាប់សក្ខីកម្មសាក្សីខាងលើនេះ អង្គជំនុំជម្រះក៏គ្រោងនឹងស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-894 និង 2-TCW-938 ផងដែរ។ សូមភាគីជ្រាប។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[១៣:៣៧:៣៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មុនពេលសម្រាកពិសាបាយថ្ងៃត្រង់ ខ្ញុំសួរសំណួរលោកអំពីការចាប់ខ្លួននៅក្នុងភូមិរបស់លោកនៅក្នុងឆ្នាំ១៩៧៤។ តើលោកដឹងថានៅក្នុងខែធ្នូ ឆ្នាំ៧៤ មានការចាប់មេដឹកនាំចាមនៅភូមិទ្រានោះ គឺថាវាធ្វើឱ្យមានការដើបបះបោរដែរឬទេ?

**លោក សុះ រំលី៖**

**ឆ៖** នៅខែធ្នូ ដូចអត់មានទេ។

**ស៖** អាចមានការបះបោរពីរលើកនៅក្នុងភូមិរបស់លោក។ ខ្ញុំសួរការបះបោរលើកទី១ ដោយ-សារថានៅពេលឈប់សម្រាក ខ្ញុំសួរពីឈ្មោះ ម៉ាត់ លី។ មិនមែន ម៉ាត់ លី ដែលលោកស្គាល់

ច្បាស់លាស់នោះទេ គឺ ម៉ាត់ លី ដែលជាមេដឹកនាំចាម។ គាត់បានប្រាប់ ប៉ែន យៀរនិន ជាទស្សនវិទូជនជាតិអូស្ត្រាលីថា មានការបះបោរនៅក្នុងឆ្នាំ១៩៧៤ ដែលនាំឱ្យមានការចាប់ខ្លួនជាច្រើននោះ។ តើលោកមានដឹងអំពីការចាប់ខ្លួនលើកទី១ ប្រហែលជាមួយឆ្នាំមុនការបះបោរលើកទី២។ លោកដឹងទេ?

**ឆ៖** បាទ នៅ -- ខ្ញុំនៅចាំបានថានៅចុងឆ្នាំ១៩៧៣នោះ មានការបះបោរតូចមួយនៅភូមិទ្រាទី៥ មិនមែនភូមិខ្ញុំទេគឺភូមិទ្រាទី៥ក្នុងឃុំទ្រាហ្នឹង។ ហើយកាលនោះមានការចាប់ខ្លួន។ តាមខ្ញុំប៉ាន់ស្មានមើលលើឡានទៅប្រហែលជា ២០នាក់។

**ស៖** ខ្ញុំសូមអានសម្រង់ចេញពីសៀវភៅលោក ប៉ែន យៀរនិន ទស្សនវិទូគឺឯកសារ E3/1593 ERN ជាភាសាអង់គ្លេស 00678635, បារាំង 00639030, ខ្មែរ 00637765។ សម្រង់នោះគឺដូចតទៅនេះ៖ “នៅខែធ្នូ ឆ្នាំ៧៤ ការចាប់ខ្លួនមេដឹកនាំចាម នៅភូមិទ្រា ឃុំក្រូចឆ្មា ស្រុកក្រូចឆ្មារ គឺថានាំឱ្យមានការបះបោរ។ តួលេខនៃការចាប់ខ្លួន មិនដឹងច្បាស់លាស់ទេ។ ក៏ប៉ុន្តែចាមគឺថា ដែលងើបធ្វើការបះបោរយ៉ាងធំនោះគឺថា គឺកើតមាននៅក្នុងតំបន់២១ គឺអ្នកដែលគាំទ្រទៅដល់សម្ដេច សីហនុ និងវៀតណាម។” ប្រភពអ្នកផ្ដល់ព័ត៌មាននេះគឺឈ្មោះ ម៉ាត់លី។ តើការបះបោរមួយនេះឬដែលលោកថា លោកដឹកដែរនោះ ដែលវាអាចកើតនៅក្នុងឆ្នាំ៧៣ ពាក់ព័ន្ធទៅនឹងចាប់ខ្លួនមនុស្សស្មោះស្ម័គ្រជាមួយសម្ដេច នរោត្តម សីហនុ ហើយនិងអ្នកដែលមានជាតិកំណើតហ្នឹងពីវៀតណាម? លោកដឹងដែរទេ?

**ឆ៖** រឿងហ្នឹងខ្ញុំមិនដឹងទេ។ រឿងហ្នឹងរឿងជ្រៅជ្រះ ដូចលោកមានប្រសាសន៍អីចឹង ខ្ញុំអត់ដឹងទេ។

[១៣:៤២:០២]

**ស៖** មិនថ្វីទេលោកសាក្សី ឥឡូវខ្ញុំបន្តដល់ឆ្នាំ៧៥។ ខ្ញុំនិយាយអំពីចម្លើយរបស់ឈ្មោះ ម៉ានហ្សាញ *(តាមការបកប្រែ)* ដែលឆ្លើយជូន អ៊ីសា ឧស្មាន នេះគឺឯកសារ E3/7675, ERN ជាភាសាខ្មែរ 002218៥៣, បារាំង 002939924 និងអង់គ្លេស 00221859។ សាក្សីរូបនេះ មកពីភូមិផ្សេងទេ មិនមែនភូមិរបស់លោកទេ គឺមកពីភូមិស្រែឃ្លាំង។ គាត់ថានៅឆ្នាំ៧៥ ការចាប់ខ្លួនគឺថាចាប់លែងរើសមុខហើយ។ ខ្ញុំសូមសួរលោក។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវីការពារក្ដីលោកបានផ្ដល់ឯកសារយោងហើយ។ លោកមិនបានយោងទៅលើចម្លើយដែលបានមកពីការធ្វើទារុណកម្មទេអីហ៎?

[១៣:៤៣:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

អត់ទេលោកស្រីចៅក្រម។ នេះគឺជាសៀវភៅរបស់ អ៊ីសា ឧស្មាន ប៉ុន្តែគាត់បានប្រើឯកសារនេះថា ជាប្រភពនៃការសួរចម្លើយដោយធ្វើការធ្វើទារុណកម្ម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំបានផ្តល់ឯកសារ E3 រួចហើយនៅក្នុងចម្លើយរបស់គាត់ ឆ្លើយជូនទៅលោក អ៊ីសា ឧស្មាន។ ដូច្នេះ--

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសុំផ្តល់ ERN ឲ្យបានត្រឹមត្រូវបន្តិចមើល ព្រោះខ្ញុំមើលទៅដូចមិនត្រូវ។ ខ្ញុំមាន E32 -- ខ្ញុំមានឯកសារ E3/2653 ហើយ ប៉ុនមើល ERN ផ្ទៀងទៅមិនត្រូវគ្នា។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារ E3/7675។ ខ្ញុំថាសៀវភៅរបស់គាត់ហ្នឹង គឺមានពីរច្បាប់ មាន E3 ហ្នឹងនោះពីរនោះ។ ប៉ុន្តែខ្ញុំយក E3/-- ERN គឺ 00221859។ ហើយខ្ញុំទើបតែដកស្រង់ ERN នេះជាភាសាខ្មែរទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីបុគ្គលនេះមកពីភូមិស្វាយឃ្លាំង ថានៅក្នុងឆ្នាំ១៩៧៥ ហ្នឹងមានការចាប់ខ្លួនលែងរើសមុខហើយ។ ជួនកាលចាប់ពេលយប់ ជួនកាលចាប់តែងថ្ងៃតែម្តង។ ហើយគាត់បន្តទៅទៀតថា ពាក្យចចាមអារ៉ាមថា ខ្មែរក្រហមនឹងចាប់អ្នកណាក៏ដោយ ឲ្យតែជាប់ពាក់ព័ន្ធនឹងចលនាខ្មែរស។ ប្រជាជនរាប់រយនាក់ត្រូវបានចាប់ខ្លួន។ សំណួររបស់ខ្ញុំ សួរថាតើលោកមានបានដឹងការចាប់ខ្លួននៅដើមឆ្នាំ១៩៧៥ និងចុងឆ្នាំ៧៥ ដែរទេ? ហើយតើលោកស្គាល់ ដឹង ឬក៏ធ្លាប់ឮអំពីចលនាខ្មែរសនេះដែរទេ?

[១៣:៤៥:២០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! បាទ សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ដោយសារ ឧស្មាន គាត់និយាយអំពីការចាប់ខ្លួននៅភូមិផ្សេង ក្រៅពីភូមិរបស់សាក្សីរូបនេះ ខ្ញុំមិនដឹងថាតើសាក្សីរូបនេះ ដឹងអំពីការចាប់ខ្លួននៅឆ្នាំ១៩៧៥ នៅភូមិស្វាយឃ្លាំង ឬក៏នៅភូមិទ្រាទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសួរតែភូមិទ្រាទេ។ ដោយសារថា គាត់ថាមានការចាប់ខ្លួនច្រើននៅស្វាយឃ្លាំងនោះ ដែលជាប់ពាកព័ន្ធទៅនឹងចលនាខ្មែរស។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះ សំណួររបស់ខ្ញុំសួរថា តើអ្នកដែលគេចាប់ខ្លួននៅក្នុងភូមិរបស់លោក ក្នុងឆ្នាំ១៩៧៥ ហ្នឹង គឺចាប់ខ្លួនដោយសារតែមានការជាប់ពាក់ព័ន្ធទៅនឹងចលនាខ្មែរសនេះដែរ ឬក៏យ៉ាងណា?

**លោក សុះ រំលី៖**

**ឆ៖** កាលហ្នឹងមានការចាប់ខ្លួនមែន ក៏ប៉ុន្តែរឿងពាក់ព័ន្ធនឹងខ្មែរណាខ្ញុំមិនដឹងទេ ឃើញតែការចាប់ខ្លួន។

**ស៖** មិនមែនត្រឹមតែពាក់ព័ន្ធទៅនឹងការចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៥ តែមួយនោះទេ ប៉ុន្តែការចាប់ខ្លួនដទៃៗទៀតនោះ តើលោកដឹងទេ ហើយចុះលោកធ្លាប់ឮសូរពាក្យថា “ចលនាខ្មែរស” នេះដែរទេ?

[១៣:៤៧:០៣]

**ឆ៖** កាលចុង៧៤ ខ្ញុំមានឮថាខ្មែរស ប៉ុន្តែខ្ញុំមិនដឹងថាខ្មែរសហ្នឹងមកពីប្រភពណា ទាក់ទងកន្លែងណា ខ្ញុំមិនដឹងទាំងអស់។

**ស៖** ហើយលោកចាំដែរ អ្វីដែលលោកបានឮនៅក្នុងឆ្នាំ៧៤-៧៥ អំពីចលនាខ្មែរសហ្នឹង លោកឮថាម៉េចដែរ?

**ឆ៖** ខ្ញុំគ្រាន់តែឮថា មានចលនាខ្មែរស ប៉ុនមិនដឹងមូលដ្ឋានគេនៅត្រង់ណា រូបរាងគេយ៉ាងម៉េច ខ្ញុំមិនដឹងទេ។

**ស៖** មិនថ្វីទេលោកស្រី ឥឡូវនេះខ្ញុំចូលអំពីការបះបោរលើកទី២ នៅភូមិរបស់លោក។ ការបះបោរលើកនេះគឺនៅក្នុងឆ្នាំ១៩៧៥ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកថាការបះបោរក្នុងឆ្នាំ១៩៧៥ តើត្រឹមត្រូវដែរទេ ដែលថាការបះបោរក្នុងឆ្នាំ១៩៧៥ហ្នឹង គឺកើតឡើងនៅក្នុងខែតុលា ១៩៧៥?

**ឆ៖** នៅភូមិទ្រា ខ្ញុំមិនដែលថាមានបះបោរនៅឆ្នាំ១៩៧៥ទេ ខ្ញុំបានប្រាប់ថា មានការបះបោរនៅឆ្នាំ១៩៧៣ នៅភូមិទ្រាទី៥។

**ស៖** ដូច្នេះនៅក្នុងភូមិទ្រា ក្នុងខែតុលា ១៩៧៥ នោះគឺមិនមានការបះបោរនៅក្នុងភូមិទ្រា របស់

លោកនេះទេ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ការបះបោរអត់មានទេ ប៉ុន្តែការបង្ក្រាបមាន។

**ស៖** អ៊ីចឹងលោកកំពុងតែនិយាយថា មិនមានការបះបោរក្នុងភូមិទ្រាទេ ប៉ុន្តែមានការចាប់ខ្លួនអ៊ីចឹងឬ? មានការបង្ក្រាបអ៊ីចឹងឬ?

**ឆ៖** បាទ ពិតមែន។

[១៣:៤៩:៤៥]

**ស៖** ខ្ញុំសូមអានសម្រង់មួយដែលចេញពីសៀវភៅរបស់លោក ប៉ែន យៀរនិន ជាទស្សនវិទូជនជាតិអូស្ត្រាលី។ លោកប្រធាន គឺឯកសារ E3/159 ហើយនៅក្នុងសៀវភៅរបស់គាត់នេះ ERN គឺ ERN អង់គ្លេស 00678636, បារាំង 00639034, ខ្មែរ 00637770។ សូមដកស្រង់ -- សូមអនុញ្ញាតឱ្យខ្ញុំបញ្ចប់សំណួររបស់ខ្ញុំសិន សូមដកស្រង់ ជនជាតិ -- សាក្សីជាជនជាតិបារាំងម្នាក់ឈ្មោះ ហ្វ្រង់ស្វ័រ ប៉ុងស្វូដ៍ គាត់និយាយថា -- សូមដកស្រង់ ប៉ង់ស្វូដ៍ បាននិយាយថា៖ “នៅក្នុងខែវិច្ឆិកា ១៩៧៥ ចាមនៅក្នុងភូមិទ្រា ស្រុកក្រូចឆ្មារ ក៏បានងើបបះបោរដែរ។ ហើយបន្ទាប់មក ខ្មែរក្រហមបានកម្ទេចភូមិនោះ ហើយនិងកម្ទេចអ្នកដែលមេដឹកនាំ គេបោះខ្មោចចូលទៅក្នុងទន្លេ។ គឺថាសាកសពខ្មោចហ្នឹងអណ្តែតនៅតាមបណ្តោយទន្លេមេគង្គ។”

លោកសាក្សី តើលោកធ្លាប់ឮពីព្រឹត្តិការណ៍នេះទេ? សាក្សីឈ្មោះ ប៉ង់ស្វូដ៍ នេះបានរៀបរាប់អំពីការបង្ក្រាបយ៉ាងចាស់ដៃនៅក្នុងភូមិរបស់លោក។ តើលោក -- គាត់និយាយនេះ ត្រឹមត្រូវដែរទេ ឬក៏មិនត្រឹមត្រូវទេ?

**លោក នីកូឡាស គូមជែន៖**

នៅពេលដែលមេធាវីការពារក្តីអាន ERN គឺថា ខ្ញុំមាន ERN ខុសគ្នានៅក្នុងឯកសារលើ /159 ដោយសារមានការបាត់ទំព័រខ្លះ ប្រហែលជាមេធាវីការពារក្តីកំពុងតែមានអត្ថបទនៃឯកសារនេះខុសពីខ្ញុំ ហើយមើលទៅ ដោយសារតែ ERN របស់ខ្ញុំ និងរបស់គាត់ហ្នឹង គឺថាខុសគ្នាទាំងស្រុង។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាខ្ញុំមានកំហុស ERN ជាភាសាខ្មែរ អង់គ្លេស ហើយនិងខ្មែរ ប៉ុន្តែបារាំងហ្នឹង គឺត្រឹមត្រូវហើយ។

[១៣:៥២:៤៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសួរឲ្យបានច្បាស់លាស់ ថាតើសៀវភៅហ្នឹង ជាសៀវភៅមួយដែលបានកែប្រែថ្មី ពិនិត្យកែប្រែថ្មីឡើងវិញ ឬក៏សៀវភៅចាស់? លោកសាក្សី សាក្សីដែលជាជនជាតិបារាំងនេះ បានរៀបរាប់អំពីការបង្ក្រាបយ៉ាងចាស់ដៃទៅលើការបះបោរ។ គេបាន គឺថាមានការកាត់ក្បាលមនុស្ស ហើយគេទម្លាក់ខ្មោចហ្នឹងទៅក្នុងដងទន្លេមេគង្គនៅក្នុងខែវិច្ឆិកា ឆ្នាំ៧៥។ តើលោកធ្លាប់ឮពីរឿងនេះទេ?

**លោក សុះ វំលី៖**

**ឆ៖** ខ្ញុំអត់ធ្លាប់ឮទេ។

**ស៖** ចុះលោកធ្លាប់ឮការបង្ក្រាបនៅភូមិជិតៗភូមិលោកដែរទេ ដូចជានៅកោះផល និងនៅស្វាយឃ្លាំង? ហើយបើសិនជាធ្លាប់ឮ ថាមានអ្វីកើតឡើងនៅភូមិទាំងពីរនេះ?

**ឆ៖** ខ្ញុំធ្លាប់ឮបង្ក្រាបនៅភូមិ ថាបះបោរនៅភូមិកោះផល ហើយនិងស្វាយឃ្លាំង។ ឮថា បាញ់សម្លាប់យ៉ាងរង្គាលនៅកន្លែងនុ៎ង ហើយក្រោយពីកន្លែងនោះមក ក្រោយពីបង្ក្រាបកន្លែងនោះមក ភូមិទ្រាដែលភូមិមិនបះបោរ គេមកបង្ក្រាបភូមិនេះទៀត។

[១៣:៥៤:២២]

**ស៖** ខ្ញុំសូមអានសម្រង់ចេញពីអ្នកនិពន្ធដដែល ទំព័រដដែល គឺ ម៉ាន ស៊ើន គឺ៖ "យើងឮស្គរពីវិហារមក យើងៗឮស្គរមានការវាយស្គរ ដើម្បីឲ្យអ្នកភូមិនោះងើបមកបះបោរ នៅល្ងាចៗនោះគឺថាមិនមានប្រតិកម្មអ្វីពីខ្មែរក្រហមទេ។" ហ្នឹង គាត់និយាយអំពីខែតុលា ឆ្នាំ៧៥។ "នៅម៉ោងប្រាំបីព្រឹកស្អែកឡើង ក៏កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធ ចេញមកពីទិសខាងលិច គឺថាគេបានវាយមកលើ បាញ់លើអ្នកបះបោរ។ ខ្ញុំមានដាវ ត្រៀមខ្លួនរួចជាស្រេចហើយ ដើម្បីតដៃវិញ។ ពីកន្លែងដែលខ្ញុំឈរទៅហ្នឹង ខ្ញុំមើលឃើញខ្មែរក្រហមមកពីថ្នាក់ស្រុក ហើយនិងកងទ័ពខ្មែរក្រហមមកពី ក្រូចឆ្មារ គេមិនអាចចូលមកក្នុងភូមិបានទេ។ នៅម៉ោងប្រាំបួន ខ្ញុំឃើញកម្លាំងរាប់រយនាក់មកបន្ថែមទៀត មានស្លៀកពាក់ឯកសណ្ឋានខុសពីកងទ័ពស្រុក។ ពួកគេមានស្ពាយសាក់កាដូ និងមានអាវុធគ្រប់ប្រភេទ គេបាញ់អាវុធធុនធ្ងន់ក៏ដូចជាអាវុធស្រាលសំដៅមកលើអ្នកភូមិ ហើយគេក៏បាញ់បន្តទម្លាក់មកច្រាំទន្លេ ហើយក្រោយមកគាត់និយាយថា កងទ័ពខ្មែរក្រហមប្រាំមួយនាក់ត្រូវបានចាក់សម្លាប់។" នៅពេលដែលខ្ញុំអានសម្រង់នេះទៅ តើលោកធ្លាប់ឮអំពីការបង្ក្រាប ការបះបោរនៅស្វាយឃ្លាំង និងកោះផលនេះដែរទេ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែបានឮការបះបោរបង្ក្រាបនៅស្វាយឃ្លាំងនុ៎ង ឮថាក្រុមបះបោរហ្នឹងបាញ់

ស្លាប់មានជាការយោធាស្រុកក្រូចឆ្មារម្នាក់តែប៉ុណ្ណឹង។

**ស៖** តើលោកបានឮការបាញ់ផ្គោងកាំភ្លើងធំទេ? ហើយនិងការប្រើប្រាស់ទូក បាញ់ចេញពីទូកមក? នេះជារបៀបដែលគេអនុវត្តនៅៗការបង្ក្រាបនៅក្នុងភូមិនោះ។ លោកឮទេ?

**ឆ៖** នៅស្ងាយឃ្លាំងខ្ញុំអត់ឮទេ ព្រោះឆ្ងាយពីភូមិខ្ញុំប្រហែលជាង១០គីឡូ ១០គីឡូដី។ ខ្ញុំគ្រាន់តែឮតាមគេទេ ខ្ញុំមិនដែលឃើញ មិនដែលឮទេ។

**ស៖** ចុះខ្លួនលោកផ្ទាល់នេះ បានឃើញកងទ័ពមកពីស្រុកក្រូចឆ្មារ ឬក៏កងទ័ពមកពីកន្លែងផ្សេងៗទៀត ស្លៀកពាក់ឯកសណ្ឋានខុសៗគ្នាដែរទេ?

**ឆ៖** ការមកបង្ក្រាបនៅភូមិទ្រា ខ្ញុំបានឃើញ ប៉ុនឮគេនិយាយថាទ័ពតំបន់ មានឯកសណ្ឋានយោធាខៀវ ហើយនិងទ័ពស្រុកក្រូចឆ្មាខ្លះ។

[១៣:៥៨:១៤]

**ស៖** ចុះតើលោកចាំអ្វីខ្លះដែរ ពីអ្វីដែលគេប្រាប់លោកនេះ? តើគេប្រាប់លោកឲ្យបានលម្អិតយ៉ាងដូចម្ដេចដែរ ចំពោះទាហានទាំងនោះ ចំពោះកងទ័ពទាំងនោះ?

**ឆ៖** ទាហានទាំងនោះមកដើរ ដំបូងព្រឹកឡើង ដើរចាប់អ្នកដែលមានឈ្មោះ ដែលគេត្រូវចាប់ហ្នឹង គេចាប់មួយសាទៅ ហើយក្រោយមកគេដើរហៅប្រជាជនចុះដីទាំងអស់ទៅប្រជុំតាមភូមិៗ ដើម្បីថ្កោលទោសតែម្ដង។

**ស៖** ខ្ញុំមានចំណាប់អារម្មណ៍ចង់ដឹងអ្វីដែលលោកបានឮ បានឃើញទាហាន មកពីថ្នាក់ស្រុកថ្នាក់តំបន់នេះ តើលោកចាំអ្វីខ្លះទៀត ពាក់ព័ន្ធទៅនឹងកងទ័ពទាំងនោះ?

**ឆ៖** ខ្ញុំមិនឃើញអីទៀតទេ ឃើញតែប៉ុននុ៎ង ឃើញតែកងទ័ពដំបូងហ្នឹង ចាប់អ្នកដែលមានឈ្មោះនុ៎ងប្រហែលជា ៥០-៦០ នាក់ ចាប់ចងទាំងខ្សែៗទៅ។ ហើយក្រោយមកដើរហៅប្រជាជន ចុះដីទាំងអស់ ប្រជុំម្ដុំៗមួយភូមិ មួយកន្លែងៗទៅ រួចទៅមានយោធាខ្លះដើររើផ្ទះតាមក្រោយ។

**ស៖** តើលោកដឹងថាអ្នកភូមិនេះអាចញែកឲ្យដាច់ពីគ្នាថាកងទ័ពណាមកពីស្រុកក្រូចឆ្មារ ហើយនិងកងទ័ពណាមកពីថ្នាក់តំបន់ទេ ប្រជាជនអាចញែកឲ្យដាច់ពីគ្នាអ៊ីចឹងបានទេ?

**ឆ៖** មិនអាចញែកបានទេ ព្រោះប្រជាជនអត់ស្គាល់ទាល់តែសោះ។

**ស៖** ខ្ញុំសូមអានសម្រង់ខ្លីមួយចេញពីចម្លើយរបស់សាក្សីម្នាក់ដែលសាក្សីរូបនេះឈ្មោះ ស្វ ស៊ីម៉ិច TCW-997 គឺឯកសារ E3/5261, ERN អង់គ្លេស 00274336, បារាំង 00285329, ខ្មែរ

00250943។ សាក្សីរូបនេះជាយុទ្ធជននៅក្នុងកងវរសេនាធំលេខ៥៥ ភូមិភាគបូព៌ា -- ហើយវរសេនាតូច៥៥ ភូមិភាគបូព៌ា ដែលវរសេនាតូចនេះ សូមដកស្រង់៖ “មកបង្ក្រាបការបះបោររបស់ចាម” ហើយកងវរសេនាតូចនេះ ស្ថិតនៅក្នុងសេនាធិការតំបន់២១។ តើលោកធ្លាប់ឮថាកងវរសេនាតូច ដែលចំណុះឲ្យកងទ័ពតំបន់២១ហ្នឹងពាក់ព័ន្ធទៅនឹងការបង្ក្រាបការបះបោររបស់ជនជាតិចាមនៅក្នុងឆ្នាំ១៩៧៥ នេះដែរទេ?

**ឆ៖** ខ្ញុំមិនស្គាល់កងវរៈទេ ព្រោះខ្ញុំស្គាល់ -- ឮថាយោធាតំបន់តែម្តង តែមួយមុខគត់។

[១៤:០២:៥១]

**ស៖** តើលោកធ្លាប់ឮដែរឬទេថា គឺនាយករដ្ឋមន្ត្រីបច្ចុប្បន្ននៃប្រទេសនេះជាលោក ហ៊ុន សែន នោះ ក៏គាត់ជាមេបញ្ជាការរបស់វរសេនាតូច៥៥ ហើយក៏បានចូលរួមក្នុងការបង្ក្រាបការបះបោរជនជាតិចាមនៅស្វាយឃ្លាំងនោះ?

**ឆ៖** ខ្ញុំមិនដែលឮទេ ព្រោះខ្ញុំប្រាប់ហើយថា រឿងដល់វរៈ ខ្ញុំអត់ស្គាល់ទេ ខ្ញុំឮថារឿងយោធាតំបន់តែមួយមុខ។

**ស៖** ការបះបោរក្នុងឆ្នាំ១៩៧៥ តើលោកធ្លាប់ឮដែរឬទេថា ប្រជាជនចាមមានប៉ុន្មាននាក់ដែលជាជនរងគ្រោះ ហើយតើការស្លាប់ និងរបួសជនជាតិចាមនោះ ពីខែវិច្ឆិកា តុលា ឆ្នាំ១៩៧៥ ហ្នឹង លោកដឹងទេមានចំនួនប្រហែលប៉ុន្មាន?

**ឆ៖** ការបង្ក្រាបនោះ អត់មានការបាញ់បោះ អត់មានរបួសទេ គឺមានតែការចាប់យកទៅតែម្តងប្រហាក់ប្រហែលពី ៥០ ទៅ ៦០នាក់។

**ស៖** បាទ ម៉ាត់លី ជាមនុស្សដែលយើងនិយាយថា គាត់មានឋានៈខ្ពស់ជាជនជាតិចាមនៅភូមិភាគបូព៌ានៅក្នុងប្រទេសនៅក្នុងឆ្នាំ១៩៧៥ ហើយបានផ្តល់បទសម្ភាសន៍មួយ E3/7821 អង់គ្លេស ERN 00441577, បារាំង ERN 00611784, ខ្មែរ ERN 00229128។ ទំនងជាបង្ហាញថា មនុស្សរាប់ពាន់នាក់បានស្លាប់នៅក្នុងការបង្ក្រាបមួយនោះ។ ហើយគាត់ក៏បន្តនិយាយទៀតថា ២០ ទៅ ៣០ ភាគរយនៃប្រជាជននៅកោះផលបានរស់រានមានជីវិត។ តើលោកអាចឆ្លើយតប ឬក៏ពន្យល់ដូចម្តេចទៅនឹងចម្លើយរបស់គាត់នេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនពិនិត្យឃើញថា កំណត់ត្រាហ្នឹង គឺអាចនឹងធ្វើឲ្យមានការភ័ន្តច្រឡំពីព្រោះមេធាវីបានអានពីអ្វីដែលការបង្ក្រាបនៅក្នុងកោះមួយផ្សេងទៀត។ ហើយក៏សួរទៅសាក្សីនេះថា តើគាត់យល់ឃើញម្តេច? ប៉ុន្តែសាក្សីគាត់និយាយពីអ្វីដែលគាត់បានសង្កេតឃើញនៅក្នុងភូមិរបស់គាត់។ ប៉ុន្តែមេធាវីការពារក្តីបែរជាសួរគាត់ឲ្យផ្តល់យោបល់ពីអ្វីកើតឡើងនៅក្នុងភូមិផ្សេង។ អ៊ីចឹងគឺថា គប្បីតែសួរសាក្សីតែពីអ្វីដែលនៅភូមិទ្រាដែលគាត់រស់នៅទីនោះគាត់បានដឹង បានឮ អ្វីដែលនៅក្រៅភូមិទ្រាមិនគប្បី។

[១៤:០៦:៣១]

**លោក វ៉ិចទ័រ កូប៉េ៖**

ទោះបីជាគាត់មិនបានឃើញថានៅភូមិផ្សេងក៏ដោយ ក៏ប៉ុន្តែភូមិនោះវានៅជិតស្វាយឃ្លាំងនៅជិតភូមិគាត់ ហើយកោះផលនៅម្ខាង ត្រើយម្ខាងនៃទន្លេ គឺជាកោះនៅក្នុងទន្លេ។ ហើយជាទីតាំងដែលវានៅប្រហែលជា១គីឡូម៉ែត្រអីពីកន្លែងគាត់តែប៉ុណ្ណោះ។ ហើយខ្ញុំដឹងថា ការបះបោរជនជាតិចាមនៅឆ្នាំ១៩៧៥ នេះគឺដូចយើងដឹងហើយ គឺថាជាការបះបោរដែលមានការរៀបចំ។ ប៉ុន្តែខ្ញុំរីករាយក្នុងការកម្រិតសំណួរខ្ញុំទាក់ទងទៅនឹងកោះផលអំពីអ្វីដែល ម៉ាត់ លី គាត់និយាយពីការបះបោរនៅកោះផល។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកអាចនឹងផ្តល់មតិទាក់ទងទៅនឹងអ្វីដែល ម៉ាត់ លី គាត់បាននិយាយដែរឬទេ?

**លោក នីកូឡាស គូមជែន៖**

លោកចៅក្រម បើសុំឲ្យសាក្សីហ្នឹងសម្តែងយោបល់បែបនេះដែលអំពីចម្លើយរបស់សាក្សីផ្សេងនោះនេះ ហើយក៏វាស្ថិតនៅក្រៅភូមិរបស់គាត់ទៀតគឺមិនច្បាស់លាស់ទេ ហើយមេធាវីការពារក្តីបញ្ជាក់ថា ជាការបះបោរមានការរៀបចំនោះ គឺជាចម្លើយដែលបានបញ្ជាក់ដោយការនិយាយនោះគឺថា វាខុសពីភស្តុតាង។ ហើយគឺភស្តុតាងនិយាយថា តាមការសង្កេតរបស់គាត់ គឺដែលមានការប៉ុនប៉ង ការជនជាតិចាម ប៉ុន្តែ -- ហើយគេនិយាយថា អាចនឹងមានការបះបោរជនជាតិចាម។ ហើយក្រោយមានការចាប់ខ្លួនជនជាតិចាម ហើយថាគេបម្រុងនឹងផ្តួលរដ្ឋាភិបាល។ អ៊ីចឹងមេធាវីទៅហួសវិសាលភាពដែលសាក្សីដែលដឹងពីអ្វីដែលកើតឡើងនៅក្នុងភូមិផ្សេងទៀត។ ម្ល៉ោះហើយយើងមិនច្បាស់ថា មេធាវីការពារក្តីសួរនៅកន្លែងណានោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ អ៊ីចឹងសហព្រះរាជអាជ្ញាៗនេះគឺជាមនុស្សតែម្នាក់ដែលបដិសេធថា មិនមានការបះបោរជាក់លាក់ដែលត្រូវបានបង្ក្រាបដោយកងវរសេនាធំ វរសេនាតូច ហើយក៏មិនមានការអ្វីសង្ស័យទេ គឺមិនមានការបះបោរទ្រង់ទ្រាយធំ ហើយមានការបង្ក្រាប ហើយមានមនុស្សស្លាប់របួសនឹងច្រើន។ ហើយអង្គហេតុនេះគឺស្ថិតនៅក្នុងភស្តុតាងដែលផ្តល់ឡើងដោយប្រធាននៃមនុស្សទី២ នៃតំបន់២១ គឺប្រធាននៅរដ្ឋសភា គឺ អ៊ុក ប៊ុនឈឿន។ ហើយគាត់ពន្យល់យ៉ាងច្បាស់អំពី -- ទូលំទូលាយអំពីការបះបោរនៅក្នុងឆ្នាំ១៩៧៥។

[១៤:០៩:១១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បញ្ហាស្ថិតនៅក្នុងចំពោះមុខនេះគឺថា -- ហើយយើងយកលោក -- យកចម្លើយរបស់សាក្សីមួយមកតទល់ជាមួយសាក្សីរូបនេះអំពីចំនួននៃជនរងគ្រោះ។ ហើយសំណួរដែលទាក់ទងទៅថា អ្វីដែលសាក្សីអាចឆ្លើយបាន គឺៗនិយាយតែពីភូមិរបស់គាត់។ បាទ អ៊ីចឹងគឺថា យើងសួរពីអ្វីកើតឡើងក្នុងភូមិគាត់ ហើយយើង -- លោកដកស្រង់ពីសម្រង់ផ្សេងនៅភូមិផ្សេងនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួរហ្នឹងគឺវាមានភាពខុសគ្នាយ៉ាងច្បាស់ ដើម្បីកំណត់ថាភូមិទាំងពីរកោះផល ស្វាយឃ្លាំងហ្នឹងគឺខុសគ្នា ពីព្រោះជាភូមិនៅជិតគ្នា។ ខ្ញុំចង់សួរគាត់ថា តើគាត់ដឹងអ្វីខ្លះអំពីជនរងគ្រោះនៅក្នុងការបះបោរហ្នឹង? ហើយនិងតើគាត់អាចឆ្លើយដូចម្តេចបានចំពោះចម្លើយដែល ម៉ាត់ លី គាត់បានឆ្លើយក្នុងបទសម្ភាសន៍នោះ គឺខ្ញុំមិនចង់បានលើសពីហ្នឹងទេ លោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ប្រហែលជាភ្លេចសំណួរហើយ។ ម៉ាត់ លី បាននិយាយថា មានជនរងគ្រោះជាច្រើន នៅពេលដែលគេបង្ក្រាប់ជនជាតិ នៅក្នុងការបះបោរឆ្នាំ១៩៧៥។ តើលោកយល់ស្របជាមួយនឹងចម្លើយរបស់គាត់ ឬក៏លោកមិនយល់ស្របទេ?

**លោក សុះ រំលី៖**

**ឆ៖** អារឿងនៅស្វាយឃ្លាំង ហើយនិងកោះផល ខ្ញុំមិនដឹងទេ ព្រោះពីភូមិទ្រា ទៅកោះផល មិនមែន១គីឡូ ដូចលោកថានោះទេ គឺជាង១០គីឡូ។ ហើយពីស្វាយឃ្លាំងទៅកោះផលទៀត ប្រហែលជា

៥-៦គីឡូទៀត ហើយថាខ្ញុំធ្វើម៉េចដឹង ធ្វើម៉េចឮសូរកាំភ្លើង។ រឿងរ៉ាវទាំងអស់ជំនាន់នុំង គឺមិនអាចទាក់ទងគ្នាដោយងាយនោះទេ គឺពិបាកណាស់។ ធ្វើដំណើរទៅមកក៏ពិបាក។ ព័ត៌មានក៏ពិបាក ហើយលោកឲ្យខ្ញុំដឹងនៅកោះផល និងស្វាយឃ្លាំង គឺខ្ញុំអត់ដឹងទាំងអស់។

[១៤:១១:២០]

**ស៖** បាទ មិនមែនជាទេ លោកសាក្សី។ ថាខ្ញុំបានបញ្ជាក់រួចមកហើយ ថាភស្តុតាងនេះទំនងជាបង្ហាញថានាយករដ្ឋមន្ត្រីបច្ចុប្បន្ននេះ ក៏បានចូលរួមក្នុងការបង្ក្រាបការបះបោរជនជាតិចាម នៅខែតុលា ឆ្នាំ១៩៧៥ នៅកោះផល ហើយនិងស្វាយឃ្លាំង។ ហើយមនុស្សទី៣ ហេង សំរិន ជាប្រធានរដ្ឋសភា ក៏ធ្លាប់ធ្វើជាប្រធានយោធានៅភូមិភាគបូព៌ា ហើយជនស៊ីវិលដែលទទួលខុសត្រូវការបះបោរនេះ គឺនៅក្រូចឆ្មារហ្នឹង ដែលស្ថិតនៅក្នុងតំបន់២១ គឺជាសមាជិកព្រឹទ្ធសភាឈ្មោះ អ៊ុក ប៊ុនឈឿន មកពីបក្សប្រជាជនកម្ពុជា។ ហើយខ្ញុំសូមដកស្រង់ពីបទសម្ភាសន៍របស់គាត់ដែលគាត់បានឆ្លើយ ឯកសារ E3/387 ERN អង់គ្លេស 00350206 ទំនងជា បាទ មានភាសាបារាំង ERN 00441419 ដល់ -- ហើយខ្មែរ ERN 00374986 ដល់ 87។ ខ្ញុំនឹងដកស្រង់ពីរបីចំណុចពីបទសម្ភាសន៍របស់លោក អ៊ុក ប៊ុនឈឿន ឲ្យលោកស្ដាប់ ហើយគាត់និយាយដូចតទៅនេះ៖ “មានចលនាពីរប្រឆាំងនឹងពួកគេ។ ចលនាទី១ គឺចាមមូស្លីមនៅតាមបណ្ដោយទន្លេមេគង្គនៅត្បូងឃ្មុំ និងតំបន់២១ តំបន់២២។ ចលនាមានចេតនាបង្កើតរដ្ឋនៅក្នុងរដ្ឋ ពីព្រោះចាមមូស្លីមមានបំណងចង់កាន់កាប់ដីខ្មែរនៅត្រើយខាងកើតនៃប្រទេសកម្ពុជា ទៅដែលភ្ជាប់ទៅអាណ្ណាម ជារដ្ឋអាណ្ណាម”។

ផ្នែកទី២ តំបន់២១ ដែលស្ថិតនៅ -- ភូមិលោកនៅក្នុងហ្នឹងដែរ។ និយាយថា “ចាមមូស្លីមបង្កើតចលនាដើម្បីបង្កើតរដ្ឋនៅក្នុងរដ្ឋ”។ តើលោកធ្លាប់ឮសេចក្ដីថ្លែងការណ៍ ឬក៏ពាក្យបែបនេះទេ លោកសាក្សី?

**ឆ៖** បាទ ខ្ញុំអត់ដែលឮទេ។

[១៤:១៤:១៦]

**ស៖** គាត់និយាយថា អ្នកទាំងអស់នោះ ត្រូវបានគេបំផ្លាញកម្ទេច ហើយគាត់និយាយអំពីចលនាទី២ នៅ ថាក្បាល-ស បាទ ខ្មែរស។ នៅក្បាល-ស គឺធ្វើប្រតិបត្តិការទូទាំងប្រទេសនៅក្នុងឆ្នាំ៧៣, ៧៤ ដែលមានជនជាតិចាម និងខ្មែររួមគ្នា យើងមិនអាចរកឃើញមេដឹកនាំ ហើយមិនដឹងថាអ្នកណាជាមេទេ ប៉ុន្តែយើង -- អ្នកនេះជាអនុសេនីយ៍ឯក ជាវរសេនីយ៍ ប៉ុន្តែយើងមិនដឹងថាអ្នកហ្នឹងមកពីណាទេ។

ហើយបន្ទាប់មក គេនិយាយចលនាក្បាល-សនោះ គឺថាត្រូវបានដួលរលំ ហើយសមាជិកហ្នឹង ត្រូវបានគេចាប់។ តើលោកអាចឆ្លើយបញ្ជាក់ថាតើចលនាខ្មែរស ឬក៏ក្បាល-សហ្នឹងលោកធ្លាប់ឮអ្វីស្រដៀងៗហ្នឹងទេ ឬក៏លោកអាចបញ្ជាក់ជូនតុលាការដូចម្ដេចបានពីចម្លើយរបស់គាត់នេះ?

**ឆ៖** រឿងហ្នឹងខ្ញុំមិនដែលឮទេ រឿងចលនាខ្មែរស។ គ្រាន់តែឮថាចលនាខ្មែរស ប៉ុនឮតែប៉ុណ្ណឹង មិនដឹងមូលដ្ឋានរូបរាងគេនៅត្រង់ណា ខ្ញុំអត់ដឹងទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ការអានទូវចម្លើយដែលលោកមេធាវីគាត់បានអាននេះ និយាយអំពីចលនានេះដើម្បីបង្កើតរដ្ឋចាម។ អ្នកដែលផ្ដល់បទសម្ភាសន៍នៅក្នុងកិច្ចសម្ភាសន៍នោះនិយាយអំពីចលនានោះ ហើយផ្ដល់ជាប្រភព ដែលជាព័ត៌មាននៅទំព័រនោះ គឺមេធាវីមិនបានចំណុចនោះទេ។ នេះទាក់ទងទៅនឹងចម្លើយសារភាពរបស់ពួកគេ។ ដូច្នេះ ដោយជាក់ស្ដែង អ្វីដែលមេធាវីបានអាននោះ គឺខ្លឹមសារយកមកពីសេចក្ដីសារភាពដែលខ្មែរក្រហមគេបានចាប់ខ្លួន។

[១៤:១៦:៣២]

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាទឡ្ហីករណ៍ដ៏ល្អដើម្បីបុគ្គលរូបនោះមកធ្វើជាសាក្សី លោកប្រធាន លោកអង្គជំនុំជម្រះសាលាដំបូងគឺថ្ងៃទី១៨ ខែធ្នូ យើងបានដាក់សំណើហើយ សូមឲ្យពួកគាត់មកធ្វើសាក្សី គឺឯកឧត្ដម អ៊ុក ប៊ុនឈឿន ឲ្យមកធ្វើសាក្សី ក៏ប៉ុន្តែសំណើរបស់យើងមិនបានជោគជ័យទេ។ អ៊ីចឹងបើយើងចង់ដឹងថាគាត់ពឹកផ្អែកទៅលើចម្លើយសារភាព ឬក៏ជាភស្តុតាងដែលគាត់ដឹង ពេលដែលគាត់ឆ្លើយប្រាប់ទៅអ្នកសម្ភាសគាត់នោះ។

[១៤:១៧:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៧:២៤]

**ប្រធានអង្គជំនុំ៖**

បាទលោកមេធាវី លោកដឹងច្បាស់លាស់ហើយថា ព័ត៌មានដែលលោកយកមកសួរសាក្សីនេះ គឺ

ជាប្រភពដែលបានមកពីការធ្វើទារុណកម្ម ហើយលោកនៅតែព្យាយាមប៉ុនប៉ងក្នុងការធ្វើម្តងហើយម្តងទៀត។ ឥឡូវនេះ យើងមិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះទេ ហើយសំណួរបែបនេះក៏លោកមេធាវីមិនគួរគប្បីប្រើប្រាស់ទៀតដែរ ហើយសូមអនុវត្តឲ្យបានម៉ឺងម៉ាត់តាមសេចក្តីណែនាំអនុវត្តរបស់អង្គជំនុំជម្រះ ក៏ដូចជាអនុស្សរណៈស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម ហើយសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។ លោកអាចសួរសំណួរផ្សេងតទៅទៀតបាន។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយខ្លីលោកប្រធាន។ ខ្ញុំយល់ថា ជំហររបស់សាលាដំបូងទាក់ទងទៅនឹងចម្លើយសារភាពនៅស-២១ ប៉ុន្តែគាត់មិនបាននិយាយអំពីស-២១ទេ គាត់និយាយអំពីមន្ទីរស្រុកក្រូចឆ្មារ គឺមន្ទីរសន្តិសុខក្រូចឆ្មារ ហើយជាអកុសលនោះ គឺវាមិនមែនជាផ្នែកនៃអ្វីដែលយើងនិយាយនៅទីនេះនោះទេ។ ហើយដូច្នេះ យើងអាចនឹង--

**ប្រធានអង្គជំនុំ៖**

មន្ទីរណាក៏ដោយ ឲ្យតែព័ត៌មានបានមកពីការធ្វើទារុណកម្មមិនឲ្យប្រើប្រាស់ទេ វាជាព័ត៌មានមិនពិត ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយ! លោកតទៅមុខទៀត ប្រសិនបើលោកអស់សំណួរអង្គុយចុះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាឲ្យមេធាវីផ្សេងទៀតដែលនឹងបន្តសំណួរដេញដោលកុំឲ្យខាតពេល!

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំយល់ហើយ នេះជាបញ្ហាស្រួចស្រាល់ចំពោះអង្គជំនុំជម្រះចំពោះភាគីផ្សេងៗទៀត។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តទៅលោក ម៉ាត់ លី ម្តងទៀត។

[១៤:១៩:១៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកសាក្សី លោកមិនស្គាល់លោក ម៉ាត់ លី នោះទេ។ ប៉ុនគាត់បាននិយាយអំពីការប្រតិបត្តិសាសនា។ ខ្ញុំនឹងអានជូនលោកស្តាប់អំពីចម្លើយរបស់គាត់។ នៅក្នុងឯកសារ E3/7821 ម៉ាត់ លី ជាចាមដែលមានឋានៈខ្ពស់នៅក្នុងរបបនោះដែរ គាត់នៅក្នុងភូមិភាគបូព៌ា ហើយគាត់ក្លាយជាសមាជិកសភានៅឆ្នាំ១៩៧៦ ហើយគាត់បាននិយាយថា "នៅក្នុងរបប ប៉ុល ពត នៅក្នុងឆ្នាំ១៩៧៥ ពិធីបុណ្យសាសនាមិនត្រូវបានហាមឃាត់ទេ ប៉ុន្តែនៅថ្ងៃ៣០ កញ្ញា ត្រូវបានគេលើកការហាមឃាត់ចេញ ហើយគេសួរអំពីការហាមឃាត់ អំពីសាសនានេះ គេសួរគាត់ ហើយគាត់ឆ្លើយថា គេមិនមានការហាម

នោះទេ រហូតទាល់តែថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៦។ តើវាអ៊ីចឹងត្រឹមត្រូវដែរឬទេ តាមអ្វីដែលលោកចង់ចាំនោះ?

**លោក សុះ រលី៖**

**ឆ៖** កាលនុ៎ងការហាមឃាត់ខាងសាសនា ហាមផ្ដាច់នុ៎ងពីថ្ងៃរំដោះ ថ្ងៃវ៉ៃបែកភ្នំពេញ។ ពួកខ្មែរក្រហមវ៉ៃបែកភ្នំពេញហើយហ្នឹង ចាប់រឹតបន្តឹងតែម្ដង បិទទាំងវិហារ បិទទាំងអស់រឿងសាសនា។

**ស៖** អ៊ីចឹងលោកនិយាយថា ម៉ាត់ លី មិននិយាយត្រឹមត្រូវទេ អ្វីដែលគាត់និយាយថា គេមិនបានហាមឃាត់។ គាត់និយាយថា គេហាមហ្នឹងដល់ថ្ងៃ៣០ កញ្ញា ឆ្នាំ១៩៧៦ទេ បានគេហាម។ អ៊ីចឹងលោកនិយាយថា ម៉ាត់ លី ហ្នឹងខុស ឬយ៉ាងម៉េច?

**ឆ៖** រឿងដឹងខ្ញុំមិនដឹងទេ។

[១៤:២១:៤៥]

**ស៖** សំណួរចុងក្រោយមួយអំពីលោក ម៉ាត់ លី ហើយខ្ញុំដឹងថា -- មិនដឹងថា ច្បាស់ថាអ្នកណាមនុស្សនោះជាអ្នកណាទេ តែអាចត្រូវដែរឬទេដែលថាគាត់នៅក្នុងឆ្នាំ២០០០ មិនមែនជា ត្រឹមជាសមាជិករដ្ឋសភានៅក្នុងខេត្ត តំណាងខេត្តកំពង់ចាមទេ ប៉ុន្តែជាស្ថិតនៅក្នុងសមាជិកនៅឧត្តមក្រុមប្រឹក្សារាជបល្ល័ង្កផងដែរ។ តើលោកបានដឹងពីរឿងនេះទេ អំពីលោក ម៉ាត់ លី នោះ?

**ឆ៖** ខ្ញុំមិនបានដឹងទេរឿងនុ៎ង។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងកម្មាភិបាលនៅភូមិភាគបូព៌ា។ តើលោកចាំដែរឬទេថាមេដឹកនាំភូមិភាគបូព៌ានោះ នៅក្នុងឆ្នាំ១៩៧៥ អ្នកណាជាមេដឹកនាំភូមិភាគបូព៌ាខ្ពស់ជាងគេ ជាប្រធានភូមិ? តើលោកចាំទេ?

**ឆ៖** មេដឹកនាំខាងលើៗ ខាងភូមិភាគ ហើយតំបន់ខ្ញុំអត់ដែរដឹងទេ មិនដឹងឈ្មោះអី អ្នកកាន់ភូមិភាគ ខ្ញុំអត់ដឹងទេ ដឹងត្រឹមតែភូមិខ្ញុំហ្នឹង។

**ស៖** អ៊ីចឹងរវាងឆ្នាំ១៩៧៥ ដល់ ១៩៧៩ លោកមិនធ្លាប់ឮពាក្យមនុស្សម្នាក់ឈ្មោះ សោ ភឹម ទេឬ?

**ឆ៖** បាទ ឮៗ សោ ភឹម ខាងភូមិភាគ ប៉ុនមិនដឹងគាត់ប្រធាន ឬអនុ ខ្ញុំមិនដឹងទេ។ ឮថា ឮតែឈ្មោះ សោ ភឹម ហ្នឹង។

**ស៖** បាទ ខ្ញុំយល់។ ខ្ញុំដឹងថា លោកមិនមែនជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាទេ ប៉ុន្តែយ៉ាង

ហោចណាស់ក៏លោកមានតំណែងនៅថ្នាក់ឃុំ ថ្នាក់ភូមិនោះដែរ។ ហើយខ្ញុំនឹងអានសៀវភៅ ប៉ែន យៀរនិន ដែលនិយាយអំពីលោក សោ ភឹម។ ហើយខ្ញុំនឹងដកស្រង់។ លោកប្រធាន លោក យៀរនិន បានយោងបុគ្គលម្នាក់ដែលមានឈ្មោះថា ហែម –ហែម សាមិន– បាទៗ គាត់ជាសមាជិក ជាប្រធានគណៈកម្មការបដិវត្តមួយរវាងឆ្នាំ១៩៧៥ ៧៦, ហែម សាមិន ហ្នឹងនិយាយថា តាមលោក ប៉ែន យៀរនិន គាត់ដកស្រង់សម្ដីគាត់ គាត់កុម្មុយនីស្តហាណូយជាអតីតអ្នកទោសនៅក្នុងភូមិភាគ ហើយគាត់បានបន្ទោស សោ ភឹម ដែលជាលេខាភូមិភាគ អំពីការបង្ក្រាបជនជាតិចាម ហើយគាត់ជាអ្នកចុះហត្ថលេខាចេញបញ្ជាក្នុងការបង្ក្រាបសម្លាប់ជនជាតិចាម នៅភូមិទ្រាឆ្នាំ១៩៧៤ ឃោរឃៅ ដ៏ឃោរឃៅ ហើយ ហែម សាមិន ហ្នឹងក៏បាននិយាយថា សោ ភឹម ចុះហត្ថលេខាលើបទបញ្ជាឲ្យសម្លាប់ចាមនៅក្នុងភូមិរបស់លោក ហើយគាត់ហ្នឹងគឺជាមេរបស់លោក ហេង សំរិន និងលោក ហ៊ុន សែន។ តើលោកដឹងអំពីរឿងហ្នឹងដែរឬទេ លោកសាក្សី?

[១៤:២៥:៥៧]

**ឆ៖** អារឿងហ្នឹង ខ្ញុំអត់ដឹងទាល់តែសោះហើយ ព្រោះអីកាលហ្នឹង មិនមែនដូចសម័យបច្ចុប្បន្នមានព័ត៌មានអី ហើយដឹងអ្នកដឹកនាំឈ្មោះអ្វីដូចឥឡូវទេ គឺគេលាក់ការណ៍ជាទីបំផុតហើយ ជំនាន់ខ្មែរក្រហមនោះ។ គ្មានពីណាដឹងមេដឹកនាំឈ្មោះអ្វី ឈ្មោះស្រុកក៏មិនស្គាល់ដែរ ក៏មិនស្គាល់ថា ប្រធានស្រុកហ្នឹងឈ្មោះអ្វីដែរ។ ខ្ញុំធ្វើការនៅឃុំហ្នឹង ស្គាល់តែមេឃុំហ្នឹង អត់ស្គាល់ដល់ស្រុកអីទេ អត់ដែលឃើញទេ អត់ដែលទៅទៀត អត់ដែលទៅកន្លែងស្រុកទៀត។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ គឺព្រឹកមិញនេះលោកបាននិយាយអំពី គឺរណ្ដៅដែលលោកបានឃើញបន្ទាប់ពីឆ្នាំ១៩៧៩ លោកមិនបាននិយាយពិស្ដារអំពីស្ថានភាពពិស្ដារទាក់ទងទៅនឹងរណ្ដៅសាក-សព រណ្ដៅទាំងនោះទេ តើអាចទៅរួចដែរឬទេពីអ្វីដែលលោកបានដឹង ដែលបានលោកឆ្លងកាត់នោះ គឺឆ្អឹង ហើយនិងសាកសពដែលលោកបានឃើញ គឺជាជនរងគ្រោះនៃការបង្ក្រាបការបះបោរជនជាតិចាមនៅឆ្នាំ១៩៧៥គឺ -- ហើយជាចលនាបះបោរដែលត្រូវបានបង្ក្រាបដោយសមាជិករដ្ឋាភិបាលបច្ចុប្បន្ននេះ?

**ឆ៖** កន្លែងរណ្ដៅហ្នឹង ដំបូងជាដីភូមិរបស់ប្រជាជននៅក្បែរៗហ្នឹង អត់ដែលមានរណ្ដៅ ឬមានផ្នូរអីកន្លែងហ្នឹងម្ដងសោះ ហើយផ្នូរហ្នឹងមកកើតមានពីឆ្នាំ១៩៧៨មក នៅអំឡុងពាក់កណ្ដាលឆ្នាំ១៩៧៨ ហើយក្រោយរំដោះបានឃើញរណ្ដៅហ្នឹងតែម្ដង។ ពីមុនមក គឺអត់មានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណច្រើនលោកសាក្សី បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហ -- ការពារក្ដីលោកខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១៤:២៨:៤១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៅកាន់លោកក្នុងឋានៈខ្ញុំជាមេធាវី។ លោកបាននិយាយអំពីការហាមប្រាមមិនឲ្យប្រតិបត្តិសាសនាចាមចាប់ពីឆ្នាំ១៩៧៥មក បើខ្ញុំស្ដាប់មិនច្រឡំទេ គឺមុនឆ្នាំ៧៥ គឺនៅពេលដែលមានរណសិរ្ស និងខ្មែរក្រហមហ្នឹង គឺមុនឆ្នាំ៧៥ គឺលោកនៅមានសិទ្ធិប្រតិបត្តិសាសនានៅឡើយទេ។ តើអ៊ីចឹងមែនទេ?

**លោក សុះ រំលី៖**

**ឆ៖** បាទ ពិតមែន អ៊ីចឹងហើយ។

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី លោកថាគេហាមមិនឲ្យប្រតិបត្តិសាសនាហ្នឹង មិនត្រឹមតែចំពោះសាសនាចាមទេ គឺសាសនាទាំងអស់ដែលគេចាត់ទុកថាជាប្រតិកិរិយា គឺគេហាមមិនឲ្យៗប្រតិបត្តិទេ ទាំងអស់តែម្ដង គ្រប់សាសនា តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** លោកអាចជម្រាបជូនបានទេថា នៅពេលដែលខ្មែរក្រហមតែងតាំងលោកនៅក្នុងកងយុវជននោះ តើគ្រួសាររបស់លោកមានឋានៈ ឬក៏មានវណ្ណភាពយ៉ាងម៉េចដែរ? ជាគ្រួសារក្រីក្រ ជាគ្រួសារធូរធារ ឬអ្នកមាន?

**ឆ៖** បាទ ខ្ញុំជាគ្រួសារក្រីក្រ។

សៈ តើលោកដឹងទេ ដោយសារតែលោកស្ថិតនៅក្នុងគ្រួសារក្រីក្របែបនេះហើយបានជាគេតែងតាំងលោកនោះ មែនទេ?

ឆៈ បាទ មែនហើយ។

[១៤:៣១:១៨]

សៈ អ៊ីចឹងគេមានប្រាប់លោកដោយផ្ទាល់ទេថា លោកដោយលោកជាគ្រួសារក្រីក្រអ៊ីចឹង?ឥឡូវខ្ញុំសួរអ៊ីចេះ ពីអ៊ីចេះវិញសិនមុនដំបូង គឺចង់ដឹងថាអ្នកណាជាអ្នកតែងតាំងលោក?

ឆៈ ដំបូងមេភូមិនុំងហៅខ្ញុំធ្វើតែម្តង។

សៈ មេភូមិហ្នឹង គាត់ឈ្មោះអីដែរ?

ឆៈ មេភូមិនុំង គាត់ឈ្មោះ សា ម៉ាត់ន។

សៈ គាត់ជាជនជាតិចាម ឬក៏ខ្មែរ?

ឆៈ បាទ ជនជាតិចាម។

សៈ សា ម៉ាត់ន នេះហើយជាអ្នកប្រាប់លោកថា ដោយសារតែលោកជាអ្នកក្រីក្រអ៊ីចឹង បានគេតែងតាំងលោកនុំង? គាត់ប្រាប់លោកអ៊ីចឹងទេ នៅពេលនោះ?

ឆៈ ពេលនុំងគេមិនប្រាប់ទេ។ ក្រោយមក ខ្ញុំឮតាមគេ តាមឯង តាមប្រធានយុវជនឃុំនុំង គេថាការចាត់តាំង គឺជ្រើសរើសវណ្ណភាព ពិសេសវណ្ណៈក្រីក្រ។

សៈ លោកបានឆ្លើយថា នៅភូមិទ្រា មានភូមិចាមបី ហើយនិងភូមិខ្មែរពីរ។ ដូច្នេះខ្ញុំចង់ដឹងថានៅមុនឆ្នាំ១៩៧០ តើភូមិទាំងអស់នេះ មានទំនាក់ទំនងគ្នាទេ?

[១៤:៣៣:៥២]

ឆៈ បាទ ខ្ញុំសូមកែតម្រូវ។ ខ្ញុំមិនដែលឆ្លើយថា ភូមិចាមបីទេ ខ្ញុំថា ភូមិចាមប្រាំភូមិ ភូមិខ្មែរ បីភូមិ។ ភូមិទាំងអស់នោះមានទំនាក់ទំនងជាមួយគ្នា អត់អីទេ។

សៈ សូមអរគុណដែលបានកែតម្រូវខ្ញុំ។ ខ្ញុំសូមអភ័យទោស ដែលខ្ញុំសួរខុស ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់សង្កត់ធ្ងន់នោះ គឺទំនាក់ទំនងរវាងភូមិចាម និងខ្មែរនេះទេ។ អ៊ីចឹងមានន័យថា ភូមិទាំងប្រាំបីហ្នឹង គឺទាំងចាម ទាំងខ្មែរហ្នឹង មានទំនាក់ទំនងនឹងគ្នាទៅមក។ អ៊ីចឹងមែនទេ?

ឆៈ បាទ អត់អីទេ មានទំនាក់ទំនងគ្នាល្អ មានការសាមគ្គីស្អីទៅវិញទៅមកបានល្អ អត់អីទេ។

សៈ នៅក្នុងប្រពៃណីចាម គឺគេចូលចិត្តឲ្យចាមហ្នឹងរៀបការជាមួយនឹងចាមគ្នាឯង។ បើខ្ញុំ

និយាយអ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ចុះត្រឹមត្រូវទេ ប្រសិនបើខ្ញុំនិយាយថា បុរសចាមអាចរៀបការជាមួយប្រពន្ធដែលមិនមែនជាជនជាតិចាម គឺអាចជាជនជាតិថ្មីសក៏បាន កាតូលិកក៏បាន។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** មុនឆ្នាំ១៩៧៥ ជនជាតិចាម និងជនជាតិខ្មែរមានរៀបការជាមួយគ្នាជាហូរហែជាធម្មតា។ តើមែនទេ?

**ឆ៖** សុំទោស ខ្ញុំស្តាប់មិនទាន់ សូមតាំងសំណួរម្តងទៀត។

**ស៖** មិនអីទេ ខ្ញុំប្រហែលជាអាចសួរវង្វេងវង្វាន់បន្តិច។ ឥឡូវខ្ញុំចង់សួរលោកថាអ៊ីចេះ មុនឆ្នាំ១៩៧៥នោះ តើជនជាតិចាម និងជនជាតិខ្មែរហ្នឹងរៀបការជាមួយគ្នាជាធម្មតា ឬក៏ពេលនុ៎ង គឺមុន៧៥ ហ្នឹងចាមរៀបការតែជាមួយចាមគ្នាឯងទេ?

**ឆ៖** រឿងរៀបការហ្នឹង មិនដែលមានរៀបការជាមួយគ្នាទេ បើថាមានស្រឡាញ់គ្នាអីមាន ហើយយកមករៀបការក្រោយ ហើយការងារហ្នឹងមានបន្តិចបន្តួចអត់ច្រើនទេ។

**ស៖** ឥឡូវនេះខ្ញុំចូលទៅនិយាយចាប់ពីឆ្នាំ៧៥ លោកបាននិយាយអំពីឈ្មោះ ហូ ជាមេស្រុក។ លោកស្គាល់ឈ្មោះ ផ្សេងពី ផ្សេងទៀតទេ របស់ ហូ ហ្នឹង លោកដឹងថា ហូ ហ្នឹងមានឈ្មោះអីផ្សេងទៀតទេ?

**ឆ៖** បាទខ្ញុំសូមម្តងទៀត។ ថា ហូ ជំនាន់ ហូ មិនមែន១៩៧៥ ទេ គឺឆ្នាំ១៩៧៨ ហើយខ្ញុំមិនដែលស្គាល់ តាហូ ហ្នឹង មានឈ្មោះផ្សេងទៀតទេ។

[១៤:៣៨:១៧]

**ស៖** លោកឃើញ ហូ ដែលជាមេស្រុកហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំធ្លាប់ឃើញគាត់តែពីរដង គាត់មកដំបូងម្តង ហើយបានប្រហែលជាពីរបីខែ គាត់ប្រជុំ ហើយមេឃុំហ្នឹងហៅខ្ញុំទៅជាមួយ។ ធ្លាប់ជួបតែពីរដងហ្នឹង។

**ស៖** ពេលជួបពីរដងហ្នឹង លោកឃើញគាត់ជិះម៉ូតូ ឬក៏លោកមិនដឹងថាគាត់ជិះអីទេ?

**ឆ៖** ដំបូងឃើញៗគាត់ដើរនៅមុខវិហារជនជាតិចាមហ្នឹងម្តង ដំបូងគេបង្អស់ ហើយក្រោយមកឃើញគាត់ចូលកន្លែងប្រជុំតែម្តង។

**ស៖** លោកអាចជម្រាបបានទេថា ហូ គាត់មកប្រជុំក្នុងថ្ងៃហ្នឹង ប្រជុំដើម្បីអីដែរ?

**ឆ៖** ហូ មកប្រជុំកាលហ្នឹងលើកផែនការតែពីការបង្កបង្កើនផលមួយមុខ អត់មានរឿងអីទេ។

**ស៖** អ៊ីចឹងការប្រជុំដែលមានវត្តមាន ហូ ហ្នឹងគឺលោកចូលរួមបានតែម្តងហ្នឹងគត់មែនទេ?

**ឆ៖** បាទ មានតែម្តងគត់។

**ស៖** លោកបាននិយាយអំពីការពិភាក្សាគ្នាជាមួយនឹងប្រធានសន្តិសុខ ហើយពេលហ្នឹងគេសួរលោកថា មានវត្តមានជនជាតិចាមនៅក្នុងភូមិដែរឬទេ? លោកអាចជម្រាបម្តងទៀតបានទេ ថាការជជែកគ្នា ឬក៏ពិភាក្សាគ្នាហ្នឹងនៅពេលណាដែរ?

**ឆ៖** នៅឆ្នាំ១៩៧៧ហ្នឹង ខ្ញុំមិនជជែកជាមួយគាត់ទេ គាត់សួរខ្ញុំថាផ្ទះហ្នឹងគេទៅណាអស់? ខ្ញុំថាផ្ទះជនជាតិចាម គេជម្លៀសតាំងពីចុងឆ្នាំ១៩៧៥មកទៅខាងភូមិភាគកណ្តាលអស់ហើយ។ ហើយគាត់ក៏បន្ថែមខ្លួនឯងថា ចាមអស់ទាំងនេះអនាគតទៅគេកម្ទេចទាល់តែអស់។

**ស៖** ពេលនោះ លោកដឹងយ៉ាងម៉េចបានថាគាត់ហ្នឹងជាប្រធានសន្តិសុខ?

**ឆ៖** គាត់មកគាត់ឲ្យខទ្មេសនាមខ្ញុំមើល គាត់សុំជួបមេឃុំ។ គាត់សួរថា មេឃុំទៅណា? ខ្ញុំថាអត់នៅទេ គាត់ខទ្មេសនាមថាគាត់នៅខាងសន្តិសុខតំបន់ គាត់មកសុំធ្វើការជាមួយមេឃុំ។

[១៤:៤១:១៧]

**ស៖** លោកអាចបញ្ជាក់ម្តងទៀតបានទេនៅឆ្នាំ១៩៧៧ ហ្នឹងអ្នកណាជាមេឃុំ?

**ឆ៖** បាទ កាលនោះ ឈាន ឈ្មោះ ឈាន ជាមេឃុំ។

**ស៖** លោកថា ប្រធានសន្តិសុខនោះមានមនុស្សម្នាក់មកអមជាមួយ លោកដឹងថាម្នាក់ទៀតដែលអមជាមួយប្រធានសន្តិសុខហ្នឹងមានមុខនាទីអីទេ?

**ឆ៖** ខ្ញុំអត់ដឹងផង។

**ស៖** ខ្ញុំមានសំណួរមួយប្រហែលជាលោកគិតថាឆោតល្ងង់បន្តិច ក៏ប៉ុន្តែខ្ញុំមិនយល់ច្បាស់អំពីអ្នកដែលជាជនជាតិចាម ចំពោះខ្ញុំ ខ្ញុំមើលទៅ បើមើលមុខលោកទៅ ខ្ញុំគិតថាប្រហែលជាអាហ្វ្រិកខាងជើង ឬក៏អីទៅវិញទេ ខ្ញុំមើលទៅដូចជាមិនដូចជាខ្មែរទេ។ អ៊ីចឹង ខ្ញុំសួរចង់ដឹងថា ពេលដែលគេមកសួរអំពីជនជាតិចាមអ៊ីចឹង តើគេមានសួរពីរូបរាងខាងក្រៅអីយ៉ាងម៉េចទេ?

**ឆ៖** គេមិនសួរអ្វីទាំងអស់ គេសួរ -- គេអត់ដឹងថាខ្ញុំចាមផងកាលនោះ។ កាលនោះ ខ្ញុំនិយាយខ្មែរច្បាស់ជាងឥឡូវនេះ ព្រោះកាលនោះនិយាយតែខ្មែរ អត់និយាយចាមសោះ។ អ៊ីចឹងគេដឹងថា ខ្ញុំខ្មែរ

គេសួរនោះ គេអត់ដឹងថាខ្ញុំចាមទេ ហើយគេមិនសួរពីអតីតកាល ឬខ្ញុំជាអ្វីទៀតទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយសម្រាប់ពេលត្រូវសម្រាកហើយ ហើយមុននឹងសម្រាកសុំសួរលោកខាងក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន តើមានសំណួរនៅច្រើនទេ តើត្រូវការពេលវេលាប្រហែលជាប៉ុន្មានទៀតក្នុងការតាំងសំណួរសាក្សីរូបនេះ ដើម្បីអង្គជំនុំជម្រះមានព័ត៌មានសមស្របសម្រាប់ជម្រាបជូនទៅខាងកិច្ចការដឹកជញ្ជូនបុគ្គលិក អ.វ.ត.ក ត្រឡប់ទៅរាជធានីភ្នំពេញវិញ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនសួរមានច្រើនប៉ុន្មានទៀតទេលោកប្រធាន ប្រហែលជា១៥ ទៅ ២០នាទីហ្នឹងច្រើនពេកហើយលោកប្រធាន។ ហើយលោកមេធាវី គង់ សំអុន គាត់អត់មានសំណួរអីទៀតទេ តែខ្ញុំសួរហើយគឺចប់តែម្ដងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវព័ត៌មានល្អនេះ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហមេធាវីជាតិ

-- អ៎! មេធាវីការពារក្ដីលោក ខៀ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកសាក្សី ខ្ញុំសូមបន្តសួរលោកទៀត។ អម្បាញ់មិញនេះ ខ្ញុំសួរអំពីប្រធានសន្តិសុខ។ ដូច្នេះ ខ្ញុំចង់ដឹងថាអ្នកណាជាមេរបស់គាត់ទេ?

**លោក សុះ រំលី៖**

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីពេលដែល ហ្វូ ជាប្រធានស្រុក។ លោកចាំទេថាលោកមានជំនួយការ ឬក៏អនុប្រធានហ្នឹងប៉ុន្មាននាក់ដែរ ហើយមានឈ្មោះអីខ្លះ?

**ឆ៖** ខ្ញុំចាំ -- អត់ចាំទេ ព្រោះខ្ញុំអត់ដឹងថាគាត់ គ្រាន់តែដឹងថាគាត់មានគ្នា៣០នាក់ ប៉ុន្តែអ្នកណាអនុ អ្នកណាធ្វើអីខ្លះ ខ្ញុំអត់ដឹងទេ។ អត់បានទៅក្បែរទេ គេមកពីខាងភូមិភាគកណ្ដាលហ្នឹង។

**ស៖** ក្រោយពេល ហ្វូ មកដល់ លោកធ្លាប់ឮគេនិយាយអំពីហេតុការណ៍មួយ ដែលក្នុងពេលនោះគឺមានសមាជិកស្រុកនោះ ត្រូវបានគេបង្ករបួសស្នាម។ លោកធ្លាប់ឮអំពីហេតុការណ៍ហ្នឹងទេ?

**ឆ៖** ខ្ញុំមិនដែលឮទេ។

[១៥:០៥:៣៨]

**ស៖** កាលពីសវនាការថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ គឺក្រោយម៉ោងបី ប្រាំនាទីបន្តិច ឈ្មោះ បាន សៀក បាននិយាយអំពី "វត្តមានរបស់ ហ្វូ នៅលើទូក" ហើយលោកថាមានការបាញ់ទៅលើអនុប្រធានស្រុក គឺស្រុកក្រូចឆ្មារ។ លោកមានចាំហេតុការណ៍ហ្នឹងទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ហេតុការណ៍ហ្នឹង។

**ស៖** លោកបាននិយាយអំពីឈ្មោះ យាយយ៉ -- យ៉ូប គាត់ជាចាម ហើយជាប្រធានកងនេសាទ។ លោកអាចបញ្ជាក់បានទេ ថាគាត់ជាប្រធានកងនេសាទហ្នឹង នៅពេលណាដែរ?

**ឆ៖** គាត់ជាប្រធានកងនេសាទ នៅឆ្នាំ១៩៧៤មក។

**ស៖** គាត់នៅជាប្រធានកងនេសាទនុ៎ង រហូតដល់ឆ្នាំណា?

**ធ៖** ឆ្នាំ១៩៧៨ ពេលដែល ហូ មកដល់ ហើយចាប់ខ្លួនគាត់យកទៅ។

**ស៖** ដូច្នេះ ពីឆ្នាំ៧៤ ដល់ឆ្នាំ៧៨ហ្នឹង គាត់នៅជាប្រធានកងនេសាទហ្នឹង មែនទេ?

**ធ៖** បាទ គាត់នៅប្រធាននេសាទរហូត។

**ស៖** កាលពីព្រឹកមិញនេះ លោកឆ្លើយជូនអង្គជំនុំជម្រះថា បងប្អូនរបស់លោកបួននាក់នៅជាមួយលោកក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹង លោកអាចជម្រាបបានទេ ពួកគាត់ហ្នឹងធ្វើការទេ ហើយបើធ្វើហ្នឹង ធ្វើអីដែរ?

[១៥:០៨:២១]

**ធ៖** បាទ ប្អូនខ្ញុំទី១ហ្នឹង គាត់ធ្វើខាង គាត់ដាំបាយ ចង្ក្រានបាយ ហើយទី២ ហើយនិងទី៣ហ្នឹង គាត់នៅកងចល័ត។

**ស៖** ពួកគាត់នៅធ្វើការរហូតដល់ពេលវៀតណាមវាយចូលនៅឆ្នាំ៧៩ មែនទេ?

**ធ៖** បាទ ធ្វើរហូតទាល់តែវៀតណាមមកដល់។

**ស៖** ខ្ញុំសូមត្រឡប់មកក្រោយបន្តិច ខ្ញុំភ្លេចសួរអម្បាញ់មិញ។ លោកថាមុនពេល ហូ មកដល់ លោកបានរត់ គឺនៅក្បែរៗផ្ទះលោកនៅក្នុងព្រៃ។ ហើយលោកថាពេលនុ៎ង មានខ្មែរមួយចំនួនដែរ ដែលរត់ទៅជាមួយលោកក្នុងពេលដំណាលគ្នាហ្នឹង តែលោកមិនដឹងថាគេរត់ទៅណាទេ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ធ៖** រត់កាលហ្នឹង រត់ដោយខ្លួនៗទេ មិនមែនរត់ជាមួយគ្នាទេ។ ហើយការរត់ដែលមានបងប្អូនខ្មែរទៅជាមួយ រត់ទាំងភូមិទាំងអស់ហ្នឹង រត់វៀបនឹងដាច់ហើយ។ នៅថ្ងៃទី០១ ខែមករា ហើយ អាហ្នឹងរត់ រត់មែនទែនតែម្តង។ ហើយខ្ញុំក្រែងថា កំណត់ហេតុហ្នឹងច្រឡំពាក់ព័ន្ធគ្នារវាងរត់ទាំងពីរហ្នឹង។ ដំបូងគ្រាន់តែគេចខ្លួនទេ គេចខ្លួននៅក្បែរៗផ្ទះហ្នឹង។ ហើយការរត់មែនទែន រត់ពេលដែលកងយោធា ប៉ុល ពត បានកៀរស្រែកមីក្រូឲ្យទៅជាមួយគេ។ ពេលហ្នឹងរត់ រត់បានប្រហែលជាមួយអាទិត្យ ឮថាបែកភ្នំពេញ ០៧ មករា។

**ស៖** ហ្នឹង លោកនិយាយអំពីគេរត់គេចពេលវៀតណាមវាយចូល ប្រហែលជាខ្ញុំស្តាប់មិនត្រូវ។ ប៉ុន្តែខ្ញុំយល់ថា មុនពេល ហូ មកដល់នោះ លោកបានគេចទៅក្បែរៗផ្ទះលោកហ្នឹង។ ខ្ញុំយល់ហ្នឹងត្រូវទេ?

**ធ៖** ខ្ញុំមិនរត់គេចពីវៀតណាមវ៉ៃចូលទេ។ ខ្ញុំរត់គេចពីរបប ប៉ុល ពត ហ្នឹង ពួកយោធាខ្មែរ

ក្រហមហ្នឹងកៀរៗប្រជាជននៅក្នុងភូមិហ្នឹងឲ្យទៅជាមួយគេ រត់ពេលហ្នឹង មិនមែនដោយសារយួនវៃចូលទេ។

**ស៖** ខ្ញុំចង់ដឹងពេលដែលលោករត់គេចនោះ រត់គេច។ ក្នុងសវនាការ លោកថាពេល ហ្វូ មកដល់គឺមុនពេលគេតែងតាំងគាត់បន្តិចឲ្យធ្វើជាមេស្រុកហ្នឹង លោករត់គេច តែនៅក្បែរៗផ្ទះហ្នឹងទេ។ អ៊ីចឹងខ្ញុំស្ដាប់សក្ខីកម្មរបស់លោកហ្នឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ពេល ហ្វូ មកដល់ហ្នឹង ខ្ញុំគេចក្បែរៗផ្ទះហ្នឹង។

**ស៖** អ៊ីចឹងពេលនុ៎ង មិនមែន ០១ មករា ៧៩ ទេ គឺនៅឆ្នាំ៧៨ មែនទេ?

**ឆ៖** បាទ មែនហើយ។

[១៥:១២:១១]

**ស៖** គឺពេល ៧៨ ហ្នឹងហើយដែលខ្ញុំចាប់អារម្មណ៍នោះ។ ប្រសិនបើខ្ញុំនិយាយខុស សូមលោកកែតម្រូវ។ លោកថាពេលឆ្នាំ៧៨ ហ្នឹងមិនមែនមានតែម្នាក់ឯងទេ ដែលរត់នុ៎ងលោកហ្នឹង គឺមានអ្នកផ្សេងទៀតក៏គេរត់ទៅដែរ។ មែនទេ?

**ឆ៖** ហ្នឹងខ្ញុំសូមនិយាយម្ដងទៀតថា មិនមែនជារត់ទេ គេចខ្លួន គេចឲ្យបាត់ពីមុខក្រុម ហ្វូ ហ្នឹង សូម្បីតែមេឃុំ អនុឃុំ ឬតាយ៉ា យ៉ូប ក៏គេចដែរ។ គាត់ តាយ៉ា យ៉ូប ហ្នឹងគេចពីអង្គភាពៗគាត់មកនៅផ្ទះគាត់នៅភូមិទ្រា២ ហ្នឹង។ ហើយមេឃុំហ្នឹង ហើយនិងអនុឃុំហ្នឹង ផ្ទះណាដែលគាត់ស្គាល់ គាត់គេចទៅនៅក្បែរៗផ្ទះ នៅផ្ទះគាត់ស្គាល់នុ៎ង។ ហើយអ្នកអង្គភាពដទៃទៀត ភាគច្រើននៅឃុំទ្រាហ្នឹង រត់គេចទៅតាមផ្ទះខ្លួនឯងហ្នឹង ក្បែរៗហ្នឹង។

**ស៖** អ៊ីចឹងអ្នកដែលគេចខ្លួនហ្នឹង មានទាំងខ្មែរ ទាំងចាមមែនទេ?

**ឆ៖** បាទ ទាំងខ្មែរ ទាំងចាម ហើយភាគច្រើនខ្មែរទេ មិនភាគច្រើនចាមទេ។ ចាមមានតែខ្ញុំម្នាក់ ហើយនិងឈ្មោះ យ៉ា យ៉ូប ហ្នឹងម្នាក់ គេចពីអង្គភាពគាត់មកហ្នឹង។

**ស៖** លោកលាក់ខ្លួនក្បែរៗផ្ទះហ្នឹង ប្រហែលជាប៉ុន្មានពេល -- ថ្ងៃដែរ?

**ឆ៖** បានប្រហែលជាមួយថ្ងៃ ពីរថ្ងៃ ឮសួរថាចាប់មេឃុំបាន ហើយនិងអនុឃុំបាន ចាប់តា យ៉ា យ៉ូប ហ្នឹងបានហើយ។

**ស៖** ចុះលោក ពេលលោកចេញមកវិញ ចូលមកវិញ លោកទទួលមុខងារដដែលទេ?

**ឆ៖** ពេលនោះខ្ញុំមិនទាន់ទទួលភ្លាមៗទេ ទាល់តែដល់ ហ្វូ នុ៎ងតែងតាំងឈ្មោះ ម៉េង ធ្វើមេឃុំ

បានឈ្មោះ ម៉េង នុំងហៅខ្ញុំឲ្យធ្វើស្មៀនគាត់។

**ស៖** លោកធ្លាប់ស្គាល់ ម៉េង នេះពីមុនមកទេ?

**ឆ៖** ម៉េង ខ្ញុំមិនធ្លាប់ស្គាល់ពីតូច ពីមុនមកទេ ប៉ុន្តែទើបតែស្គាល់គាត់ជម្លៀសមកនៅភូមិទ្រា។ គាត់ជម្លៀសមកនៅភូមិទ្រា ទើបខ្ញុំស្គាល់គាត់។

**ស៖** លោកដឹងទេ ហេតុអ្វីបានជា ម៉េង នេះស្នើតែងតាំងលោកជាស្មៀនឃុំ?

**ឆ៖** ខ្ញុំមិនដឹងទេ ប្រហែលជាគាត់ឃើញខ្ញុំធ្វើស្មៀនកន្លងមក មិនដឹង ស្អីមិនដឹង ខ្ញុំមិនដឹងទេ ស្រាប់តែគាត់ហៅខ្ញុំធ្វើស្មៀនតែម្តង។

[១៥:១៥:៥៥]

**ស៖** លោកដឹងថា មានអ្នកណាណែនាំទៅ ម៉េង ហ្នឹងឲ្យចាត់តាំង ឬក៏តែងតាំងលោកហ្នឹងទេ?

**ឆ៖** អត់បានដឹងទេ។

**ស៖** ចំណុចចុងក្រោយដែលខ្ញុំចង់សុំការបំភ្លឺពីលោក លោកបាននិយាយអំពីកន្លែងមួយដែលលោកបានឃើញរណ្តៅនៅឆ្នាំ១៩៧៨ លោកថារណ្តៅទាំងអស់ហ្នឹង គឺថាមាននៅឆ្នាំ៧៨ ហើយលោកថានៅពេលមួយនោះ គឺមានទឹកជំនន់ជន់លិចកន្លែងដែលរណ្តៅនោះ។ លោកអាចបញ្ជាក់បានទេថា នៅឆ្នាំ៧៨ហ្នឹង នៅពេលណាដែរ ខែណាដែរ រដូវណាដែរ ដែលមានទឹកជំនន់ហ្នឹង?

**ឆ៖** ទឹកជំនន់នៅឆ្នាំ១៩៧៨ ហ្នឹងនៅក្នុងខែ៩។

**ស៖** ចុះពីខែឧសភា ទៅដល់ខែកញ្ញា ៧៨ លោកធ្លាប់ទៅកន្លែងហ្នឹងទេ?

**ឆ៖** អត់ធ្លាប់ទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណដែលលោកបានឆ្លើយបញ្ជាក់។ លោកប្រធានញ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអរគុណ បាទ។ ដល់ពេលនេះ សវនាការស្តាប់សក្ខីកម្ម សុះ រំលី បានដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះក៏សូមអរគុណលោក សុះ រំលី ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនាពេលនេះលែងមានចំបាច់ទៀតហើយ លែងចាំបាច់ទៀតហើយនៅ អ.វ.ត.ក លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោល

ដៅណាដែលលោកមានបំណងចង់ទៅបានហើយ សូមលោកជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន និងមានសុខភាពល្អ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក សុះ រំលី វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់បំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះក៏សូមអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី ហើយលោកអាចសម្រាកបានហើយ។

សវនាការនៅថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវ-នាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ចាប់ពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-987 ពាក់ព័ន្ធនឹងអង្គហេតុការប្រព្រឹត្តទៅលើក្រុមមនុស្សជាគោលដៅជាក់លាក់ចំពោះជនជាតិចាម សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅថ្ងៃចន្ទ ទី១១ ខែមករា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:១៩ នាទី)*